# សង្គ្រាតការណ៍

២៨

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




គណៈប្រតិភូនៃរដ្ឋាភិបាលរួបរួមជាតិ ទស្សនកិច្ចប្រទេសចិនក្នុងអំឡុងដើមទសវត្សរ៍៧០

(បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)


មជ្ឈមណ្ឌលឯកសារកម្ពុជា◆ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌◆www.dccam.org

ខែមីនា-មេសា ឆ្នាំ២០១៤

# មាតិកា

ខែមីនា-មេសា ឆ្នាំ២០១៤




១ ដំណើរវិវឌ្ឍន៍ប្រកបដោយភាពស្មុគស្មាញនៃសំណុំរឿង០០៣ និង០០៤

១៣ ការវិវត្តន៍ និងបញ្ហាប្រឈមផ្នែកថវិកានៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

២២ វិសាលភាពនៃសំណុំរឿង០០២/០២

៣២ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើវិសាលភាពសំណុំរឿង០០២/០២

៣៥ អង្គជំនុំជម្រះសាលាដំបូងសម្រេចចាត់តាំងអ្នកជំនាញឱ្យពិនិត្យ សម្បទារបស់ជនជាប់ចោទសាជាថ្មី

៣៧ វិសាលភាពនៃការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២/០១



លីម ជ័យទត្ត, ឌី សុជាតា,
ចាន ប្រាថ្នា, និង ទូន ឡៃហុល

ពិនិត្យ និងផ្ទៀងផ្ទាត់ដោយ វ៉ាន់ថាន់ ពៅដារ៉ា
និង ជី ទេវិទ្ធិ


*យុវជនខ្មែរក្រហមកំពុងហ្វឹកហាត់ ។ រូបនេះត្រូវបានបោះពុម្ពនៅលើប័ណ្ណប្រៃសណីយ៍នៃរបបកម្ពុជាប្រជាធិបតេយ្យ (បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)*

# ដំណើរវិវឌ្ឍន៍ប្រកបដោយភាពស្មុគស្មាញនៃសំណុំរឿង០០៣ និង០០៤

លីម ជ័យទ័ត្ត

## *សេចក្តីសង្ខេប*

បន្ទាប់ពីបញ្ចប់ទាំងស្រុងនៃសំណុំរឿង០០១ ករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច និងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ ចម្ងល់ជាច្រើនបានលើកឡើងទាក់ទងនឹងដំណើរវិវឌ្ឍន៍នៃសំណុំរឿង០០៣ និង០០៤ ថាតើសំណុំរឿងទាំងពីរនេះអាចនឹងត្រូវបានលើកយកមកជំនុំជម្រះសេចក្តី ដូចជាសំណុំរឿង០០១ និង០០២ ដែរឬយ៉ាងណា ។

ចាប់តាំងពីមានការបើកការស៊ើបអង្កេតជាផ្លូវការពីសំណាក់សហព្រះរាជអាជ្ញាក្នុងឆ្នាំ២០០៨ ជនសង្ស័យចំនួន៥រូប ត្រូវបានបង្ហាញថា មានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ក្នុងសំណុំរឿង០០៣ និង០០៤។ សំណុំរឿងទាំងពីរនេះកំពុងតែស្ថិតនៅក្រោមការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ប៉ុន្តែរហូតមកទល់នឹងពេលបច្ចុប្បន្ននេះ ពុំទាន់មានជនសង្ស័យណាម្នាក់ត្រូវបានចោទប្រកាន់ជាផ្លូវការនៅឡើយ ហើយអត្តសញ្ញាណរបស់ជនសង្ស័យទាំង៥រូប ក៏កំពុងស្ថិតនៅជាការសម្ងាត់ ។ ទោះបីជាយ៉ាងណាក្តី មានសារព័ត៌មានជាតិ និងអន្តរជាតិជាច្រើន បានផ្សព្វផ្សាយជាបន្តបន្ទាប់ពីឈ្មោះរបស់ជនសង្ស័យទាំង៥រូប បន្ទាប់ពីមានការលេចធ្លាយនូវឯកសារសម្ងាត់របស់តុលាការនៅអំឡុងខែមិថុនា ឆ្នាំ២០១១ ។ អ្នកទាំង៥រូបត្រូវបានសហព្រះរាជអាជ្ញាអន្តរជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិអះអាងថា ជាបុគ្គលដែលស្ថិតនៅក្រោមដែនយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជាអ្នកដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ។[១]

ទោះបីជា នៅពេលបច្ចុប្បន្នសំណុំរឿង០០៣ និង០០៤ បានឈានទៅដល់ដំណាក់កាលបង្ហាញអំពីទីតាំងឧក្រិដ្ឋកម្ម ទទួលយកសំណើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងមានការអនុញ្ញាតឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចចូលពិនិត្យមើលឯកសារក្នុងសំណុំរឿងក៏ដោយ ក៏ដំណើរវិវឌ្ឍន៍នៃសំណុំរឿងនេះនាពេលកន្លងទៅបានជួបប្រទះនឹងឧបសគ្គជាច្រើន ។ នៅអំឡុងពេលនៃដំណើរទស្សនកិច្ចរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក បាន គីមូន នៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ២០១០ ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្លាប់បានបង្ហាញអំពីជំហរពុំចង់ឲ្យមានសំណុំរឿងបន្ថែមក្រៅពីសំណុំរឿង០០១ និង០០២ ដោយលើកឡើងពីហេតុផលអស្ថិរភាព និងអាចបង្កឲ្យមានចលាចលសង្គម ហើយប៉ះពាល់ដល់គោលនយោបាយផ្សះផ្សាជាតិរបស់កម្ពុជា ។[២] រីឯភាគីជាតិនៃតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម រាប់ចាប់តាំងពីសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត និងចៅក្រមអង្គបុរេជំនុំជម្រះ សុទ្ធតែបានបង្ហាញជំហរពុំគាំទ្រឲ្យមានការចោទប្រកាន់បន្ថែមលើជនសង្ស័យក្នុងសំណុំរឿង០០៣ និង០០៤ ដោយបានផ្តល់នូវហេតុផលផ្សេងៗគ្នា ។ ដំណើរពុំយល់ស្របគ្នារវាងភាគីជាតិ និងភាគីអន្តរជាតិចំពោះការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង០០៤ ត្រូវបានអ្នកជំនាញអន្តរជាតិ និងអ្នកតាមដានដំណើរវិវឌ្ឍន៍នៃសាលាក្តីខ្មែរក្រហមមើលឃើញថា បណ្តាលមកពីការទទួលរងឥទ្ធិពលនយោបាយពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ដែលបានប្រឆាំងដាច់ខាតចំពោះការចោទប្រកាន់ជនសង្ស័យថ្មីបន្ថែមទៀត ។[៣]

មានសហចៅក្រមស៊ើបអង្កេតអន្តរជាតិចំនួន៣រូបហើយ ដែលបានសម្រេចចិត្តលាឈប់ជាបន្តបន្ទាប់ ក្រោយពីមានបញ្ហាចម្រូងចម្រាសពាក់ព័ន្ធនឹងការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង០០៤ ។[៤] អង្គការសហប្រជាជាតិបានចេញសេចក្តីថ្លែងការណ៍ជាបន្តបន្ទាប់ ដោយបង្ហាញអំពីការព្រួយបារម្ភយ៉ាងខ្លាំងរបស់ខ្លួនទាក់ទងនឹងដំណើរការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង០០៤ និងបានសម្រេចតែងតាំងចៅក្រមស៊ើបអង្កេតមួយរូបថ្មីទៀត គឺលោក ម៉ាក ហាមិន ដើម្បីបន្តកិច្ចការងារស៊ើបអង្កេត

ក្នុងសំណុំរឿង០០៣ និង០០៤ ។[៥]

ការវិវឌ្ឍចុងក្រោយមួយទៀត គឺការស្លាប់របស់ ស៊ូ មេ៉ត ដែលជាជនសង្ស័យមួយរូបក្នុងចំណោមជនសង្ស័យចំនួនពីររូប ក្នុងសំណុំរឿង០០៣ កាលពីខែមិថុនា ឆ្នាំ២០១៣ ។[៦] ជនសង្ស័យរូបនេះ ត្រូវបានរំពឹងថា អាចនឹងត្រូវបានចាប់ខ្លួនមកកាត់ទោសដោយសាលាក្តីខ្មែរក្រហម ។ ជនសង្ស័យ ស៊ូ មេ៉ត បានស្លាប់កាលថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ ដោយសារជំងឺ ។[៧] ស៊ូ មេ៉ត ធ្លាប់ធ្វើជាទីប្រឹក្សាក្រសួងការពារជាតិ មានឋានន្តរស័ក្តិជាឧត្តមសេនីយ៍ទោ ក្រោយពេលចូលសមាហរណកម្ម ចាប់តាំងពីខែសីហា ឆ្នាំ១៩៩៦ ដល់ឆ្នាំ១៩៩៩ ។ នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ស៊ូ មេ៉ត ធ្លាប់មានតួនាទីជាមេបញ្ជាការកងពល៥០២ និងជាមេបញ្ជាការកងទ័ពអាកាសរបស់ខ្មែរក្រហម ។[៨] ការស្លាប់នេះ ត្រូវបានមេធាវី ម៉ៃឃើល ការណាវ៉ាស ដែលជាអតីតមេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង សារី ក្នុងសំណុំរឿង០០២ និងត្រូវបានចាត់តាំងឲ្យធ្វើជាមេធាវីតំណាងឲ្យជនសង្ស័យមួយរូបផ្សេងទៀតក្នុងសំណុំរឿង០០៣ អះអាងថា ការស្លាប់របស់ ស៊ូ មេ៉ត នឹងពុំប៉ះពាល់ដល់កិច្ចដំណើរស៊ើបអង្កេតលើកូនក្តីរបស់ខ្លួនក្នុងសំណុំរឿង០០៣នេះឡើយ ។[៩] ទោះបីជាយ៉ាងណាក្តី ឋានៈជាមេធាវីតំណាងឲ្យជនសង្ស័យក្នុងសំណុំរឿង០០៣ របស់មេធាវី ម៉ៃឃើល ការណាវ៉ាស និងមេធាវី អាង ឧត្តម ត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក ហាមិន ។ ការបដិសេធនេះ គឺដោយសារមានការព្រួយបារម្ភអំពីបញ្ហាទំនាស់ផលប្រយោជន៍ទាក់ទងនឹងការការពារកូនក្តី ។[១០]

ចាប់ពីខែមករា រហូតដល់ខែមេសា ឆ្នាំ២០១៤ មានការវិវឌ្ឍថ្មីៗជាច្រើនក្នុងសំណុំរឿង០០៣ និង០០៤ ។ បើយោងតាមសេចក្តីប្រកាសជាច្រើនរបស់អង្គភាពគាំពារការពារក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនសង្ស័យទាំងអស់នៅក្នុងសំណុំរឿង០០៣ និង០០៤ មានមេធាវីតំណាងរៀងៗខ្លួនដែលចាត់តាំងដោយអង្គភាពនេះ ដើម្បីការពារជនសង្ស័យនៅចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទាក់ទងនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះបីជាយ៉ាងណា មេធាវីតំណាងឲ្យជនសង្ស័យទាំងអស់នោះនៅពុំទាន់ត្រូវបានអនុញ្ញាតឲ្យពិនិត្យមើលឯកសារដែលមាននៅក្នុងសំណុំរឿងនៅឡើយទេ ។

ការវិវឌ្ឍចុងក្រោយបង្អស់នៃសំណុំរឿងទាំងពីរនេះ គឺនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមក្នុងសំណុំរឿង០០៤ ដោយស្នើឲ្យមានកិច្ចស៊ើបសួរទៅលើអំពើហិង្សាផ្លូវភេទ ឬ យេនឌ័រ រួមទាំងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅតាមបណ្តាស្រុកសំខាន់ៗមួយចំនួនដែលបច្ចុប្បន្នកំពុងស្ថិតនៅក្រោមកិច្ចស៊ើបសួរនៃសំណុំរឿងនេះ ។[១១]

ខាងក្រោមនេះ នឹងមានការបង្ហាញពិស្តារអំពីប្រវត្តិនីតិវិធីនៃសំណុំរឿង០០៣ និង០០៤ ចាប់តាំងពីការចាប់ផ្តើមដំបូងរហូតដល់ដំណើរវិវឌ្ឍន៍ថ្មីៗចុងក្រោយបង្អស់នៃសំណុំរឿងទាំងពីរនេះ រួមទាំងឧបសគ្គជាច្រើនដែលបានធ្វើឲ្យរាំងស្ទះ និងបានអូសបន្លាយការស៊ើបអង្កេតអស់រយៈពេលជាច្រើនឆ្នាំ ។

## ប្រវត្តិនីតិវិធីនៃសំណុំរឿង០០៣ និង០០៤

នៅក្នុងឆ្នាំ២០០៨ អតីតសហព្រះរាជអាជ្ញាអន្តរជាតិ រ៉ូប៊ឺត ប៉ុទីត បានសម្រេចបើកការស៊ើបអង្កេតថ្មីចំនួន២ នៅក្នុងសំណុំរឿង០០៣ និង០០៤ បន្ទាប់ពីមានការចោទប្រកាន់ជនសង្ស័យចំនួន៥រូប ក្នុងសំណុំរឿង០០១ និង០០២ នៅខែកក្កដា ឆ្នាំ២០០៧ ។ ការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង ០០៤ ត្រូវបានធ្វើឡើងទោះបីជាមានការជំទាស់ពីសំណាក់សហព្រះរាជអាជ្ញាជាតិ លោកស្រី ជា លាង យ៉ាងណាក្តី ។ លោកស្រី ជា លាង បានបង្ហាញអំពីមូលហេតុដែលនាំឲ្យមានការជំទាស់ថា ដោយសារតែជនសង្ស័យទាំង៥រូបដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងសំណុំរឿង០០៣ និង០០៤ ពុំស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ព្រោះអ្នកទាំង៥រូបនោះពុំមែនជាមេដឹកនាំជាន់ខ្ពស់ ហើយក៏ពុំមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមដែរ ។[១២] ដោយសារតែពុំមានការព្រមព្រៀងគ្នារវាងសហព្រះរាជអាជ្ញាអន្តរជាតិ និងសហព្រះរាជអាជ្ញាជាតិ ដើម្បីបើកការស៊ើបអង្កេតលើសំណុំរឿងទាំងពីរនេះ សហព្រះ

រាជអាជ្ញាអន្តរជាតិ រ៉ូប៊ើត ប៉ីទីត បានដាក់ញត្តិមួយស្ដីពីកំណត់ហេតុនៃការខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះ ដើម្បីឲ្យអង្គបុរេជំនុំជម្រះដោះស្រាយបញ្ហានេះ ។ ប៉ុន្តែអង្គបុរេជំនុំជម្រះដែលមានចៅក្រម៥រូប (បីរូបជាចៅក្រមជាតិ និងពីររូបជាចៅក្រមអន្តរជាតិ) ពុំអាចចេញសេចក្ដីសម្រេចណាមួយបាន ដោយសារមិនអាចស្វែងរកសំឡេងឯកឆន្ទ ឬសំឡេងភាគច្រើនដាច់ខាត ដើម្បីចេញសេចក្ដីសម្រេចលើញត្តិរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ។[13] ដោយសារតែពុំមានសេចក្ដីសម្រេចដូច្នេះ យោងតាមវិធាន៧៨(១) នៃវិធានផ្ទៃក្នុង សំណុំរឿងនេះត្រូវបានសន្មតថា ត្រូវបន្តទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីបើកការស៊ើបអង្កេតតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ។

នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ព្រះរាជអាជ្ញាអន្តរជាតិស្ដីទីបានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើបសួរតាមផ្លូវតុលាការសម្រាប់សំណុំរឿង០០៣ និង០០៤ ។

ទោះបីជាយ៉ាងណាក្ដី ចាប់តាំងពីខែកញ្ញា ឆ្នាំ២០០៩ សំណុំរឿង០០៣ និង០០៤ បានត្រូវទុកចោលនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយពុំមានជនសង្ស័យណាម្នាក់ត្រូវបានកំណត់អត្តសញ្ញាណជាជ្ជវិការ ឬក៏ត្រូវបានចាប់ខ្លួនឡើយ ។ ឧបសគ្គចម្បងដែលត្រូវបានមើលឃើញ គឺដោយសារសហព្រះរាជអាជ្ញាជាតិ សហចៅក្រមស៊ើបអង្កេតជាតិ និងចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះទាំងអស់បានចេញសេចក្ដីសម្រេចស្របគ្នា រារាំង និងប្រឆាំងនឹងកិច្ចប្រឹងប្រែងរបស់សហភាគាអន្តរជាតិរបស់ខ្លួនដែលចង់ឲ្យកិច្ចដំណើរការនីតិវិធីនៃសំណុំរឿងទាំងពីរនេះបន្តទៅមុខ ។[14]



អៀង សារី កំពុងត្រួតពិនិត្យរោងចក្រក្រឡឹងមួយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

## **ការលាឈប់ពីតំណែងជាបន្តបន្ទាប់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

នៅក្នុងឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិទី២ គឺលោក ស៊ីកហ្វ្រេដ ប៊្លុង (*Siegfried* Blunk) ដែលចូលកាន់តំណែងជំនួសលោកចៅក្រម ម៉ាកសែល ឡឺម៉ុង (Marcel Lemond) ដែលបានលាឈប់ពីមុខតំណែងកាលពីថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ

២០១០ ទំនងជាបានយល់ស្របជាមួយសមភាគីជាតិរបស់ខ្លួន គឺចៅក្រម យូ ប៊ុនឡេង សម្រេចបិទបញ្ចប់កិច្ចដំណើរការស៊ើបអង្កេតសំណុំរឿង០០៣ និង០០៤ ដោយពុំមានការចោទប្រកាន់ជនសង្ស័យណាម្នាក់ឡើយ ។ ការសម្រេចរបស់ចៅក្រមស៊ើបអង្កេត ស៊ីកហ្វ្រេដ ប៊្លុង ក្នុងការបិទបញ្ចប់ការស៊ើបអង្កេតលើសំណុំរឿង០០៣ និង០០៤ បានទទួលរងការរិះគន់ពីសំណាក់អង្គការសិទ្ធិមនុស្សជាតិ និងអន្តរជាតិ ថា មិនបានធ្វើការដោយអញ្ញាក្រឹត្យក្នុងសំណុំរឿងទាំងពីរនេះឡើយ ។ បន្ទាប់ពីទទួលរងការរិះគន់យ៉ាងខ្លាំងពីសំណាក់អង្គការសិទ្ធិមនុស្ស រួមទាំងស្ថាប័នឯករាជ្យជាច្រើនរួចមក ចៅក្រម ស៊ីកហ្វ្រេដ ប៊្លុង បានសម្រេចលាឈប់ពីមុខតំណែងនៅ ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១១ ។[១៥]

នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង គឺលោក ឡូរ៉ង់ កាសប៉ឺ អានសឺម៉េត (*Laurent Kasper-Ansermet*) បានចូលកាន់តំណែងជំនួសចៅក្រម ប៊្លុង ដែលបានលាលែងពីមុខតំណែង ។[១៦] នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ គឺរយៈពេលបីថ្ងៃបន្ទាប់ពីចូលកាន់តំណែងចៅក្រម អានសឺម៉េត បានចេញដីកាមួយឲ្យបើកការស៊ើបអង្កេតលើសំណុំរឿង០០៣ និង០០៤ ឡើងវិញ បន្ទាប់ពីពិចារណាឃើញថា ការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ ដោយសហចៅក្រមស៊ើបអង្កេតទាំងពីររូប នៅពុំទាន់ធ្វើបានពេញលេញ ។[១៧] ទោះបីជាយ៉ាងណាក្តី សិទ្ធិអំណាចក្នុងការស៊ើបអង្កេតលើសំណុំរឿង០០៣ និង០០៤របស់ចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងអានសឺម៉េត ត្រូវ បានជំទាស់ជានិច្ចជាកាលដោយចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង ។[១៨] ការជំទាស់នេះត្រូវបាន ចៅក្រម យូ ប៊ុនឡេង ផ្តល់ហេតុផលថា ដោយសារតែចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងពុំទាន់ត្រូវ បានតែងតាំងជាផ្លូវការណាមួយ ដូចដែលមានចែងនៅក្នុងវិធាន៧(៤) នៃវិធានផ្ទៃក្នុង មាត្រា២៦ និងមាត្រា២៧ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងមាត្រា៣ និងមាត្រា៥ នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ។[១៩] នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១២ ចៅក្រម យូ ប៊ុនឡេង បានចេញបញ្ជាជាលាយលក្ខណ៍អក្សរមួយផ្ញើជូនចៅក្រម អានសឺម៉េត ដោយបង្គាប់ថា ចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង អានសឺម៉េត “ត្រូវតែបញ្ឈប់ជាបន្ទាន់នូវសកម្មភាពខុសច្បាប់របស់ខ្លួន” ។[២០] បន្ទាប់ពីមានការបដិសេធពុំទទួលស្គាល់ពីសំណាក់សហចៅក្រមស៊ើបអង្កេតជាតិ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា ចំពោះតួនាទីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង លោក ឡូរ៉ង់ កាសប៉ឺ អានសឺម៉េត បានចេញសេចក្តីថ្លែងការណ៍មួយ ដោយប្រកាសលាឈប់ពីមុខតំណែង និងបានអះអាងថា “ការជំទាស់យ៉ាងសកម្មដោយលោកចៅក្រម យូ ប៊ុនឡេង នៅក្នុងការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង០០៤ បាននាំទៅដល់ស្ថានការណ៍នៃភាពមិនអាចដំណើរការបាននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ [....] កាលៈទេសៈបច្ចុប្បន្ននេះ លែងអនុញ្ញាតឲ្យខ្ញុំបំពេញការងាររបស់ខ្ញុំដោយត្រឹមត្រូវ និងដោយសេរីទៀតហើយ” ។[២១] នៅក្នុងសេចក្តីថ្លែងការណ៍ដដែលនេះ ចៅក្រម អានសឺម៉េត បានបញ្ជាក់ថា ការលាលែងពីមុខតំណែងនេះមានអានុភាពគិតចាប់ពីថ្ងៃ៤ ខែឧសភា ឆ្នាំ២០១២ តទៅ ។

ក្រោយពីការប្រកាសលាឈប់ពីតំណែងរបស់ចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង អង្គការសហប្រជាជាតិបានចេញសេចក្តីថ្លែងការណ៍មួយ ដោយប្រកាសអំពីក្តីព្រួយបារម្ភយ៉ាងខ្លាំងរបស់ខ្លួន ចំពោះដំណើរការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង០០៤ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អង្គការសហប្រជាជាតិបានថ្លែងសង្កត់ធ្ងន់ថា កិច្ចស៊ើបអង្កេតក្នុងសំណុំរឿងទាំងពីរនេះត្រូវតែត្រឡប់មកក្នុងស្ថានភាពវិជ្ជមាន និងថា នីតិវិធីក្នុងការជ្រើសរើសសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មីកំពុងចាប់ផ្តើម ។[២២]

នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក ហាមិន (Mark B. Harmon) ត្រូវបានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា សម្រេចតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃសាលាក្តីខ្មែរក្រហម តាមសំណើរបស់អង្គការសហប្រជាជាតិដើម្បីបន្តកិច្ចការស៊ើបអង្កេតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅអំឡុងពេលនៃ

របបកម្ពុជាប្រជាធិបតេយ្យ ។[២៣]

**ការបង្ហាញព័ត៌មានស្តីពីទីតាំងឧក្រិដ្ឋកម្ម និងបទចោទប្រកាន់**

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក ហាមិន បានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈមួយ ដោយពុំមានការចូលរួមពីសំណាក់សហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង បង្ហាញអំពីទីតាំងឧក្រិដ្ឋកម្មបន្ថែមចំនួន១៤ ដែលស្ថិតនៅក្រោមការស៊ើបអង្កេតក្នុងសំណុំរឿង០០៤ និងបានអញ្ជើញសាក្សី និងជនរងគ្រោះ ដែលមានជាប់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មទាំងអស់នោះ ឲ្យមកទំនាក់ទំនងជាមួយនឹងសាលាក្តីខ្មែរក្រហម ។[២៤] សេចក្តីថ្លែងការណ៍នេះ បានបង្ហាញថា ការស៊ើបអង្កេតលើសំណុំរឿងនេះនៅតែបន្តដំណើរការ ហើយព័ត៌មានចាំបាច់មួយចំនួនត្រូវបានបង្ហាញជូនជនរងគ្រោះ ដែលមានបំណងចង់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ ។[២៥] ទីតាំងឧក្រិដ្ឋកម្មបន្ថែមទាំង១៤កន្លែងនោះមានដូចជា ៖

**ក) ខេត្តបាត់ដំបង**

- មន្ទីរសន្តិសុខធិបតី និងការដ្ឋានទួលម្រេស ៖ ស្ថិតនៅឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង
- ភ្នំត្រដាក់ចិត្ត និងអន្លង់វិលប្រែង ៖ ស្ថិតនៅភូមិឫស្សីព្រះ ឃុំឆ្នាល់មាន់ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង
- មន្ទីរសន្តិសុខតំបន់១ និងកន្លែងសម្លាប់ដំណាក់រាំង ៖ ស្ថិតនៅភូមិបាណន់ ឃុំកន្ទឺ ស្រុកបាណន់ ខេត្តបាត់ដំបង

**ខ) ខេត្តពោធិ៍សាត់**

- រណ្តៅទួលសេះញ៉ាវ និងវាលពិឃាតព្រៃក្រជៅ ៖ ស្ថិតនៅឃុំរំលេច និងឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់ (ការប្រព្រឹត្តលើខ្មែរក្រោម)
- គុកភូមិវាល ៖ ស្ថិតនៅឃុំតាឡូ ស្រុកបាកាន ខេត្តពោធិ៍សាត់ (ការប្រព្រឹត្តលើខ្មែរក្រោម)
- គុកស្វាយជ្រុំ ហៅគុកភូមិថ្កោល និងគុកបឹងបាតកណ្តាល ហៅត្រាក្រោល ៖ ស្ថិតនៅឃុំបឹង បាតកណ្តាល ស្រុកបាកាន ខេត្តពោធិ៍សាត់ (ការប្រព្រឹត្តលើខ្មែរក្រោម)
- ទីតាំងសម្លាប់វត្តច័ន្ទវង្សី រណ្តៅសាកសពរួម និងអណ្តូងសាកសពរួមនៅភូមិកូនត្នោត ឬ ភូមិចាម ៖ ស្ថិតនៅឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ (ការប្រព្រឹត្តលើប្រជាជនជម្លៀសពីភូមិភាគបូព៌ា)
- កន្លែងសម្លាប់វាលបាក់ចិញ្ចៀន ៖ ស្ថិតនៅឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ (ការប្រព្រឹត្តទៅលើប្រជាជនជម្លៀសពីភូមិភាគបូព៌ា)

**គ) ខេត្តតាកែវ**

- កន្លែងសម្លាប់ព្រៃសុខុន និងមន្ទីរឃុំឃាំងវត្តអង្គសិរីមុនី ៖ ស្ថិតនៅភូមិស៊ីស្វា ឃុំធ្លាប្រជុំ ស្រុកកោះអណ្តែត ខេត្តតាកែវ (ការប្រព្រឹត្តទៅលើខ្មែរក្រោម)
- ព្រៃភូមិស្វែង វត្តអង្គញ កន្លែងសម្លាប់ភូមិព្រាល និងភូមិសោម និងគុកវត្តសុបិនៈ ស្ថិតនៅឃុំគោព្រេច និងឃុំកំពែង ស្រុកគិរីវង្ស ខេត្តតាកែវ (ការប្រព្រឹត្តទៅលើខ្មែរក្រោម)
- មន្ទីរសន្តិសុខវត្តប្រធាតុ ៖ ស្ថិតនៅក្នុងឃុំគោកព្រេច ស្រុកគិរីវង្ស ខេត្តតាកែវ (ការប្រព្រឹត្តលើខ្មែរក្រោម)
- មន្ទីរសន្តិសុខក្រាំងតាចាន់ ៖ ស្ថិតនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ (ការប្រព្រឹត្តលើខ្មែរក្រោម និងជនដទៃទៀត)

**ឃ) ខេត្តកំពង់ធំ**

- គុកសម័យអាណានិគម ៖ ស្ថិតនៅទីរួមខេត្តកំពង់ធំ (ការបោសសម្អាតភូមិភាគកណ្តាល)

**ង) ខេត្តកំពង់ចាម**

- កន្លែងសម្លាប់ថ្មល់បែក ៖ ស្ថិតនៅឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម (ទាក់ទងនឹងមន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក)[២៦]

បន្ទាប់មក នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក ហាមិន និងសហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង បានចេញសេចក្តីប្រកាសពីរដាច់ពីគ្នាទាក់ទងនឹងសំណុំរឿង០០៣ ។[២៧] នៅក្នុងសេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង បានលើកឡើងថា ដីកាដែលលោក (យូ ប៊ុនឡេង) និងអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស៊ីកហ្វ្រេដ ប្លុង បានចេញរួមគ្នាដើម្បីការបិទបញ្ចប់ការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ ដោយពុំមានការចោទប្រកាន់ នៅតែ

បន្តមានសុពលភាពដដែល ។[២៨] ប៉ុន្តែ សម្រាប់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក ហាមិន យល់ថា សំណុំរឿង០០៣ នៅពុំទាន់បិទបញ្ចប់នៅឡើយទេ ហើយកិច្ចដំណើរការស៊ើបអង្កេតនៅតែអាចបន្តធ្វើបាន ។[២៩] ចៅក្រម ហាមិន ថែមទាំងបានប្រើប្រាស់សេចក្តីប្រកាសនេះ ដើម្បីជាការជូនដំណឹងដល់ជនរងគ្រោះ និងសាធារណជនទូទៅអំពីព័ត៌មាននៃសំណុំរឿង០០៣ ដោយបង្ហាញអំពីឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងទីតាំងឧក្រិដ្ឋកម្មដែលស្ថិតនៅ ក្រោមការស៊ើបអង្កេត ។ បន្ថែមពីលើនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហាមិន បានអំពាវនាវឲ្យជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងនោះ និងអ្នកដែលធ្លាប់បានដឹងឮអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅទីតាំងឧក្រិដ្ឋកម្មទាំងនោះអាចចូលរួមក្នុងសំណុំរឿង០០៣ ក្នុងនាមជាសាក្សី ជាដើមបណ្តឹងរដ្ឋប្បវេណី ឬជាអ្នកដាក់ពាក្យបណ្តឹង ។[៣០] បទចោទប្រកាន់ និងទីតាំងឧក្រិដ្ឋកម្មនៃសំណុំរឿង០០៣ ដែលត្រូវបានបង្ហាញនៅក្នុងសេចក្តីប្រកាសដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិមានដូចខាងក្រោម ៖

«នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ សម្រាប់សំណុំរឿង០០៣ សហព្រះរាជអាជ្ញាបានចោទថា សមាជិកកងទ័ពបដិវត្តន៍កម្ពុជា កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ និងកងទ័ពអាកាសកម្ពុជាប្រជាធិបតេយ្យ បានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញានៃទីក្រុងហ្សឺណែវ អំពើមនុស្សឃាត និងអំពើទារុណកម្មនៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ នៅចន្លោះពីខែមេសា ឆ្នាំ១៩៧៥ ទៅខែមករា ឆ្នាំ១៩៧៩ ។

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ សហព្រះរាជអាជ្ញាធ្វើការបញ្ជាក់ដូចតទៅ ៖ កងទ័ពបដិវត្តន៍កម្ពុជា កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ និងកងទ័ពអាកាសកម្ពុជាប្រជាធិបតេយ្យបានបោសសម្អាតកងពលយោធា ។ មនុស្សដែលត្រូវបានបោស សម្អាតត្រូវបានចាប់ខ្លួនតាមអំពើចិត្ត ដាក់ឃុំឃាំងដោយខុសច្បាប់ ធ្វើទារុណកម្ម ធ្វើមនុស្ស ឃាត និងទទួលរងពលកម្មដោយបង្ខំ ។ កម្មករ អ្នកនេសាទ និងប្រជាជនដែលត្រូវបានសម្គាល់ថាជា “ជនក្បត់” ជនបរទេស (លោក



អ្នកភូមិធ្វើពិធីបង្សុកូលដើម្បីគោរពវិញ្ញាណក្ខន្ធដល់អ្នកដែលបានស្លាប់ក្នុងរបបខ្មែរក្រហម បន្ទាប់ពីគាស់ផ្នូរពីរណ្តៅរួចមក ។
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខាងលិច ថៃ និងវៀតណាម) ដែលត្រូវបានចាប់ខ្លួននៅក្នុងដែនទឹករបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬត្រូវបានចាប់ពង្រត់ពីតំបន់ព្រំដែន គឺជាជនរងគ្រោះនៃបទឧក្រិដ្ឋទាំងនោះ ហើយបទឧក្រិដ្ឋទាំងនោះត្រូវបានប្រព្រឹត្តឡើងដោយកម្មាភិបាលនៃកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ និងកងទ័ពកម្ពុជា ប្រជាធិបតេយ្យក្នុងអំឡុងពេលវាយលុកចូលប្រទេសវៀតណាមនៅចុងឆ្នាំ១៩៧៧ និងឆ្នាំ ១៩៧៨ ។»

បន្ថែមពីលើឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅតំបន់ឆ្នេរប្រទេសកម្ពុជា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាសម្រាប់សំណុំរឿង០០៣ បានបង្ហាញទីតាំងជាក់លាក់មួយចំនួនដែលឧក្រិដ្ឋកម្មទាំងនោះបានកើតឡើង ។ ទីតាំងឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង០០៣ មានដូចជា ៖

- មន្ទីរសន្តិសុខ ស-២១ ៖ ស្ថិតនៅភ្នំពេញ
- ទីតាំងសម្លាប់ស្ទឹងតូច ៖ ស្ថិតនៅស្រុកពញាក្រែក ខេត្តកំពង់ចាម
- ការដ្ឋានសាងសង់ព្រលានយន្តហោះ ៖ ស្ថិតនៅឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង
- មន្ទីរសន្តិសុខកងពល៨០១ ៖ ស្ថិតនៅស្រុកវើនសៃ ខេត្តរតនគិរី
- ការដ្ឋានវាយថ្មស្ទឹងហាវ ៖ ស្ថិតនៅខេត្តកំពង់សោម
- មន្ទីរសន្តិសុខ និងទីតាំងសម្លាប់វត្តឥន្ទញាណ ៖ ស្ថិតនៅខេត្តកំពង់សោម
- មន្ទីរសន្តិសុខ ស-២២ ៖ ស្ថិតនៅខណ្ឌមានជ័យ រាជធានីភ្នំពេញ
- ចម្ការធូរេន ៖ ស្ថិតនៅភូមិរាម សង្កាត់រាម ខណ្ឌព្រៃនប់ ខេត្តព្រះសីហនុ
- ការដ្ឋានបិតត្រាំង ៖ ស្ថិតនៅសង្កាត់បិតត្រាំង ខណ្ឌព្រៃនប់ ខេត្តព្រះសីហនុ

## ការទទួលស្គាល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ទោះបីជាមានការជំទាស់ពីសំណាក់សហចៅក្រមស៊ើបអង្កេតជាតិ លើការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង០០៤ ដំណើរវិវឌ្ឍន៍នៃសំណុំរឿងទាំងពីរត្រូវបានមើលឃើញថា កំពុងមានការវិវឌ្ឍ ជឿនលឿនទៅមុខ ។

ជាក់ស្តែង នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ គឺ២ថ្ងៃនៅមុនពេលចេញសេចក្តីប្រកាសទាក់ទងនឹងសំណុំរឿង០០៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក ហាមិន បានចេញសេចក្តីសម្រេចមួយផ្តល់នីតិសម្បទាទទួលស្គាល់ និងអនុញ្ញាតឲ្យចូលមើលឯកសារក្នុងសំណុំរឿងដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៤រូប ដែលតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៣ ។[៣១] បន្ទាប់មក នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៣ ចៅក្រម ម៉ាក ហាមិន បានចេញសេចក្តីសម្រេចមួយទៀតស្រដៀងគ្នានឹងសេចក្តីសម្រេចចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ដោយបានផ្តល់នីតិសម្បទាទទួលស្គាល់ និងអនុញ្ញាតឲ្យចូលមើលឯកសារក្នុងសំណុំរឿងដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួន២០រូបទៀត ដែលមានបំណងតំណាងឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង០០៤ ។[៣២] សេចក្តីសម្រេចនេះ ស្របគ្នាជាមួយនឹងទស្សនៈរបស់ចៅក្រមអន្តរជាតិទាំងពីររូបនៃអង្គបុរេជំនុំជម្រះ ដែលបានលើកឡើងថា វិធានផ្ទៃក្នុងបានផ្តល់លទ្ធភាពឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិពិនិត្យសំណុំរឿងតាមរយៈមេធាវីតំណាងរបស់ខ្លួន គិតចាប់ពីពេលដាក់ពាក្យសុំរហូតដល់ពេលសេចក្តីសម្រេចបដិសេធចោលពាក្យសុំនេះ ចូលជាស្ថាពរ ។[៣៣]

## ការចាត់តាំងមេធាវីតំណាងជនសង្ស័យ

ដូចគ្នានឹងជនរងគ្រោះដែរ ជនសង្ស័យទាំង៥រូប ដែលមានឈ្មោះក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ នៅក្នុងសំណុំរឿង០០៣ និង០០៤ ត្រូវបានជូនដំណឹងអំពីការចោទប្រកាន់ និងសិទ្ធិក្នុងការមានមេធាវីការពារក្តី ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ។[៣៤] នៅពេលដំបូង អ្វីដែលត្រូវបានដឹងជាសាធារណៈ គឺមានតែជនសង្ស័យមួយរូបនៅក្នុងសំណុំរឿង០០៣ និងជនសង្ស័យមួយរូបនៅក្នុងសំណុំរឿង០០៤ ដែលបានអនុវត្តសិទ្ធិក្នុងការមានមេធាវីការពារនេះ ។[៣៥]

ក្នុងសំណុំរឿង០០៤ ជនសង្ស័យបានជ្រើសរើសអតីតប្រធានអង្គភាពគាំពារក្តី លោក រីឆាត រ៉ូជឺ (Richard Rogers)

ធ្វើជាមេធាវីការពារក្តីអន្តរជាតិរបស់ខ្លួន និងលោក មុំ លុជ្ស ធ្វើជាមេធាវីជាតិ ។ ប៉ុន្តែ ដោយសារមានការជំទាស់ពីសំណាក់អង្គភាពគាំពារការការពារក្តីចំពោះការជ្រើសរើសលោក រីឆាត រ៉ូជឺ ជនសង្ស័យបានជ្រើសរើសយកលោក ហ្គោរ៉េន ស្លូតធឺ (Goran Sluiter) ជាមេធាវីអន្តរជាតិមួយរូបទៀតរបស់ខ្លួន ។ នៅក្នុងខែតុលា ឆ្នាំ២០១២ លោក ស្លូតធឺ ត្រូវបានតែងតាំងជាមេធាវីការពារក្តីជាផ្លូវការ ។ ចំណែកឯជនសង្ស័យមួយរូបក្នុងសំណុំរឿង ០០៣ បានជ្រើសរើសយកមេធាវី ម៉ៃឃើល ការណាវ៉ាស និងមេធាវី អាង ឧត្តម ដើម្បីការពារក្តីឲ្យខ្លួននៅចំពោះមុខការចោទប្រកាន់របស់តុលាការ ។ មេធាវីទាំងពីររូបត្រូវបានតែងតាំងជាផ្លូវការ ដោយអង្គភាពគាំពារការការពារក្តីនៅខែធ្នូ ឆ្នាំ២០១២ នៅខណៈពេលដែលមេធាវីទាំងពីររូបនេះកំពុងបំពេញភារកិច្ចការពារក្តីឲ្យជនជាប់ចោទ អៀង សារី ក្នុងសំណុំ រឿង០០២ ។[៣៦] ប៉ុន្តែនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ម៉ាក ហាមិន បានចេញសេចក្តីសម្រេចមួយបដិសេធចំពោះការតែងតាំងមេធាវីទាំងពីររូប ដោយលើកឡើងថា កិច្ចការរបស់មេធាវីទាំងពីររូបក្នុងការការពារក្តីឲ្យជនជាប់ចោទ អៀង សារី និងការធ្វើជាមេធាវីតំណាងឲ្យជនសង្ស័យក្នុងសំណុំរឿង ០០៣ អាចនឹងបង្កឲ្យមានបញ្ហាជម្លោះផលប្រយោជន៍ ទោះបីជា អៀង សារី បានស្លាប់ហើយក៏ដោយ ។ ចៅក្រម ហាមិន បានបញ្ជាក់នៅក្នុងសេចក្តីសម្រេចនោះថា មេធាវី ការណាវ៉ាស និងមេធាវី អាង ឧត្តម ពុំមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីធ្វើជាអ្នកតំណាងឲ្យជនសង្ស័យក្នុងសំណុំរឿង០០៣ទេ និងបានបញ្ជាឲ្យតុលាការតែងតាំងមេធាវីការពារក្តីថ្មីជំនួសកន្លែងរបស់មេធាវីទាំងពីររូប ។[៣៧] រហូតមកដល់ពេលនេះ ពុំទាន់ឃើញមានការតែងតាំងមេធាវីថ្មីជំនួសឲ្យមេធាវី ការណាវ៉ាស និងមេធាវី អាង ឧត្តម នៅឡើយទេ ។

រហូតដល់ខែមករា ឆ្នាំ២០១៤ ទើបឃើញមានការតែងតាំងមេធាវីតំណាងឲ្យជនសង្ស័យពីររូបផ្សេងទៀតដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ ក្នុងសំណុំរឿង០០៤ ។ នៅក្នុងសេចក្តីប្រកាសចុះថ្ងៃទី២ ខែមករា ឆ្នាំ ២០១៤ អង្គភាពគាំពារការការពារក្តីនៃសាលាក្តីខ្មែរក្រហមបានសម្រេចចាត់តាំង លោក ប៊ិត ស៊ាងលីម និងលោក សូ មូស្សេទ្ធី ធ្វើជាសហមេធាវីជាតិតំណាងឲ្យជនសង្ស័យពីររូបផ្សេងគ្នានៅក្នុងសំណុំរឿង០០៤ ។[៣៨] បន្ទាប់មក នៅក្នុងសេចក្តីប្រកាសចុះនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ អង្គភាពគាំពារការការពារក្តីបានចាត់តាំងមេធាវីអន្តរជាតិមួយរូបផ្សេងទៀត គឺលោកស្រី ស៊ូហ្សាណា តូមាណូវិច (Suzana Tomanovic) ធ្វើជាសហមេធាវីអន្តរជាតិតំណាងឲ្យជនសង្ស័យក្នុងសំណុំរឿង០០៤ ដែលនឹងត្រូវធ្វើការងាររួមគ្នាជាមួយលោក សូ មូស្សេទ្ធី ។[៣៩] បន្ទាប់ពីលោកស្រីមេធាវី ស៊ូហ្សាណា តូមាណូវិច មេធាវីអន្តរជាតិមួយរូបទៀតត្រូវបានចាត់តាំងឲ្យតំណាងឲ្យជនសង្ស័យក្នុងសំណុំរឿង០០៤ ។ នៅក្នុងសេចក្តីប្រកាសចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៤ អង្គភាពគាំពារការការពារក្តីបានចាត់តាំងលោក ចន ចូន (John R.W.D. Jones) សញ្ជាតិអង់គ្លេសធ្វើជាសហមេធាវីអន្តរជាតិតំណាងឲ្យជនសង្ស័យក្នុងសំណុំរឿង០០៤ ដោយត្រូវធ្វើកិច្ចការរួមគ្នាជាមួយនឹងលោក ប៊ិត ស៊ាងលីម ។[៤០] ដូច្នេះ បើយោងតាមសេចក្តីប្រកាសទាំងអស់នេះ ជនសង្ស័យទាំងអស់នៅក្នុងសំណុំរឿង០០៣ និង ០០៤ ទំនងជាមានមេធាវីតំណាងរៀងៗខ្លួន ដើម្បីការពារខ្លួននៅចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទាក់ទងនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

នៅមុនពេលមានការចាត់តាំងមេធាវីតំណាងឲ្យជនសង្ស័យទាំង៥រូប ដែលមានឈ្មោះនៅក្នុងសំណុំរឿង០០៣ និង០០៤ អ្នកឃ្លាំមើលដំណើរការវិវឌ្ឍន៍នៃសាលាក្តីខ្មែរក្រហម ព្រមទាំងចៅក្រមនៃអង្គបុរេជំនុំជម្រះ ធ្លាប់បានបង្ហាញអំពីក្តីព្រួយបារម្ភថា សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនសង្ស័យក្នុងសំណុំរឿង០០៣ និង០០៤ អាចនឹងត្រូវបានរំលោភបំពាននៅពេលដែលជនសង្ស័យទាំងនោះស្ថិតនៅក្រោមការស៊ើបអង្កេតចាប់តាំងពីឆ្នាំ២០០៩ ដោយពុំមានមេធាវីតំណាង ។[៤១]

## មេធាវីតំណាងជនសង្ស័យពុំទាន់ត្រូវបានអនុញ្ញាតឲ្យចូលមើលឯកសារក្នុងសំណុំរឿង

បច្ចុប្បន្ននេះ ទោះបីជាជនសង្ស័យទាំងអស់នៅក្នុងសំណុំរឿង០០៣ និង០០៤ ទទួលបានមេធាវីតំណាងហើយក៏ដោយ ក៏មេធាវីតំណាងឲ្យជនសង្ស័យទាំងអស់នោះនៅពុំទាន់ទទួលបាន

ការអនុញ្ញាតឲ្យចូលពិនិត្យមើលឯកសារនៅក្នុងសំណុំរឿងនៅឡើយទេ ។ អង្គភាពគាំពារការពារក្តី និងស្ថាប័នការពារសិទ្ធិមនុស្សមួយចំនួនបានលើកឡើងថា ការរារាំងមិនអនុញ្ញាតឲ្យមេធាវីតំណាងជនសង្ស័យចូលពិនិត្យមើលឯកសារក្នុងសំណុំរឿងបង្ហាញពីការខកខានក្នុងការផ្តល់ការការពារសិទ្ធិជូនជនសង្ស័យឲ្យបានគ្រប់គ្រាន់ ។ ក្រុមមេធាវីការពារក្តីមិនអាចផ្តល់កិច្ចការពារដល់កូនក្តីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពបានទេ ប្រសិនបើពួកគេមិនត្រូវបានអនុញ្ញាតឲ្យចូលមើលឯកសារក្នុងសំណុំរឿង ឬមិនអាចចូលរួមក្នុងកិច្ចដំណើរការស៊ើប អង្កេតបាននោះ ។[៤២]

គោលការណ៍ផ្តល់សិទ្ធិឲ្យមេធាវីការពារក្តីអាចចូលពិនិត្យមើលឯកសារក្នុងសំណុំរឿង គឺធ្វើឡើងក្នុងគោលបំណងដើម្បីធានាថា សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទត្រូវបានការពារ និងលើកស្ទួយប្រសិទ្ធភាពនៃការស៊ើបអង្កេត និងដំណើរការក្តី និងដើម្បីអនុញ្ញាតឲ្យមេធាវីតំណាងអាចធ្វើសំណើដើម្បីធ្វើការស៊ើបអង្កេត ។[៤៣]

## សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យមានការស៊ើបអង្កេតបន្ថែមលើសំណុំរឿង០០៤

ការវិវឌ្ឍចុងក្រោយបង្អស់នៃសំណុំរឿង០០៤ គឺការស្នើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីឲ្យមានកិច្ចស៊ើបសួរបន្ថែមទាក់ទងនឹងអំពើហិង្សាផ្លូវភេទ រួមទាំងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅតាមបណ្តាលស្រុកសំខាន់ៗមួយចំនួនដែលបច្ចុប្បន្នកំពុងស្ថិតនៅក្រោមកិច្ចស៊ើបសួរ ដែលជាផ្នែកនៃសំណុំរឿងនេះ ។[៤៤] នៅក្នុងសេចក្តីប្រកាសមួយចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញា អន្តរជាតិ និកូឡាស គូមជេន (Nicholas Koumjian) បានបញ្ជាក់ថា អាពាហ៍ពិពាហ៍ដោយបង្ខំ អំពើរំលោភសេពសន្ថវៈ និងអំពើហិង្សាខាងផ្លូវភេទ ដូចបានចោទប្រកាន់ ត្រូវបានប្រព្រឹត្តិឡើងដោយកម្មាភិបាលខ្មែរក្រហម និងបានកើតឡើងនៅក្នុងតំបន់នានាដែលជនសង្ស័យក្នុងសំណុំរឿង ០០៤ គឺជាអ្នកកាន់មុខនាទីជាអ្នកបញ្ជា ឬនយោបាយដ៏មានឥទ្ធិពល ។[៤៥] សហព្រះរាជអាជ្ញាអន្តរជាតិបានបន្ថែមទៀតថា បន្ទាប់ពីវិភាគដោយយកចិត្តទុកដាក់លើព័ត៌មាននៅក្នុងអំឡុងពេលប៉ុន្មានខែកន្លងមក សហព្រះរាជអាជ្ញាជឿជាក់ថា ការចោទប្រកាន់លើអង្គហេតុទាំងឡាយដែលមាននៅក្នុងភស្តុតាងថ្មី គឺអាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលរួមមាន ៖ ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការធ្វើឲ្យទៅជា ទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ។ អំពើទាំងនេះក៏បង្កើតបានជា អំពើមនុស្សឃាត និងអំពើទារុណកម្ម ដែលជាការរំលោភទៅលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។[៤៦]

## សន្និដ្ឋាន

ទោះបីជាការវិវឌ្ឍចុងក្រោយនេះ បានបង្ហាញថា សំណុំរឿង០០៣ និង០០៤ កំពុងដំណើរការទៅមុខប្រកបដោយភាពវិជ្ជមានក៏ដោយ សាធារណជនទូទៅហាក់បីដូចជានៅពុំទាន់ទទួលបានព័ត៌មានទូលំទូលាយអំពីកិច្ចដំណើរការស៊ើបអង្កេតលើសំណុំរឿងទាំងពីរនេះនៅឡើយ ។ បន្ថែមពីលើនេះ អត្តសញ្ញាណរបស់ជនសង្ស័យនៅតែបន្តស្ថិតនៅក្នុងភាពសម្ងាត់ ពុំទាន់ត្រូវបានប្រកាសជាផ្លូវការ ទោះបីជាការស៊ើបអង្កេតបានចាប់ផ្តើមតាំងពីឆ្នាំ២០០៩យ៉ាងណាក្តី ។ ការមិនអនុញ្ញាតឲ្យមេធាវីតំណាងជនសង្ស័យចូលពិនិត្យមើលឯកសារក្នុងសំណុំរឿង និងការបដិសេធមិនទទួលស្គាល់មេធាវីតំណាងជនសង្ស័យ ក៏ជាឧបសគ្គរារាំងជនសង្ស័យពីការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ។ ប្រជាជនកម្ពុជា ជាពិសេស ជនរងគ្រោះដោយសាររបបខ្មែរក្រហមគប្បីសមនឹងទទួលបានព័ត៌មានទូលំទូលាយអំពីការវិវឌ្ឍនៃសំណុំរឿង០០៣ និង០០៤ ច្រើនជាងនេះ ដើម្បីធ្វើឲ្យប្រាកដថា ការចូលរួមរបស់ជនរងគ្រោះនឹងធ្វើឡើងប្រកបដោយអត្ថន័យ ។

## កំណត់សម្គាល់

១ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ឡូរ៉ង់ កាសប៉ឺ អានសឺម៉េត (Laurent Kasper-Ansermet) *"Decision on Personal Jurisdiction and Investigative Policy Regarding Suspect"* ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២, កថាខណ្ឌទី១០ និង២៨ ។

២ របាយការណ៍របស់ Open Society Justice Initiative ដែលមានចំណងជើងថា *"The Future of Cases 003/004 at the Extra0dinary Chambers in the Courts of Cambodia"* ដែលចេញផ្សាយខែតុលា

ឆ្នាំ២០១២ ទំព័រទី២ [បន្ទាប់ពីនេះនឹងហៅថា OSJI : The Future of Case 003/004] ។ របាយការណ៍នេះ អាចរកអានបានតាមរយៈគេហទំព័រ http://www.opensocietyfoundations.org/sites/default/files/eccc-report-cases3and4-100112_0.pdf ។ សូមមើលបន្ថែម សុខ ខេមរា, "ភាពចម្រូងចម្រាសរវាងសហព្រះរាជអាជ្ញាចំពោះការស៊ើបអង្កេតសំណុំរឿង០០៣", វិទ្យុសំឡេងសហរដ្ឋអាមេរិក, ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១១ ។

២ http://khmer.voanews.com/content/in-turbulent-week-for-tribunal-rising-concerns—-analysis-121806374/1142961.html

៣ Seth Mydans, *"Efforts to Limit Khmer Rouge Trials Decried"*, កាសែតញូវយ៉កថែមស៍ ចុះផ្សាយថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៩ ។ សូមមើលផងដែរ Ek Madra, *"Cambodian PM Rejects Wider Khmer Rouge Trials"* កាសែត រ៉យទ័រស៍ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ។ សូមមើលបន្ថែម Anne Heindel, *"Decision on Case 004 Suspect's Right to Counsel"* គម្រោងឃ្លាំមើលសាលាក្តីខ្មែរក្រហម, ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៣ ។ អត្ថបទនេះអាចរកអានបានតាមរយៈគេហទំព័រ http://www. cambodiatribunal.org/wp-content/uploads/2013/08/commentary_130604-english.pdf

៤ ចៅក្រមស៊ើបអង្កេតអន្តរជាតិទាំងបីរូប ដែលបានសុំលាឈប់ពីមុខតំណែងនោះ រួមមាន ចៅក្រម ម៉ាកសែល ឡឺម៉ុង (Marcel Lemond) ចៅក្រម ស៊ីកហ្វ្រេដ ប៊្លុង (Siegfried Blunk) និងចុងក្រោយ ចៅក្រម ឡូរ៉ង់ កាសប៉ឺ អានសឺម៉េត (Laurent Kasper-Ansermet) ។

៥ OSJI : The Future of Case 003/004, ទំព័រ១១ ។

៦ *LAUREN CROTHERS* និង *PHORN BOPHA*, កាសែត ឌឹ ខេមបូឌា ដេលី, *"Khmer Rouge War Crimes Suspect Sou Met Dead"* ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ ។ អត្ថបទនេះអាចរកអានបានតាមរយៈគេហទំព័រ http://www.cambodiadaily.com/archives/khmer-rouge-war-crimes-suspect-sou-met-dead-32184/ ។ សូមមើលផងដែរ សុខ ខេមរា, "ជនសង្ស័យម្នាក់នៃសំណុំរឿងកាត់ទោសខ្មែរក្រហម បានស្លាប់មុនពេលកាត់ទោស", វិទ្យុសំឡេងសហរដ្ឋអាមេរិក, ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ ។ អត្ថបទនេះអាចរកអានបានតាមរយៈគេហទំព័រ http://khmer.voanews.com/content/khmer-rouge-suspect-in-case-003-died/1689896.html

៧ សុខ ខេមរា, "ជនសង្ស័យម្នាក់នៃសំណុំរឿងកាត់ទោសខ្មែរក្រហមបានស្លាប់មុនពេលកាត់ទោស", វិទ្យុសំឡេងសហរដ្ឋអាមេរិក, ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ ។ អត្ថបទនេះអាចរកអានបានតាមរយៈគេហទំព័រ http://khmer.voanews.com/content/khmer-rouge-suspect-in-case-003-died/1689896.html

៨ ដដែល ដូចខាងលើ ។

៩ *LAUREN CROTHERS* និង *PHORN BOPHA*, កាសែត ឌឹ ខេមបូឌា ដេលី, *"Khmer Rouge War Crimes Suspect Sou Met Dead"* ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ ។ អត្ថបទនេះអាចរកអានបានតាមរយៈគេហទំព័រ http://www.cambodiadaily.com/archives/khmer-rouge-war-crimes-suspect-sou-met-dead-32184/

១០ Julia Wallace, កាសែត ឌឹ ខេមបូឌា ដេលី, *"Judge Removes Case 003*



ខៀវ សំផន (ស្តាំ) នាំគណៈប្រតិភូនៃប្រទេសភូមា ដឹកនាំដេ
ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧ ។ (បណ្ណ

*Suspect's Lawyers"* ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ។ អត្ថបទនេះអាចរកអានបានតាមរយៈគេហទំព័រ http://www.cambodiadaily.com/archives/judge-removes-case-003-suspects-lawyers-51056/

១១ សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីសំណុំរឿង០០៤ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ។ សេចក្តីថ្លែងការណ៍នេះអាចរកមើលបានតាមរយៈអាស័យដ្ឋានគេហទំព័រ http://www.eccc.gov.kh/articles/30193

១២ សេចក្តីប្រកាសដោយសហព្រះរាជអាជ្ញាជាតិទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១ ។ សេចក្តីប្រកាសនេះ អាចរកអានបានតាមរយៈគេហទំព័រ http://www.eccc.gov.kh/sites/default/files/media/5-Press%20release%20by%20the%20National% 20Prosecutor-10%20May%202011-Eng.pdf

១៣ "*Decision on Personal Jurisdiction and Investigative Policy Regarding Suspect*" ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២, កថាខណ្ឌទី៣ ។

១៤ Anne Heindel, *"Decision on Case 004 Suspect's Right to Counsel"* ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៣ ។ អត្ថបទនេះអាច រកអានបានតាមរយៈ គេហទំព័រ http://www.cambodiatribunal.org/wp-content/uploads/2013/08/commentary_130604-english.pdf



...ាយប្រធានាធិបតី ណេវិន (អាវដ្ធ) ទស្សនាខេត្តសៀមរាប ...សារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

១៥ គីម ម៉ារីយ៉ាន, ទស្សនាវដ្តីស្វែងរកការពិត, លេខ១៤៣, ខែវិច្ឆិកា ឆ្នាំ២០១១ ទំព័រ៣២ ។

១៦ សេចក្តីប្រកាសព័ត៌មានដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ។

១៧ "*Decision on Personal Jurisdiction and Investigative Policy Regarding Suspect*" ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២, កថាខណ្ឌទី៥ ។

១៨ សេចក្តីប្រកាសព័ត៌មានដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ។ សេចក្តីប្រកាសនេះ អាចរកអានបានតាមរយៈគេហទំព័រ http://www.eccc.gov.kh/articles/17285

១៩ សេចក្តីប្រកាសព័ត៌មានដោយសហចៅក្រមស៊ើបអង្កេតជាតិ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ។ http://www.eccc.gov.kh/articles/17495

២០ សេចក្តីប្រកាសព័ត៌មានដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ។ សេចក្តីប្រកាសនេះ អាចរកអានបានតាមរយៈគេហទំព័រ http://www.eccc.gov.kh/articles/17285

២១ ដដែល ដូចខាងលើ ។

២២ សេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យអគ្គលេខាធិការនៃអង្គការសហប្រជាជាតិស្តីអំពី អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ផ្ញើនៅទីក្រុងញ៉ូវយ៉ក, ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១២ ។ សេចក្តីថ្លែងការណ៍នេះ អាចរកអានបានតាមរយៈគេហទំព័រ http://www.un.org/sg/statements/index.asp?nid=5961 ។ សូមមើលផងដែរ UN News Centre, *"UN Voices Concern as Second Judge Resigns from Cambodia Genocide Court"* http://www.un.org/apps/news/story.asp?NewsID=41578&Cr=Cambodia&Cr1. *"UN concerned over Khmer Rouge tribunal row,"* ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២, *World Radio*, អាចរកអានបានតាមរយៈគេហទំព័រ http://worldradio.ch/wrs/news/wrsnews/un-concerned-over-khmer-rouge-tribunal-row.shtml?29786

២៣ «ការរៀបចំដំណើរមកដល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ», ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ ។ សេចក្តីប្រកាសព័ត៌មាននេះ អាចរកអានបានតាមរយៈគេហទំព័រ http://www.eccc.gov.kh/articles/21715

២៤ សេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងសំណុំរឿង០០៤ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ ។ http://www.eccc.gov.kh/articles/25280

២៥ របាយការណ៍របស់ Open Society Justice Initiative ដែលមានចំណងជើងថា *"Recent Development at the Extra0dinary Chambers in the Courts of Cambodia"* ដែលចេញផ្សាយខែមីនា ឆ្នាំ២០១៣ ទំព័រទី១២ និង១៣ [បន្ទាប់ពីនេះនឹងហៅថា OSJI : Recent

Development at the ECCC] ។ របាយការណ៍នេះ អាចរកអានបានតាមរយៈគេហទំព័រ http://www.opensocietyfoundations.org/sites/default/files/eccc-report-20130322_0.pdf

២៦ សេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មបន្ថែមក្នុងសំណុំរឿង០០៤ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ ។ សេចក្តីប្រកាសនេះ អាចរកអានបានតាមរយៈគេហទំព័រ http://www.eccc.gov.kh/articles/25280

២៧ សេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងសំណុំរឿង០០៣ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ។ http://www.eccc.gov.kh/articles/25809

២៨ OSJI : Recent Development at the ECCC, ទំព័រទី១៣ ។

២៩ សេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងសំណុំរឿង០០៣ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ។ http://www.eccc.gov.kh/articles/25809

៣០ ដដែល ដូចខាងលើ ។

៣១ សេចក្តីសម្រេចទទួលស្គាល់មេធាវី និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង០០៣, ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣, ឯកសារ D58 ។

៣២ សេចក្តីសម្រេចទទួលស្គាល់មេធាវីទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង០០៤, ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៣, ឯកសារD126 ។ http://www.eccc.gov.kh/sites/default/files/documents/courtdoc/2013-04-19%2013:22/D126_KH.PDF

៣៣ Anne Heindel," *Civil Party Lawyers Granted Access to Case Files 003 & 004"*, ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ ។ *http://www.cambodiatribunal.org/wp-content/uploads/2013/08/commentary_130423.pdf* ។ សូមមើលផងដែរ "សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លោក រ៉ូប៊ីត ហាមីល, ឯកសារលេខ D11/2/4/4 ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១, មតិយោបល់របស់ចៅក្រម LAHUIS និងចៅក្រម DOWNING, កថាខណ្ឌទី៦ ។

៣៤ សូមមើលឯកសារ "ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ" ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ។ សូមមើលផងដែរ សុខ ខេមរា, "*War Crimes Tribunal Notified a Key Suspect*", វិទ្យុសំឡេងសហរដ្ឋអាមេរិក, ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០១២ ។

៣៥ Anne Heindel, *"Decision on Case 004 Suspect's Right to Counsel"* ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៣ ។

៣៦ ជនជាប់ចោទ អៀង សារី បានទទួលមរណភាពនៅព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ។

៣៧ *Julia Wallace*, កាសែត ឌឹ ខេមបូឌា ដេលី, *"Judge Removes Case 003 Suspect's Lawyers"* ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ។ អត្ថបទនេះអាចរកអានបានតាមរយៈគេហទំព័រ *http://www.cambodiadaily.com/archives/judge-removes-case-003-suspects-lawyers-51056/*

៣៨ សេចក្តីប្រកាសរបស់អង្គភាពគាំពារការពារក្តី ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៤, លោក ប៊ិត ស៊ាងលីម និង លោក សូ មូស្សេទ្ធី ត្រូវបានចាត់តាំងជាមេធាវីការពារក្តីដើម្បីតំណាងជនសង្ស័យពីររូបក្នុងសំណុំរឿង០០៤ ។

៣៩ សេចក្តីប្រកាសរបស់អង្គភាពគាំពារការពារក្តី ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤, លោកស្រី SUZANA TOMANOVI ត្រូវបានចាត់តាំងជាមេធាវីការពារក្តី ដើម្បីតំណាងជនសង្ស័យម្នាក់ក្នុងសំណុំរឿង០០៤ ។ http://www.eccc.gov.kh/articles/29999

៤០ សេចក្តីប្រកាសរបស់អង្គភាពគាំពារការពារក្តី ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៤, លោក *JOHN R.W.D. JONES* ត្រូវបានចាត់តាំងជាសហមេធាវីការពារក្តីអន្តរជាតិ ដើម្បីតំណាងជនសង្ស័យម្នាក់នៅក្នុងសំណុំរឿង០០៤ ។ http://www.eccc.gov.kh/articles/30145

៤១ *Julia Wallace*, កាសែត ឌឹ ខេមបូឌា ដេលី, *"Judge Removes Case 003 Suspect's Lawyers"* ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ។

៤២ សុខ ខេមរា, «សំណុំរឿងខ្មែរក្រហម០០៣ និង០០៤ មិនដើរទៅមុខ», វិទ្យុសំឡេងសហរដ្ឋអាមេរិក, ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៤ ។ អត្ថបទនេះអាចរកអានបានតាមរយៈគេហទំព័រ *http://khmer.voanews.com/content/without-more-indictments-cambodia-tribunal-lawyers-face-difficulties-khmer/1865129.html*

៤៣ *Stuart White*, កាសែត ភ្នំពេញប៉ុស្តិ៍, «*Controversial Case 004 gets new international attorney*», ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤ ។ អត្ថបទនេះអាចរកអានបានតាមរយៈគេហទំព័រ http://www.phnompenhpost.com/national/controversial-case-004-gets-new-international-attorney

៤៤ សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីសំណុំរឿង០០៤ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ។ សេចក្តីថ្លែងការណ៍នេះអាចរកមើលបានតាមរយៈអាសយដ្ឋានគេហទំព័រ *http://www.eccc.gov.kh/articles/30193*

៤៥ ដដែល ដូចខាងលើ ។

៤៦ ដដែល ដូចខាងលើ ។

# ការវិវត្តន៍ និងបញ្ហាប្រឈមផ្នែកថវិកា នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ចាន់ ប្រាថ្នា

## ១) មូលដ្ឋានច្បាប់

ថវិកាសម្រាប់ចំណាយនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានធានាដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ។ កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ និងច្បាប់ស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានកំណត់អំពីការទទួលខុសត្រូវរបស់ភាគីទាំងពីរនេះ ។

### ក) កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ

តាមរយៈកិច្ចព្រមព្រៀងនេះ រាជរដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ចត្រូវផ្តល់ និងរ៉ាប់រងចំណាយដោយខ្លួនឯងនូវអាគារសម្រាប់សហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះ និងការិយាល័យរដ្ឋបាល ។ រាជរដ្ឋាភិបាលក៏ត្រូវផ្តល់នូវសម្ភារប្រើប្រាស់ ការជួយសម្រួល និងសេវាកម្មផ្សេងៗទៀតដែលចាំបាច់សម្រាប់ប្រតិបត្តិការរបស់អង្គជំនុំជម្រះ ដែលអាចឯកភាពគ្នាបានតាមរយៈកិច្ចព្រមព្រៀងដោយឡែករវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាល ។[១] បន្ថែមលើនេះ រាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកបង់ប្រាក់បៀវត្សរ៍ និងប្រាក់បំណាច់របស់ចៅក្រមកម្ពុជា ព្រះរាជអាជ្ញាកម្ពុជា និងបុគ្គលិកកម្ពុជាផ្សេងទៀត ។[២] ចំណែកអង្គការសហប្រជាជាតិទទួលបន្ទុកបង់ប្រាក់



អ្នកភូមិតម្រង់ជួរដើម្បីចូលមើលកិច្ចដំណើរការសវនាការនៅសាលាក្តីខ្មែរក្រហម (បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

បៀវត្សរ៍ និងប្រាក់បំណាច់របស់ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ និងបុគ្គលិកអន្តរជាតិផ្សេងទៀត ដែលជ្រើសរើសដោយអង្គការសហប្រជាជាតិ ។[៣] លើសពីនេះ អង្គការសហប្រជាជាតិត្រូវទទួលខុសត្រូវទៅលើ ៖

១ ប្រាក់បៀវត្សរ៍របស់ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិកអន្តរជាតិដទៃទៀត ។

២ ចំណាយសម្រាប់ថ្លៃទឹក ភ្លើង ទូរស័ព្ទ។ល។ ឬសេវាផ្សេងៗ ដោយមានការព្រមព្រៀងគ្នាដោយឡែករវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ។

៣ ប្រាក់បៀវត្សរ៍សម្រាប់មេធាវីការពារក្តី ។

៤ ការធ្វើដំណើររបស់សាក្សីក្នុងប្រទេសកម្ពុជា និងមកពីបរទេស ។

៥ សុវត្ថិភាព និងសន្តិសុខ ដោយមានការព្រមព្រៀងគ្នាដោយឡែករវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ។

៦ ជំនួយឧបត្ថម្ភមានកំណត់ដទៃទៀតដែលអាចនឹងចាំបាច់ ដើម្បីធានាដំណើរការរលូនដល់ការស៊ើបអង្កេត ការចោទប្រកាន់និងអង្គជំនុំជម្រះវិសាមញ្ញ ។[៤]

## ១) ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ

ច្បាប់ស្តីពី«ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ» ត្រូវបានធ្វើវិសោធនកម្មជាលើកចុងក្រោយនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០០៤។ ច្បាប់នេះបានបញ្ជាក់បន្ថែមអំពីកាតព្វកិច្ចរបស់ភាគីកម្ពុជា និងភាគីអង្គការសហប្រជាជាតិក្នុងការធានាចំពោះ ការចំណាយ និងប្រាក់បៀវត្សរ៍ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មាត្រា៤៤ថ្មី នៃច្បាប់នេះចែងថា ៖ ការចំណាយ និងប្រាក់បៀវត្សរ៍របស់អង្គជំនុំជម្រះវិសាមញ្ញមាន ៖

១ ការចំណាយ និងប្រាក់បៀវត្សរ៍ ចំពោះមន្ត្រីរដ្ឋបាល និងបុគ្គលិកខ្មែរ ចំពោះចៅក្រមជម្រះក្តី និងចៅក្រមជម្រះក្តីបម្រុង ចៅក្រមស៊ើបអង្កេត និងចៅក្រមស៊ើបអង្កេតបម្រុង ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាបម្រុងខ្មែរទាំងអស់ជាបន្ទុករបស់ថវិកាជាតិខ្មែរ ។

២ ការចំណាយចំពោះមន្ត្រីរដ្ឋបាល និងបុគ្គលិកបរទេស ចៅក្រមជម្រះក្តី សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតបរទេស ដែលបញ្ជូនមកដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ជាបន្ទុករបស់អង្គការសហប្រជាជាតិ ។

៣ មេធាវីការពារក្តីអាចទទួលប្រាក់កម្រៃពីកិច្ចការពារក្តីរបស់ខ្លួន ។

៤ ការចំណាយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក៏អាចទទួលបន្ថែមនូវមូលនិធិស្ម័គ្រចិត្តដទៃទៀត ដូចជា រដ្ឋាភិបាលបរទេស ស្ថាប័នអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលនានា ហើយនឹងបុគ្គលដែលមានបំណងចង់ជួយដល់កិច្ចដំណើរការនេះ ។

## ២) បញ្ហាប្រឈមផ្នែកថវិកានៅអង្គជំនុំជម្រះវិសាមញ្ញ

ទោះបីមានការធានាដូចបានបញ្ជាក់ក្នុងវិធានខាងលើនេះក្តី ប៉ុន្តែសម្រាប់ការអនុវត្តន៍ជាក់ស្តែង អង្គជំនុំជម្រះវិសាមញ្ញបានប្រឈមមុខយ៉ាងខ្លាំងទៅនឹងបញ្ហាកង្វះខាតថវិកាសម្រាប់ការចំណាយ ដើម្បីធានានូវការប្រព្រឹត្តដោយរលូននៃកិច្ចដំណើរការជំនុំជម្រះក្តីខ្លួន ។ ជាក់ស្តែង កាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីប្រកាសកាត់បន្ថយចំនួនថ្ងៃធ្វើសវនាការរបស់ខ្លួន ដោយធ្វើសវនាការពីថ្ងៃច័ន្ទដល់ថ្ងៃពុធ ប៉ុណ្ណោះសម្រាប់សប្តាហ៍នីមួយៗ ។ សេចក្តីសម្រេចនេះ អង្គជំនុំជម្រះគ្រោងនឹងអនុវត្តចាប់ពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ ២០១២តទៅ ។ ទោះបីជាអង្គជំនុំជម្រះបានយល់យ៉ាងច្បាស់ថា សេចក្តីសម្រេចរបស់ខ្លួននឹងធ្វើឲ្យប៉ះពាល់ទៅដល់ភាពចាំបាច់នៃការធ្វើសវនាការឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន និងអាចនាំទៅដល់ការពន្យារពេលក្នុងការចេញសេចក្តីសម្រេចក្តី អង្គជំនុំជម្រះគ្មានជម្រើសផ្សេងឡើយ នៅពេលការិយាល័យ

ជំនួយរដ្ឋបាលរបស់អង្គការសហប្រជាជាតិ ដល់តុលាការខ្មែរក្រហម (UNAKRT) ជូនដំណឹងថា តុលាការជួបប្រទះបញ្ហាកង្វះខាតថវិកា ។ ការិយាល័យនេះបានបញ្ជាក់ថា ដោយសារបញ្ហាកង្វះខាតថវិកា អង្គជំនុំជម្រះសាលាដំបូងពុំអាចជ្រើសរើសមន្ត្រី និងបុគ្គលិក ដើម្បីឲ្យមកជំនួសកន្លែងមន្ត្រីច្បាប់អន្តរជាតិសំខាន់ៗ និងបុគ្គលិកអន្តរជាតិដទៃទៀតបានឡើយ ។ គួរបញ្ជាក់ថា ចំនួនបុគ្គលិកអន្តរជាតិដែលនៅសល់នៅពេលនោះ គឺមានប្រហែលតែពាក់កណ្តាលប៉ុណ្ណោះ បើធៀបទៅនឹងតារាងបញ្ជីបុគ្គលិកសរុបរបស់អង្គជំនុំជម្រះសាលដំបូង ដែលបានអនុម័តរួចហើយនៅក្នុងគម្រោងថវិការបស់អង្គជំនុំជម្រះវិសាមញ្ញ ។

អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា បញ្ហាកង្វះខាតថវិកានេះ បានបណ្តាលឲ្យអង្គជំនុំជម្រះ ពុំមានបុគ្គលិកគ្រប់គ្រាន់ដើម្បីបំពេញការងារឲ្យបានពេញលេញ និងមានប្រសិទ្ធិភាព ។ អង្គជំនុំជម្រះត្រូវការមន្ត្រីច្បាប់ និងបុគ្គលិកផ្សេងៗទៀតជាចាំបាច់សម្រាប់ជាជំនួយ និងដំណើរការទាំងនៅខាងក្នុង និងនៅខាងក្រៅនៃបន្ទប់សវនាការ ។ តាមការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូង មន្ត្រីច្បាប់ទាំងនោះ មានតួនាទីបំពេញការងារសំខាន់ៗដូចជា រៀបចំបញ្ជីឈ្មោះសាក្សី ធ្វើសេចក្តីសង្ខេបជូនចៅក្រម រួមទាំងកែសម្រួល និងរៀបចំឯកសារស្ថាពរបន្ទាប់ពីចៅក្រមបានពិភាក្សាគ្នារួច ។ កាន់តែសំខាន់ជាងនេះទៅទៀត មន្ត្រីច្បាប់ទាំងនោះមានតួនាទីជាអ្នករៀបចំសេចក្តីព្រាងដំបូងនៃសេចក្តីសម្រេចទាំងអស់ដោយផ្អែកតាមការណែនាំរបស់ចៅក្រម ។ ក្រៅពីនេះ មន្ត្រីច្បាប់ និងបុគ្គលិកទាំងនោះមានតួនាទីជួយធ្វើការស្រាវជ្រាវលើបញ្ហាច្បាប់ស្មុគស្មាញ ដែលភាគីបានលើកឡើងតាមរយៈសារណាដោយផ្ទាល់មាត់ក្តី និងជាលាយលក្ខណ៍អក្សរក្តី រួមទាំងការឆ្លើយតបទៅនឹងការងាររដ្ឋបាលជាច្រើនទៀតដែលចាំបាច់សម្រាប់ឲ្យកិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅដោយរលូន ។ អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា យ៉ាងហោចណាស់ ក៏តម្រូវឲ្យមានមន្ត្រីច្បាប់អន្តរជាតិមួយរូបនៅក្នុងបន្ទប់សវនាការក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី ដើម្បីផ្តល់ជំនួយដល់ចៅក្រមដែលជាការចាំបាច់សម្រាប់ឲ្យចៅក្រមមានលទ្ធភាពចេញសេចក្តីសម្រេចដោយផ្ទាល់មាត់ក្នុងអំឡុងពេលសវនាការកំពុងតែប្រព្រឹត្តទៅ ។

អង្គជំនុំជម្រះសាលាដំបូង បានគូសបញ្ជាក់ថា អស់រយៈពេល៣ខែ មុនការចេញសេចក្តីប្រកាសនេះ អង្គជំនុំជម្រះបានជូនដំណឹងម្តងហើយម្តងទៀតទៅផ្នែករដ្ឋបាលរបស់ UNAKRT និងផ្នែកពាក់ព័ន្ធនៃអង្គការសហប្រជាជាតិ អំពីផលលំបាកដែលអង្គជំនុំជម្រះកំពុងប្រឈមដោយសារពុំមានបុគ្គលិកគ្រប់គ្រាន់ដើម្បីបំពេញការងារឲ្យបានពេញលេញ និងមានប្រសិទ្ធិភាព ។ ប៉ុន្តែពុំមានដំណោះស្រាយជាស្ថាពរណាមួយឡើយ ហើយក្នុងរយៈពេលនោះ អង្គជំនុំជម្រះបានខិតខំព្យាយាមបំពេញការងារជាមួយមន្ត្រីមួយចំនួនតូចដែលនៅសេសសល់ ដែលកត្តាទាំងនេះអាចនាំទៅដល់ការពន្យារពេលក្នុងការចេញសេចក្តីសម្រេច និងប៉ះពាល់ដល់ការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធី ។ ទោះបីជាយ៉ាងណាអង្គជំនុំជម្រះនឹងធ្វើសវនាការជាប្រក្រតីឡើងវិញ ប្រសិនបើការខ្វះខាតបុគ្គលិកនេះត្រូវបានដោះស្រាយ ។[៥]

គួរបញ្ជាក់ថា ជាធម្មតាអង្គជំនុំជម្រះសាលាដំបូងបើកសវនាការជំនុំជម្រះសេចក្តីទៅលើសំណុំរឿង០០២ ចំនួន៤ថ្ងៃក្នុងមួយសប្តាហ៍ គឺពីថ្ងៃច័ន្ទដល់ថ្ងៃព្រហស្បតិ៍ ។ សម្រាប់ថ្ងៃសុក្រ អង្គជំនុំជម្រះពុំបើកសវនាការឡើយ ដោយទុកពេលវេលានេះសម្រាប់ជួបប្រជុំ ដើម្បីពិនិត្យវាយតម្លៃលទ្ធផលការងាររបស់ខ្លួន និងរៀបចំខ្លួនសម្រាប់សវនាការសប្តាហ៍បន្តបន្ទាប់ទៀត ដើម្បីធ្វើយ៉ាងណាឲ្យសវនាការប្រព្រឹត្តទៅដោយរលូន ឬដើម្បីដោះស្រាយសំណើផ្សេងៗ ដែលភាគីបានដាក់ ។ ដូច្នេះ ការដែលអង្គជំនុំជម្រះគ្រោងនឹងកាត់បន្ថយចំនួនថ្ងៃបើកសវនាការនេះ គឺដើម្បីធានាថាអង្គជំនុំជម្រះសាលាដំបូងមានពេលវេលាគ្រប់គ្រាន់ (ថ្ងៃព្រហស្បតិ៍ និងថ្ងៃសុក្រ) ក្នុងការដោះស្រាយ និងឆ្លើយតបទៅនឹងសំណើនានារបស់ភាគីបានទាន់ពេលវេលា និងត្រៀមរៀបចំសាក្សី និងអ្នកជំនាញសម្រាប់ស្តាប់សក្ខីកម្មនៅ ក្នុងសប្តាហ៍ក្រោយៗជាបន្តបន្ទាប់ទៀត ដែលការងារទាំងនេះពីមុនត្រូវបានជំនួយដោយមន្ត្រីច្បាប់ និងបុគ្គលជាច្រើន ។

នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១២ វិទ្យុបារាំងអន្តរជាតិ ដែលផ្សាយជាខេមរភាសា បានបញ្ជាក់ថា អង្គជំនុំជម្រះវិសាមញ្ញកំពុងតែប្រឈមមុខយ៉ាងធ្ងន់ធ្ងរទៅនឹងវិបត្តិថវិកាដោះស្រាយមិនចេញ ។ ដោយបញ្ជាក់ថា ភាគីអង្គការសហប្រជាជាតិកំពុង

ប្រឈមនឹងកង្វះខាតថវិកាចំនួន ៤លានដុល្លារ ដើម្បីបញ្ចប់ការងាររបស់ខ្លួនសម្រាប់ឆ្នាំ២០១២ ។ កាន់តែមានការព្រួយបារម្ភជាងនេះទៅទៀត គម្រោងថវិកា ដែលបានលើកឡើងសម្រាប់ចំណាយក្នុងឆ្នាំ២០១៣ មកដល់ថ្ងៃទី១១ ខែវិច្ឆិកា គឺពុំទាន់ប្រទេសម្ចាស់ជំនួយណាមួយ បានសន្យាផ្តល់ថវិកាជូនអង្គជំនុំជម្រះវិសាមញ្ញ ដើម្បីបន្តការងាររបស់ខ្លួននៅក្នុងឆ្នាំ២០១៣ឡើយ ។

នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២ លោក ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទីនៃអង្គជំនុំជម្រះវិសាមញ្ញ បានជូនដំណឹងថា តុលាការមានថវិកាសម្រាប់ចំណាយដល់ចុងឆ្នាំ២០១២ ប៉ុន្តែខ្វះខាតក្នុងការបើកប្រាក់បៀវត្សរ៍ឲ្យបុគ្គលិកខ្មែរសម្រាប់ខែធ្នូប្រមាណ៣០០នាក់ ដោយរាប់ចាប់តាំងពីអ្នកបើកបររហូតដល់ព្រះរាជអាជ្ញា និងចៅក្រមជំនុំជម្រះ ។ ដើម្បីដោះស្រាយបញ្ហាចំពោះមុខនេះ ផ្នែកថវិកា និងហិរញ្ញវត្ថុបានធ្វើការជាមួយម្ចាស់ជំនួយ និងអ្នកគ្រប់គ្រងថវិកា ដើម្បីទទួលបានថវិកាដែលនៅសល់ប្រមាណ ៣សែនដុល្លារអាមេរិក ដែលស្ថិតនៅក្នុងគម្រោងគាំទ្រដោយសហភាពអឺរ៉ុប ។ ថវិកានេះនឹងយកមកទូទាត់ប្រាក់បៀវត្សរ៍សម្រាប់ខែធ្នូ ។ តាមរយៈសេចក្តីជូនដំណឹងនេះដែរ បានបញ្ជាក់ថា នៅឆ្នាំ២០១៣ បុគ្គលិកខ្មែរនឹងប្រឈមមុខចំពោះការមិនទទួលបានប្រាក់បៀវត្សរ៍ចាប់ពីខែមករា ឆ្នាំ២០១៣ រហូតដល់មានការផ្តល់វិភាគទានថ្មី ។ បញ្ហាដែលបានកើតឡើង និងភាពមិនច្បាស់លាស់ទាំងនេះ បានបង្កឲ្យមានការព្រួយបារម្ភថា អាចធ្វើឲ្យប៉ះពាល់ដល់ទឹកចិត្ត និងស្មារតីរបស់បុគ្គលិកខ្មែរក្នុងការបំពេញការងារ ។ ក្នុងឱកាសនោះ លោក ក្រាញ់ តូនី បានអំពាវនាវដល់ប្រទេសម្ចាស់ជំនួយសំខាន់ៗ ឲ្យផ្តល់ថវិកាសង្គ្រោះបន្ទាន់ ដើម្បីបន្តនិរន្តរភាពការងារ និងចៀសវាងការរាំងស្ទះដល់កិច្ចដំណើរការជំនុំជម្រះក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញ ។[៦]

ទោះបីមានការអំពាវនាវដូច្នេះក្តី នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៣ លោក នេត្រ ភក្ត្រា អ្នកនាំពាក្យរបស់អង្គជំនុំជម្រះវិសាមញ្ញបានបញ្ជាក់ថា បុគ្គលិកខ្មែរប្រមាណ ៣០០រូបនោះនៅពុំទាន់ទទួលបានប្រាក់បៀវត្សរ៍សម្រាប់ខែធ្នូ នៅឡើយ ហើយការយឺតយ៉ាវនេះអាចបន្តទៅដល់ចុងខែមករា ។ ដោយឡែកប្រាក់បៀវត្សរ៍សម្រាប់បុគ្គលិកខ្មែរសម្រាប់ខែមករា ពុំទាន់ប្រមើលមើលឃើញនូវឡើយ ។[៧] នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ លោក នេត្រ ភក្ត្រា បង្ហើបថា បុគ្គលិកជាតិខ្មែរមួយអាចនឹងលាឈប់ពីការងារ ដោយសារនៅតែពុំទាន់ទទួលបានប្រាក់បៀវត្សរ៍សម្រាប់ខែធ្នូ ឆ្នាំ២០១២ ។ ការបង្ហើបឲ្យដឹងនេះធ្វើឡើងនៅចំពេលដែលរដ្ឋាភិបាលប្រទេសជប៉ុន ប្រកាសផ្តល់ជំនួយហិរញ្ញវត្ថុដល់ភាគីអង្គការសហប្រជាជាតិចំនួន ២,៥លានដុល្លារសហរដ្ឋអាមេរិក ។ នៅខណៈពេលនោះ លោក នេត្រ ភក្ត្រា អំពាវនាវដល់បណ្តាប្រទេសម្ចាស់ជំនួយ ធ្វើការពិចារណាផ្តល់ថវិកាជូនអង្គជំនុំ


កងយុវជនកំពុងគាស់ថ្មដើម្បីជីកប្រឡាយទាញទឹកធ្វើកសិកម្មក្នុង

ជម្រះវិសាមញ្ញ ដើម្បីផ្គត់ផ្គង់ចំណាយសម្រាប់ឆ្នាំ២០១៣ ។[៨]

នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ បុគ្គលិកខ្មែរជាងពាក់កណ្តាល ដែលក្នុងនោះមានទាំងបុគ្គលិកមកពីផ្នែកគ្រប់គ្រងតុលាការ ផ្នែកបកប្រែភាសាបានដាក់លិខិតទៅកាន់ការិយាល័យរដ្ឋបាល ដើម្បីសួរនាំអំពីប្រាក់បៀវត្សរ៍សម្រាប់ខែធ្នូ និងជូនដំណឹងថា ខ្លួននឹងធ្វើការរហូតដល់បំណាច់ខែមករា ឆ្នាំ២០១៣ ហើយបើនៅតែមិនមានប្រាក់ខែទៀត នោះនឹងមានការលាឈប់ពី

ការងារ ។ បុគ្គលិកទាំងនោះបានបញ្ជាក់បន្ថែមទៀតថា ក្នុងករណីដែលគ្មានព័ត៌មាន ឬប្រភពណាមួយដែលអាចជឿជាក់បានថា ប្រាក់បៀវត្សរ៍របស់គាត់នឹងបានទូទាត់ក្នុងរយៈពេលមួយសមស្របនៅពេលខាងមុខនោះបុគ្គលិកជាតិ នឹងពិចារណាលទ្ធភាពនៃការធ្វើពហិការមិនបំពេញការងារ ឬប្រកាន់យកវិធានការចាំបាច់ណាមួយដើម្បីដោះស្រាយជីវភាពផ្ទាល់ខ្លួន ។ លោក នេត្រ ភក្ត្រា បានបញ្ជាក់ថា «បើសិនជា បញ្ហានេះនៅតែពន្យារពេលមិនទាន់មានដំណឹងឲ្យបានមុនថ្ងៃទី៣១ ខែមករា ទេ នោះបុគ្គលិកជាតិ



...នរបបខ្មែរក្រហម (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នឹងឈប់ធ្វើការដែលនឹងធ្វើឲ្យប៉ះពាល់ដល់ដំណើរការជំនុំជម្រះគឺដែលនឹងក្លាយជាខបសគ្គមួយនៅក្នុងដំណើរការស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា» ។[៩] ជាថ្មីម្តងទៀត អ្នកនាំពាក្យរូបនេះអំពាវនាវឲ្យបណ្តាប្រទេសដែលផ្តល់ជំនួយទាំងអស់ធ្វើការពិចារណាអំពីបញ្ហាប្រឈមនេះ និងអនុម័តផ្តល់ថវិកាជូនអង្គជំនុំជម្រះវិសាមញ្ញសម្រាប់ចំណាយក្នុងឆ្នាំ២០១៣ ។

ទោះបីមានការបញ្ជាក់ពីបុគ្គលិកជាតិ និងមានការអំពាវនាវឲ្យផ្តល់ជំនួយដូចបានបញ្ជាក់ខាងលើនេះក្តី រហូតដល់ខែកុម្ភៈ បញ្ហាកង្វះខាតថវិកាសម្រាប់បើកប្រាក់បៀវត្សរ៍ឲ្យបុគ្គលិកខ្មែរនៅតែមិនមានដំណោះស្រាយ ហើយពុំទាន់មានប្រទេសម្ចាស់ជំនួយណាមួយសន្យាផ្តល់ថវិកាឲ្យភាគីកម្ពុជាសម្រាប់ចំណាយក្នុងឆ្នាំ២០១៣ឡើយ ។[១០] ជាលទ្ធផលនៅព្រឹកថ្ងៃច័ន្ទ ទី០៤ ខែមីនា ឆ្នាំ២០១៣ នៅពេលអង្គជំនុំជម្រះចូលមកដល់ក្នុងបន្ទប់សវនាការភ្លាម បុគ្គលិកជាតិខ្មែរផ្នែកបកប្រែភាសា បានប្រកាសជាសាធារណៈនៅចំពោះមុខចៅក្រមថា «យើងខ្ញុំជាបុគ្គលិកផ្នែកបកប្រែភាសានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមប្រកាសអនុវត្តការធ្វើពហិការមិនបំពេញការងារចាប់ពីពេលនេះ ថ្ងៃច័ន្ទ ទី០៤ ខែមីនា ឆ្នាំ២០១៣ នេះតទៅ រហូតដល់យើងខ្ញុំទទួលបានប្រាក់ខែពេញលេញសម្រាប់ខែធ្នូ ឆ្នាំ ២០១២ និងខែមករា ខែកុម្ភៈ ឆ្នាំ២០១៣ ទើបយើងខ្ញុំនឹងចាប់ផ្តើមចូលបំពេញការងារ ដូចប្រក្រតីឡើងវិញ» ។[១១] ការប្រកាសនេះ បានបង្កឲ្យមានការស្រឡាំងកាំងយ៉ាងខ្លាំងសម្រាប់អ្នកដែលបានចូលរួម តាមដានសវនាការដោយផ្ទាល់ ហើយមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីបណ្តាអ្នកការសែតជាតិ និងអន្តរជាតិ ។ គួរបញ្ជាក់ថា សកម្មភាពធ្វើពហិការរបស់អង្គភាពបកប្រែភាសានេះ ត្រូវបានគាំទ្រដោយបុគ្គលិកជាតិនៅផ្នែកផ្សេងៗទៀត ដែលសរុបទាំងអស់មានចំនួន ២៨៧នាក់ ។[១២]

បន្ទាប់ពីថយទៅពិភាក្សាជាមួយការិយាល័យរដ្ឋបាលមួយរយៈពេលខ្លីអង្គជំនុំជម្រះសម្រេចផ្អាក សវនាការ ដោយសារពុំមានអ្នកបកប្រែ ព្រោះនៅក្នុងតុលាការនេះប្រើប្រាស់ជាបីភាសា គឺភាសាខ្មែរ ភាសាបារាំង និងភាសាអង់គ្លេស ។ ការប្រកាសផ្អាកនេះ អង្គជំនុំជម្រះពុំបានកំណត់ពេលវេលាជាក់លាក់ណាមួយដែលនឹងត្រូវបើកសវនាការឡើងវិញឡើយ គឺអាស្រ័យលើស្ថានភាពថវិកា និងសុខភាពរបស់ជនជាប់ចោទ អៀង សារី ដែលត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ។ គួរបញ្ជាក់ថា នៅថ្ងៃដដែលនោះ អង្គជំនុំជម្រះបានជូនដំណឹងថា ជនជាប់ចោទ អៀង សារី ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មិនអាចចូលរួមសវនាការបាន ។ ដូច្នេះ នេះក៏ជាហេតុផលមួយដែរ ដែលអង្គជំនុំជម្រះសាលាដំបូងផ្អាកសវនាការរបស់ខ្លួន ។

នៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៣ លោក ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្ដីទីបានជួបចរចាជាមួយបុគ្គលិកផ្នែកបកប្រែភាសា ដើម្បីបន្ធូរបន្ថយភាពតានតឹងនៅខណៈដែលអង្គភាពនេះនៅតែបន្តធ្វើពហិការមិនចូលបម្រើការងារ ។ លទ្ធផលនៃការចរចាបុគ្គលិកផ្នែកបកប្រែភាសាបានបន្ធូរលក្ខខណ្ឌ ដោយយល់ព្រមចូលបម្រើការងារវិញ ប្រសិនបើគាត់ទទួលបានប្រាក់បៀវត្សរ៍សម្រាប់ខែធ្នូ ។ ចំពោះប្រាក់បៀវត្សរ៍សម្រាប់ខែមករា ខែកុម្ភៈ និងខែមីនា អាចពន្យារពេលហូតដល់ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៣ ។ ក្នុងករណីមិនគោរពលក្ខខណ្ឌនេះ បុគ្គលិកផ្នែកបកប្រែភាសានឹងធ្វើពហិការមិនចូលធ្វើការសាជាថ្មី ។ ក្នុងការដោះស្រាយបញ្ហាបន្ទាន់នេះ លោក នេត្រ ភក្ត្រា ធ្វើការអំពាវនាវជាថ្មីម្ដងទៀត ទៅដល់សហភាពអឺរ៉ុបឲ្យផ្ដល់ថវិកាចំនួន៣សែនដុល្លារសហរដ្ឋអាមេរិក ដែលសហភាពនេះបានសន្យារផ្ដល់ជូនភាគីកម្ពុជាតាំងពីយូរមកហើយ ។[១៣]

ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាបន្ទាន់នេះពុំត្រូវបានដោះស្រាយឡើយ ហើយបានអូសបន្លាយ ដែលកត្តាទាំងនេះបានបង្កឲ្យបុគ្គលិកផ្នែកផ្សេងៗទៀត ប្រកាសធ្វើពហិការមិនចូលបម្រើការងារជាបន្តបន្ទាប់ ។ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៣ បុគ្គលិកផ្នែកប្រតិចារឹកដែលទទួលបន្ទុកកត់ត្រាទាំងស្រុងអំពីកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះ ប្រកាសធ្វើពហិការមិនចូលបម្រើការងារ ដោយសារគាត់នៅតែពុំទាន់ទទួលបានប្រាក់បៀវត្សរ៍ ។ រហូតមកដល់ថ្ងៃប្រកាសធ្វើពហិការនេះ អ្នកនាំពាក្យរបស់អង្គជំនុំជម្រះវិសាមញ្ញបានត្រឹមបញ្ជាក់ថា សាលាក្ដីខ្មែរក្រហមនៅតែរង់ចាំថវិកាចំនួន ៣សែនដុល្លារ ដែលសហភាពអឺរ៉ុបបានសន្យាផ្ដល់ជូនភាគីកម្ពុជា ។ អ្នកនាំពាក្យនោះបានបញ្ជាក់បន្ថែមថា ទោះបីមានបុគ្គលិកជាច្រើនប្រកាសធ្វើពហិការមិនចូលបម្រើការងារ ដោយសារពុំមានប្រាក់បៀវត្សរ៍រហូតមកដល់ថ្ងៃប្រកាសធ្វើពហិការរបស់បុគ្គលិកផ្នែកប្រតិចារឹកនេះ គឺពុំទាន់មានប្រទេសណាមួយប្រកាសផ្ដល់ថវិកាជូនភាគីកម្ពុជាឡើយ ។[១៤]

បន្ទាប់ពីអង្គភាពប្រតិចារឹកប្រកាសធ្វើពហិការមិនចូលបម្រើការងារបានមួយសប្ដាហ៍ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ បុគ្គលិកជាតិប្រមាណ២៧០នាក់បានយល់ព្រមចូលធ្វើការជាធម្មតាវិញ បន្ទាប់ពីទទួលបានការសន្យាថា គាត់នឹងទទួលបានប្រាក់បៀវត្សរ៍សម្រាប់ខែធ្នូ មិនលើសពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៣ ឡើយ ។ អ្នកនាំពាក្យរបស់តុលាការបានបញ្ជាក់ថា ថវិកានោះនឹងយកមកពីសហភាពអឺរ៉ុប មានចំនួន៣សែនដុល្លារ ដែលបានសន្យាផ្ដល់ជូនភាគីកម្ពុជា ។ អ្នកនាំពាក្យរូបនោះបានបញ្ជាក់បន្ថែមថា ទោះបីបុគ្គលិកខ្មែរចូលមកបម្រើការដូចធម្មតាក្ដី ប៉ុន្តែស្ថានភាពនេះនៅមានភាពផុយស្រួយនៅឡើយ ព្រោះបុគ្គលិកជាតិខ្មែរនឹងធ្វើពហិការសារជាថ្មី ប្រសិនបើមិនទទួលបានប្រាក់បៀវត្សរ៍សម្រាប់ខែមករា ខែកុម្ភៈ និងខែមីនា នៅត្រឹមថ្ងៃទី១ ខែមេសា ឆ្នាំ២០១៣ ។[១៥] គួរបញ្ជាក់ថា រហូតមកដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ តាមការបញ្ជាក់របស់លោក នេត្រ ភក្ត្រា គឺពុំទាន់មាន ប្រភពថវិកាជាក់លាក់ណាមួយសន្យាផ្ដល់ជូនតុលាការឡើយ ។ កត្តានេះបានបង្កឲ្យមានការព្រួយបារម្ភកាន់តែខ្លាំង ដោយសារកាលបរិច្ឆេទធ្វើកូដកម្មរបស់បុគ្គលិកជាតិកាន់តែជិតខិតចូលមកដល់ ។[១៦]

ដើម្បីដោះស្រាយស្ថានភាពតានតឹងនេះ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣ អង្គជំនុំជម្រះប្រកាសថា *«...ថវិកាសម្រាប់បុគ្គលិកជាតិ ត្រូវបានធានាឲ្យមានរហូតដល់បំណាច់ខែមេសា ហើយឥឡូវកំពុងពិភាក្សាគ្នា ថាតើត្រូវធ្វើយ៉ាងម៉េចដើម្បីឲ្យការផ្ដល់ថវិកានេះមានស្ថិរភាពបន្តទៅទៀត»* ។[១៧] បុគ្គលិកជាតិជាច្រើនរូបបានសម្ដែងនូវការអបអរសាទរជាខ្លាំងចំពោះសេចក្ដីប្រកាសនេះ ។ ជាការគួរឲ្យកត់សម្គាល់ មន្ត្រីជាន់ខ្ពស់របស់អង្គជំនុំជម្រះវិសាមញ្ញបានបញ្ជាក់ប្រាប់វិទ្យុបារាំងអន្តរជាតិថា ថវិកាដែលទទួលបានភ្លាមៗនេះ គឺជាមូលនិធិសង្គ្រោះបន្ទាន់ដែលភាគីអន្តរជាតិឲ្យខ្ចីជាបណ្ដោះអាសន្ន ក្នុងគោលបំណងដើម្បីធានាឲ្យកិច្ចដំណើរការរបស់អង្គជំនុំជម្រះប្រព្រឹត្តទៅដោយរលូន ។[១៨]

ទោះបីជាយ៉ាងណា ថវិកានេះធានាបានត្រឹមខែមេសាប៉ុណ្ណោះ ហើយរហូតមកដល់ចុងខែមេសា នេះគឺពុំទាន់មានប្រទេសណាមួយសន្យាផ្ដល់ជំនួយថវិកាដល់ភាគីកម្ពុជាឡើយ ។ ដូច្នេះ អង្គជំនុំជម្រះវិសាមញ្ញបន្តមានវិបត្តិថវិកាសម្រាប់បើកប្រាក់បៀវត្សរ៍ឲ្យបុគ្គលិកខ្មែរចាប់ពីខែឧសភា នៅខណៈពេលដែលបុគ្គលិកភាគីអន្តរជាតិត្រូវបានធានាថាមានប្រាក់បៀវត្សរ៍រហូតដល់ខែកញ្ញា ។

នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៣ លោក នេត្រ ភក្ត្រា បានប្រាប់វិទ្យុបារាំងអន្តរជាតិថា អង្គជំនុំជម្រះវិសាមញ្ញបានសម្រេចកាត់បន្ថយបុគ្គលិកជាតិខ្មែរចំនួន១០ភាគរយ ត្រូវនឹងចំនួន៣០នាក់ចាប់ពីខែកក្កដា ហើយនឹងកាត់បន្ថយចំនួន១០ភាគរយទៀតនៅបំណាច់ឆ្នាំ២០១៣ ។ មូលហេតុនៃការកាត់បន្ថយនេះ គឺដោយសារអង្គជំនុំជម្រះជួបប្រទះនឹងវិបត្តិថវិកា (នៅខណៈពេលដែលប្រាក់បៀវត្សរ៍របស់បុគ្គលិកជាតិខែសម្រាប់ខែមិថុនា មិនទាន់ទទួលបាននូវឡើយ) និងតម្រូវការដាក់ស្ដែងរបស់តុលាការ ។ អ្នកនាំពាក្យរូបនេះបានបញ្ជាក់បន្ថែមថា រហូតដល់ដើមខែកក្កដានេះ ភាគីកម្ពុជានៅពុំទាន់ទទួលបានការសន្យាផ្ដល់ថវិកាពីប្រទេសម្ចាស់ជំនួយណាមួយនៅឡើយ ។[១៩] ភាពព្រងើយកន្តើយរបស់ប្រទេសម្ចាស់ជំនួយនៅតែបន្តដដែល ទោះបីដឹងថាភាគីកម្ពុជាពុំមានប្រាក់សម្រាប់បើកប្រាក់បៀវត្សរ៍ឲ្យបុគ្គលិកខ្មែរចាប់តាំងពីខែមិថុនា មកក៏ដោយ ។ រហូតមកដល់ចុងខែកក្កដា ភាគីកម្ពុជានៅតែពុំទាន់ទទួលបានការសន្យាផ្ដល់ថវិកាពីបណ្ដាប្រទេសដែលធ្លាប់ផ្ដល់ជំនួយដដែល ។[២០]

ដើម្បីដោះស្រាយស្ថានភាពនេះ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៣ លោក កែវ រ៉េមី (រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី) តំណាងឲ្យភាគីកម្ពុជា និងលោក ដេវីត ហ្សេសហ៊ី (អ្នកជំនាញការពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកការងារសាលាក្ដីខ្មែរក្រហម) តំណាងឲ្យភាគីអន្តរជាតិ ធ្វើដំណើរទៅបណ្ដាប្រទេសក្នុងអាស៊ាន ដើម្បីស្វែងរកការឧបត្ថមថវិកាជូនសាលាក្ដីខ្មែរក្រហម ។[២១] ខណៈពេលដែលអ្នកទាំងពីរកំពុងស្វែងរកជំនួយ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ បុគ្គលិកជាតិដែលបម្រើការផ្នែកសេវា និងផ្នែកគ្រប់គ្រងតុលាការសរុបទាំងអស់១០០នាក់ បានដាក់ញត្តិសុំផ្អាកការងារមួយរយៈ ប្រសិនបើអង្គជំនុំជម្រះនៅតែពុំទាន់មានថវិកាសម្រាប់បើកប្រាក់បៀវត្សរ៍ឲ្យគាត់ទាំងអស់គ្នា ។ នៅក្នុងញត្តិនោះបានបញ្ជាក់ថា គាត់នឹងឈប់ធ្វើការងារចាប់ពីដើមខែកញ្ញា តទៅ ដើម្បីទៅប្រកបរបរផ្សេងៗទៀតសម្រាប់ចិញ្ចឹមជីវិតជាបណ្ដោះអាសន្ន ។[២២] ការដាក់ញត្តិសុំឈប់នេះ បានបង្កឲ្យមានការព្រួយបារម្ភយ៉ាងខ្លាំង ព្រោះនឹងនាំឲ្យមានការរាំងស្ទះ និងធ្វើឲ្យប៉ះពាល់ដល់កិច្ចដំណើរការរបស់អង្គជំនុំជម្រះ ហើយគម្រោងការងារមួយចំនួនដែលត្រូវធ្វើនឹងត្រូវពន្យារពេល ។ ទោះបីជាយ៉ាងនេះក្ដីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅតែគ្មានដំណោះស្រាយ ព្រោះភាគីកម្ពុជានៅតែពុំទាន់ទទួលបានការសន្យាផ្ដល់ថវិកាពីប្រទេសផ្ដល់ជំនួយណាមួយឡើយ ។ រហូតមកដល់ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ ការិយាល័យរដ្ឋបាលជូនដំណឹងថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅតែពុំទាន់មានថវិកាសម្រាប់បើកប្រាក់បៀវត្សរ៍ជូនបុគ្គលិកជាតិខ្មែរ ព្រោះរហូតមកថ្ងៃជូនដំណឹងនេះគ្មានប្រទេសណាមួយផ្ដល់ជំនួយដល់ភាគីកម្ពុជាឡើយ ។ ដូច្នេះការខកខានក្នុងការបើកប្រាក់បៀវត្សរ៍ជូនបុគ្គលិកជាតិខ្មែរតាំងពីខែមិថុនា មក នឹងនៅតែកើតមានបន្តទៀត ។[២៣]

បន្ទាប់ពីការជូនដំណឹងរបស់ការិយាល័យរដ្ឋបាល និងកាលបរិច្ឆេទធ្វើពហិការមិនចូលបម្រើការងាររបស់បុគ្គលិកជាតិខ្មែរកាន់តែខិតជិតចូលមកដល់ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ អគ្គលេខាអង្គការសហប្រជាជាតិ លោក បាន គីមូន បានប្រកាសជាសាធារណៈថា អង្គជំនុំជម្រះវិសាមញ្ញកំពុងតែជួបប្រទះនឹងវិបត្តិថវិកា ។ ដូច្នេះលោកអំពាវនាវឲ្យសហគមន៍អន្តរជាតិបន្តការគាំទ្រផ្នែកថវិកាដល់អង្គជំនុំជម្រះវិសាមញ្ញដើម្បីបន្តការងារដ៏សំខាន់របស់ខ្លួន។ លោក បាន គីមូន បានលើកឡើងថា បរាជ័យផ្នែកហិរញ្ញវត្ថុរបស់សាលាក្ដីនេះ គឺជាសោកនាដកម្មដ៏ធំមួយសម្រាប់ប្រជាជនកម្ពុជាដែលទន្ទឹងរង់ចាំយុត្តិធម៌ជាយូរមកហើយ ។ នេះក៏ជាបរាជ័យដ៏ធំមួយដែរសម្រាប់កិច្ចសន្យារបស់សហប្រជាជាតិក្នុងការស្វែងរកយុត្តិធម៌នៅលើឆាកអន្តរជាតិ ។[២៤]

ដោយនៅតែពុំមានប្រទេសម្ចាស់ជំនួយសន្យាផ្ដល់ថវិកាដល់ភាគីកម្ពុជា និងនៅតែពុំមានដំណោះស្រាយសមស្រប នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៣ បុគ្គលិកជាតិជាងពាក់កណ្ដាលបានធ្វើពហិការមិនព្រមចូលបម្រើការងារ ។ ការធ្វើពហិការនេះ ធ្វើឲ្យមានកិច្ចប្រជុំភ្លាមៗរវាង សុខ អាន ដែលទទួលបន្ទុកសាលាក្ដីខ្មែរក្រហមជាមួយឯកអគ្គរាជទូតប្រទេសជប៉ុន និងអូស្ត្រាលី ក្នុងគោលបំណង ស្វែងរកថវិកាដើម្បីជួយដល់សាលាក្ដីខ្មែរក្រហម ។ សុខ អាន បានជួបជាមួយឯកអគ្គរាជទូតជប៉ុន ដើម្បីស្នើសុំឲ្យ

ប្រទេសជប៉ុនផ្តល់ថវិកាជូនភាគីកម្ពុជា ។ សុខ អាន បានបញ្ជាក់ថា ជានិច្ចជាកាល ជប៉ុន បានផ្តល់ថវិកាជូនភាគីកម្ពុជា ។ ប៉ុន្តែនៅឆ្នាំ២០១៣ ប្រទេសជប៉ុនពុំទាន់ផ្តល់ថវិកាជូនភាគីកម្ពុជានៅឡើយ ពោលគឺផ្តល់ឲ្យតែភាគីអន្តរជាតិតែប៉ុណ្ណោះ ដែលការខកខាននេះបានធ្វើឲ្យភាគីកម្ពុជាជួបវិបត្តិថវិកាយ៉ាងធ្ងន់ធ្ងរ ។ ឯកអគ្គរាជទូតជប៉ុនបានបញ្ជាក់ថា ប្រទេសជប៉ុននឹងយកសំណើទៅពិចារណា ។ ចំពោះជំនួបជាមួយឯកអគ្គរាជទូតប្រទេសអូស្ត្រាលី តាមការបញ្ជាក់របស់ ឌឹម សុវណ្ណារុំ (ប្រធានផ្នែកកិច្ចការសាធារណៈរបស់តុលាការ) គឺពុំទទួលបានលទ្ធផលអ្វីឡើយ ។ ឯកអគ្គរាជទូតប្រទេសអូស្ត្រាលី បានបញ្ជាក់ថា ប្រទេសអូស្ត្រាលីបានផ្តល់ថវិកាចំនួន ៣,៥លានដុល្លា ដល់ភាគីអន្តរជាតិរួចហើយ ។ ដូច្នេះពុំមានថវិកាសម្រាប់ឲ្យភាគីកម្ពុជាទៀតឡើយ ។ តាមការបញ្ជាក់របស់ ឌឹម សុវណ្ណារុំ ថវិកាដែលផ្តល់មកពីប្រភពផ្សេងៗជូនអង្គជំនុំជម្រះវិសាមញ្ញភាគីជាតិគប្បីទទួលបានមួយចំណែកដែរ ព្រោះថវិកាទាំងនោះ ផ្តល់មកកញ្ចប់ថវិការបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលគម្រោងថវិកានោះត្រូវបានរៀបចំ និងស្នើឡើងដោយភាគីជាតិ និងភាគីអន្តរជាតិ ដើម្បីសុំថវិកាពីប្រទេសផ្តល់ជំនួយ ។ ថវិកាទាំងនោះនឹងត្រូវយកមកចំណាយសម្រាប់កិច្ចដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញទាំងមូល ។[២៥] ឌឹម សុវណ្ណារុំ បានអំពាវនាវដល់បណ្តាប្រទេសដែលធ្លាប់ផ្តល់ជំនួយថវិកាជូនអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជាចាប់តាំងពីឆ្នាំ២០០៦ បន្តផ្តល់ថវិកាជូនតុលាការសម្រាប់ចំណាយនៅឆ្នាំ២០១៣ ដើម្បីធានាកិច្ចដំណើរការរបស់ខ្លួនក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជា ។

នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៣ លោក ដេវីត ហ្សេសហ៊ី អ្នកជំនាញការពិសេសរបស់អគ្គលេខាអង្គការសហប្រជាជាតិទទួលបន្ទុកសាលាក្តីខ្មែរក្រហម បានចេញសេចក្តីថ្លែងការណ៍សម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះវិបត្តិថវិកា ដែលនាំទៅដល់ការធ្វើពហិការមិនចូលបម្រើការងារនៅសាលាក្តីខ្មែរក្រហម ។ នៅក្នុងសេចក្តីថ្លែងការណ៍នេះ លោក ដេវីត ហ្សេសហ៊ី




ខៀវ សំផន ឡើងធ្វើសេចក្តីថ្លែងការណ៍នៅក្នុងបន្ទប់សវនាការនៃសាលាក្តីខ្មែរក្រហម (បណ្ណសារ ៈ មជ្ឈ

បានហៅវិបត្តិនេះថា ជាបរាជ័យរបស់ភាគីកម្ពុជា ដែលមានកាតព្វកិច្ចក្នុងការស្វែងរកថវិកាបើកប្រាក់បៀវត្សរ៍ឲ្យបុគ្គលិករបស់ខ្លួន ។ លោកបានសង្កត់ធ្ងន់ថា ការធ្វើពហិការមិនចូលបម្រើការងារនេះ នឹងធ្វើឲ្យប៉ះពាល់ដល់កិច្ចដំណើរការជំនុំជម្រះលើរឿងក្តី ០០២ និងដំណើរការរបស់តុលាការទាំងមូល ។ គួរបញ្ជាក់ថា តាមការអះអាងរបស់ លោក ឌឹម សុវណ្ណរុំ បុគ្គលិកជាតិទាំងអស់ ដែលក្នុងនោះមានទាំងមន្ត្រីច្បាប់ បានធ្វើពហិការមិនចូលបម្រើការងារ ដែលកត្តានេះបានធ្វើឲ្យប៉ះពាល់ទាំងស្រុងទៅដល់កិច្ចដំណើរការជំនុំជម្រះលើសំណុំរឿង០០២ ។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ លោក ដេវីត ហេរុសហ្វី បានអំពាវនាវឲ្យបុគ្គលិកជាតិធ្វើការអត់ធ្មត់បន្តិច ។ លោកបានបញ្ជាក់ថា អង្គការសហប្រជាជាតិបានប្តេជ្ញាក្នុងការបញ្ចប់វិបត្តិថវិកា នៅសាលាក្តីខ្មែរក្រហមឲ្យបានឆាប់បំផុត និងធ្វើឲ្យមានស្ថិរភាពថវិកាសម្រាប់សាលាក្តីនេះ ដើម្បីធ្វើយ៉ាងណាឲ្យសាលាក្តីនេះសម្រេចបេសកកម្មរបស់ខ្លួន ។[២៦]


...ជួមណ្ឌលឯកសារកម្ពុជា)

គួរកត់សម្គាល់ថា ទោះបីជាមានការអំពាវនាវជាបន្តបន្ទាប់ពីមន្ត្រីរបស់តុលាការ ឬមន្ត្រីជាន់ខ្ពស់ របស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ហើយចុងក្រោយនេះ លោក បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិបានចេញមុខដោយផ្ទាល់ក្នុងការប្រកាសស្វែងរកជំនួយ ដើម្បីផ្តល់ជូនអង្គជំនុំជម្រះវិសាមញ្ញ ប៉ុន្តែជាលទ្ធផល គឺពុំមានប្រទេសណាមួយសន្យាផ្តល់ជំនួយថវិកាជូនភាគីជាតិ សម្រាប់បើកប្រាក់បៀវត្សរ៍ បុគ្គលិកខ្លួនឡើយ ។ ដូច្នេះ ដើម្បីដោះស្រាយវិបត្តិដែលកំពុងកើតឡើងដោយសារបុគ្គលិកជាតិកំពុងធ្វើពហិការមិនចូលបម្រើការងារ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ អង្គការសហប្រជាជាតិប្រកាសផ្តល់ប្រាក់កម្ចីដល់ភាគីកម្ពុជាចំនួន ១,១៥លានដុល្លារ សម្រាប់បើកឲ្យបុគ្គលិកជាតិខ្មែរ ។ ប្រាក់នេះគ្រប់គ្រាន់ល្មមសម្រាប់បើកប្រាក់បៀវត្សរ៍របស់បុគ្គលិកខ្មែរចំនួន ៣ខែចាប់គិតពីខែមិថុនា មក ។ នេះជាប្រាក់សង្គ្រោះលើកទី២ ដែលភាគីកម្ពុជានឹងសងភាគីអង្គការសហប្រជាជាតិវិញ នៅពេលក្រោយ ។ តាមការបញ្ជាក់របស់លោក នេត្រ ភក្ត្រា អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម ប្រាក់កម្ចីលើកទី២នេះគឺដោះស្រាយបានតែមួយរយៈប៉ុណ្ណោះ ពោលគឺសាលាក្តីខ្មែរក្រហមនៅតែប្រឈមនឹងការខ្វះខាតថវិកាដែលត្រូវចំណាយចាប់ពីខែកញ្ញា រហូតដល់បំណាច់ឆ្នាំ២០១៣ ដែលគិតជាទឹកប្រាក់មានចំនួន ១,៨លានដុល្លារសហរដ្ឋអាមេរិកទៀត ។[២៧]

នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចេញផ្សាយគម្រោងថវិកាសម្រាប់ចំណាយនៅក្នុងឆ្នាំ ២០១៤ និង២០១៥ ដែលត្រូវបានអនុម័តដោយក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ ។ យោងតាមសេចក្តីប្រកាសរបស់តុលាការថវិកាសរុបដែលអង្គជំនុំជម្រះវិសាមញ្ញត្រូវចំណាយក្នុងឆ្នាំ២០១៤ មានចំនួន ៣១,៦លានដុល្លារសហរដ្ឋអាមេរិក ដែលក្នុងនោះ បែងចែកឲ្យភាគីជាតិចំនួន ៦,៤លានដុល្លារ និងភាគីអន្តរជាតិចំនួន២៥,២លានដុល្លារ ។ សម្រាប់ឆ្នាំ២០១៥ អង្គជំនុំជម្រះវិសាមញ្ញនឹងត្រូវចំណាយចំនួន ២៨,៩ លានដុល្លារសហរដ្ឋអាមេរិក ដែលក្នុងនោះភាគីកម្ពុជាទទួលបាន ៦លានដុល្លារ និងភាគីអន្តរជាតិទទួលបាន ២២,៩លានដុល្លារ ។[២៨]

# វិសាលភាពនៃសំណុំរឿង០០២/០២

ចាន់ ប្រាថ្នា

## ១) មតិយោបល់របស់ភាគីអំពីវិសាលភាពសំណុំរឿង០០២/០២

### ក) សង្ខេបរួម

ក្នុងការកំណត់វិសាលភាពនៃសំណុំរឿង០០២/០២ សហព្រះរាជអាជ្ញាបានគូសបញ្ជាក់ថា សំណុំរឿង០០២/០២ គួរដាក់បញ្ចូលនូវអង្គហេតុមន្ទីរសន្តិសុខស-២១, ការប្រព្រឹត្តទៅលើជនជាតិចាម និងវៀតណាម (អំពើប្រល័យពូជសាសន៍), សហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ រួមទាំងការប្រព្រឹត្តដំណាក់កាលទី៣ និងការបោសសម្អាតខ្សាំងនៅភូមិភាគបូព៌ា ការចោទប្រកាន់នានាពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ និងការប្រព្រឹត្តមកលើពុទ្ធសាសនិកនៅទូទាំងប្រទេស ។

ចំណែកក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ស្នើសុំធ្វើយ៉ាងណាឲ្យសំណុំរឿង០០២/០២ គ្រប់ដណ្តប់ទៅលើគ្រប់បទចោទប្រកាន់ទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយដែល មិនទាន់ត្រូវបានយកមកជំនុំជម្រះនៅក្នុងសំណុំរឿង០០២/



កុមារីម្នាក់កំពុងបីប្អូនស្រីរបស់ខ្លួនដើរលេងក្បែរលំនៅដ្ឋានដែលត្រូវបានបំផ្លាញដោយរបបខ្មែរក្រហម ។
រូបនេះថតក្នុងឆ្នាំ១៩៧៩ នៅមុំផ្សារថ្មី ។ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ទៅលើពុទ្ធសាសនិក និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការដ្ឋានទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល ។ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីយល់ស្របចំពោះទីតាំងឧក្រិដ្ឋកម្ម និងអង្គហេតុដែលស្នើឡើងដោយសហព្រះរាជអាជ្ញា ហើយស្នើសុំឲ្យបញ្ចូលបន្ថែមនូវអង្គហេតុការដ្ឋានទំនប់ត្រពាំងថ្ម មន្ទីរសន្តិសុខភូមិភាគឧត្តរ និងមន្ទីរសន្តិសុខកោះខ្សែង ការជម្លៀសប្រជាជន ០១ ។ រីឯក្រុមមេធាវីការពារក្តីជនជាប់ ចោទ នួន ជា បានលើកឡើងថា អ្វីដែលក្រុមខ្លួនចង់បានសំខាន់បំផុតនៅក្នុងដំណើរការជំនុំជម្រះនៅក្នុងដំណាក់កាលទី២នោះ គឺការទទួលបានឱកាសពេញលេញក្នុងការផ្តល់ភស្តុតាងដោះបន្ទុក ដើម្បីគាំទ្រដល់ការការពារខ្លួនសម្រាប់ នួន ជា ។ ក្នុងន័យនេះ ក្រុមមេធាវីការពារក្តី នួន ជា ស្នើសុំដាក់បញ្ចូលការដ្ឋានត្រពាំងថ្ម មន្ទីរសន្តិសុខគិរីរម្យ ឬមន្ទីរសន្តិសុខវត្តធ្លក និងថា ការចោទប្រកាន់នានាអំពីគោលនយោ

បាយបោសសម្អាតផ្ទៃក្នុង និងការចោទប្រកាន់អំពីការជម្លៀសប្រជាជនដំណាក់កាលទី៣ គឺជាការចោទប្រកាន់សំខាន់បំផុត ។

### ខ) ប្រវត្តិនីតិវិធី

នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៣ អង្គជំនុំជម្រះតុលាការកំពូលចេញសេចក្តីសម្រេចចុងក្រោយ ទាក់ទងទៅនឹងការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ ។ តុលាការកំពូលបន្តាប់ថា *"[...] សំណុំរឿង០០២/០២ ត្រូវរួមបញ្ចូលជាអប្បបរមានូវបទចោទទាក់ទងនឹងមន្ទីរស-២១ ការដ្ឋានធ្វើការសហករណ៍ និងអំពើប្រល័យពូជសាសន៍"* ។ តាមរយៈសេចក្តីសម្រេចនេះ នៅថ្ងៃទី១១-១២ ខែធ្នូ ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកកិច្ចប្រជុំធំមួយ ដោយមានការចូលរួមពីគ្រប់ភាគីទាំងអស់នៃរឿងក្តី ដើម្បីពិភាក្សាអំពីការកំណត់វិសាលភាព និងកាលបរិច្ឆេទចាប់ផ្តើមជំនុំជម្រះសម្រាប់សំណុំរឿង០០២/០២ ។ នៅក្នុងកិច្ចប្រជុំនេះ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ការលើកឡើងដោយសង្ខេបរបស់ភាគីទាំងអស់អំពីទីតាំងឧក្រិដ្ឋកម្ម និងបទចោទប្រកាន់ ដែលត្រូវយកមកជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២ ។ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយ ដោយបន្តាប់ឲ្យភាគីទាំងអស់ដាក់សារណាជាលាយលក្ខណ៍អក្សរអំពីវិសាលភាពនៃសំណុំរឿង០០២/០២ ។ សារណាទាំងនោះមិនអនុញ្ញាតឲ្យមានការឆ្លើយតបណាមួយឡើយ ។[២៩] ភាគីទាំងអស់បានដាក់សារណាជូនអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ។ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបើកសវនាការស្តាប់ភាគីលើកឡើងដោយសង្ខេបអំពីសារណាទាំងនោះ ។

### គ) សំណើសុំរបស់សហព្រះរាជអាជ្ញា

ក្នុងការកំណត់វិសាលភាពសំណុំរឿង០០២/០២ សហព្រះរាជអាជ្ញាបានយោងទាំងស្រុងទៅលើសេចក្តីសម្រេចរបស់តុលាការកំពូល ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តុលាការកំពូលបានបន្តាប់ថា *"សំណុំរឿង ០០២/០២ ត្រូវរួមបញ្ចូលជាអប្បបរមានូវបទចោទទាក់ទងនឹងមន្ទីរស-២១ ការដ្ឋានធ្វើការសហករណ៍ និងអំពើប្រល័យពូជសាសន៍"* ។ យោងតាមសេចក្តីបន្តាប់នេះ សហព្រះរាជអាជ្ញាអះអាងថា មន្ទីរសន្តិសុខស-២១ (រួមទាំងជើងឯក) អំពើប្រល័យពូជសាសន៍លើជនជាតិចាម និងអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម ត្រូវតែយកមកជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២ ។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាស្នើសុំអង្គជំនុំជម្រះសាលាដំបូងលើកយកសហករណ៍ត្រាំកក់ និងការដ្ឋានទំនប់១មករា មកធ្វើការជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២ដែរ ។ សហព្រះរាជអាជ្ញាលើកឡើងថា សហករណ៍ត្រាំកក់ ជាសហករណ៍តែមួយគត់ ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង០០២ ។ ចំណែកការដ្ឋានទំនប់១មករា ជាការដ្ឋានមួយដែលតំណាងគម្រោងប្រព័ន្ធស្រោចស្រពខ្នាតធំ ដែលប្រជាជនកម្ពុជារាប់សែននាក់ ត្រូវបានបង្ខំឲ្យធ្វើការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។[៣០]

ទាក់ទងនឹងសហករណ៍ត្រាំកក់ សហព្រះរាជអាជ្ញាស្នើឲ្យដាក់បញ្ចូលមន្ទីរសន្តិសុខស្រុកត្រាំកក់ (ក្រាំងតាចាន់) ជាផ្នែកមួយនៃសំណុំរឿង០០២/០២ ។ សហព្រះរាជអាជ្ញាបានលើកឡើងថា មន្ទីរ សន្តិសុខនេះមានការចោទប្រកាន់ជាច្រើនទាក់ទងទៅនឹងការចាប់ខ្លួន ឃុំខ្លួន សួរចម្លើយ និងការធ្វើទារុណកម្មខ្លាំងនៅក្នុងស្រុកត្រាំកក់ ។ ការចោទប្រកាន់ទាំងនេះគាំទ្រចំពោះបទចោទប្រកាន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា ការដាក់នៅក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញខាងនយោបាយ និងការបាត់ខ្លួនដោយបង្ខំ ដែលចោទប្រកាន់ទៅលើជនជាប់ចោទ នួន ជា និង ខៀវ សំផន ។ សហព្រះរាជអាជ្ញាបញ្ជាក់បន្ថែមទៀតថា ឧក្រិដ្ឋកម្មនានាដែលទាក់ទងទៅនឹងការធ្វើបាបទៅលើពុទ្ធសាសនិកជន និងការរៀបការដោយបង្ខំក៏អាចធ្វើការជំនុំជម្រះតាមរយៈសហករណ៍ត្រាំកក់បានដែរ ។[៣១]

បន្ថែមពីលើអង្គហេតុ និងទីតាំងឧក្រិដ្ឋកម្មទាំង៥ ដូចដែលបានរៀបរាប់ខាងលើនេះ សហព្រះរាជអាជ្ញាស្នើដាក់ទីតាំងឧក្រិដ្ឋកម្មចំនួន៣បន្ថែមទៀតទៅក្នុងសំណុំរឿង០០២/០២ ។ ទីតាំងឧក្រិដ្ឋកម្មទាំងនោះរួមមាន ៖ ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល ។ សហព្រះរាជអាជ្ញាអះអាងថា ការដាក់បញ្ចូលបន្ថែមទីតាំងឧក្រិដ្ឋកម្មទាំងបីនេះ "អាចធ្វើឲ្យការជំនុំជម្រះក្តីទៅបានដោយឆាប់រហ័ស



ក្រុមអ្នកស្រាវជ្រាវ និងចងក្រងឯកសាររបស់រដ្ឋាភិបាលកម្ពុជា កំពុងប្រជុំគ្នាអំពីផែនការ



ស្រាវជ្រាវ និងការធ្វើញត្តិក្នុងទសវត្សរ៍៨០ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

និងអាចធ្វើឲ្យការជំនុំជម្រះក្តីវគ្គទីពីរនេះ មានតំណាងកាន់តែខ្លាំងច្រើនថែមទៀតនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង ០០២» ។[៣៧]

សរុបសេចក្តីមក នៅក្នុងសារណាជាលាយលក្ខណ៍អក្សររបស់ខ្លួន សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងលើកយកអង្គហេតុ និងទីតាំងឧក្រិដ្ឋកម្មសរុបទាំងអស់ ៨ មកជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២ ។ អង្គហេតុ និងទីតាំងឧក្រិដ្ឋកម្មទាំងនោះរួមមាន ៖ (១)មន្ទីរសន្តិសុខស-២១ ដែលក្នុងនោះរួមបញ្ចូលទាំងដើងឯក (២)ការប្រព្រឹត្តទៅលើជនជាតិវៀតណាម (លើកលែងឧក្រិដ្ឋកម្មនានា ដែលប្រព្រឹត្តដោយកងទ័ពបដិវត្តន៍កម្ពុជានៅលើទឹកដីប្រទេសវៀតណាម) (៣)ការប្រព្រឹត្តមកលើជនជាតិចាម (មិនរាប់បញ្ចូលការប្រព្រឹត្តនៅមន្ទីរសន្តិសុខក្រូចឆ្មារឡើយ) (៤)សហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ដោយរាប់បញ្ចូលទាំងការធ្វើបាបពុទ្ធសាសនិកជន និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (៥)ការដ្ឋានពលកម្មទំនប់១មករា (៦) ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង (៧)មន្ទីរសន្តិសុខអូរកន្សែង និង(៨)មន្ទីរសន្តិសុខភ្នំក្រោល ។

គួរបញ្ជាក់ថា នៅក្នុងសារណារបស់ខ្លួន សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការបំបែក ឬដកចេញនូវអង្គហេតុឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តន៍កម្ពុជានៅលើទឹកដីវៀតណាម (ដូចបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយពីកថាខណ្ឌទី៨៣២-៨៤០) ចេញពីសំណុំរឿង០០២/០២ ដោយផ្តល់ហេតុផលថា អង្គហេតុទាំងនោះមិនជាប់ទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាមដែលបានរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការចោទប្រកាន់ទាក់ទងនឹងមន្ទីរសន្តិសុខក្រូចឆ្មារ ក៏ត្រូវបានសហព្រះរាជអាជ្ញាស្នើឲ្យបំបែក ឬដកចេញពីសំណុំរឿង០០២/០២ដែរ ។[៣៣]

## ឃ) សំណើសុំរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សារណាជាលាយលក្ខណ៍អក្សរស្តីអំពីការកំណត់វិសាលភាពនៃសំណុំរឿង០០២/០២ ។ ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញជំហរគាំទ្រចំពោះវិសាលភាពនៃសំណុំរឿង០០២/០២ ដែលលើកឡើងដោយក្រុមសហព្រះរាជអាជ្ញា ប៉ុន្តែស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងពង្រីកវិសាលភាពនៃបទចោទប្រកាន់អំពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងការប្រព្រឹត្តចំពោះពុទ្ធសាសនិករហូតដល់វិសាលភាពទូទាំងប្រទេស ពោល គឺមិនត្រូវកម្រិតយកត្រឹមទីកន្លែងឧក្រិដ្ឋកម្មមួយចំនួននោះឡើយ ។ បន្ថែមលើនេះ សហមេធាវីដើមនាំមុខបណ្តឹងរដ្ឋប្បវេណីស្នើសុំឲ្យដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មចំនួនបី និងបទចោទប្រកាន់មួយបន្ថែមទៀត ទៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ ។ ទីតាំងឧក្រិដ្ឋកម្ម និងបទចោទប្រកាន់ទាំងនោះរួមមាន៖ ការដ្ឋានទំនប់ត្រពាំងថ្ម មន្ទីរសន្តិសុខភូមិភាគខត្តរ មន្ទីរសន្តិសុខកោះខ្យង និងការជម្លៀសប្រជាជន ដោយបង្ខំក្នុងដំណាក់កាលទី៣ (ដោយរួមបញ្ចូលទាំងការបោសសម្អាតដែលពាក់ព័ន្ធនៅភូមិភាគបូព៌ា) ។[៣៤]

### ឃ.១) ការដ្ឋានត្រពាំងថ្ម

ក្រុមមេធាវីដើម្បីបណ្តឹងរដ្ឋប្បវេណីស្នើឲ្យដាក់បញ្ចូល ការដ្ឋានទំនប់ត្រពាំងថ្ម នៅក្នុងសំណុំរឿង០០២/០២ ដោយបញ្ជាក់ថា ការដ្ឋាននេះ គឺបង្ហាញឲ្យឃើញអំពីការប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំ ដើម្បីសម្រេចទិសដៅនយោបាយ និងសេដ្ឋកិច្ចរបស់បក្សកុម្មុយនីស្តកម្ពុជា ។ លើសពីនេះទៀត ការដ្ឋានត្រពាំងថ្មបង្ហាញឲ្យឃើញអំពីភាពឧក្រិដ្ឋកម្មរួមមាន ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការបាត់ខ្លួនដោយបង្ខំ និងចំនួនជនរងគ្រោះដ៏ច្រើនសន្ធឹកសន្ធាប់ដែលរងគ្រោះដោយសារឧក្រិដ្ឋកម្មទាំងនេះ ។[៣៥] ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ការបង្ហាញភ័ស្តុតាងនៃអង្គហេតុឧក្រិដ្ឋកម្មដែលកើតនៅការដ្ឋាននេះនឹងចំណាយពេលប្រមាណ៤ថ្ងៃតែប៉ុណ្ណោះ ។

### ឃ.២) មន្ទីរសន្តិសុខភូមិភាគខត្តរ និងកោះខ្យង

សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំដាក់បញ្ចូលមន្ទីរសន្តិសុខបន្ថែមចំនួន ២ទៀត ទៅក្នុងសំណុំរឿង០០២/០២ ។ មន្ទីរសន្តិសុខទាំងនោះរួមមានមន្ទីរសន្តិសុខភូមិភាគខត្តរ និងមន្ទីរសន្តិសុខកោះខ្យង ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា មន្ទីរសន្តិសុខទាំងពីរនេះបើកឲ្យដំណើរការស៊ើរពេញ

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយអំពើឧក្រិដ្ឋដែលកើតឡើងនៅមន្ទីរសន្តិសុខទាំងពីរនេះ មានការជាប់ពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងគោលបំណងនៃការ«ការពារបក្ស ប្រឆាំងនឹងសត្រូវផ្ទៃក្នុងក៏ដូចជា សត្រូវខាងក្រៅ តាមគ្រប់មធ្យោបាយដែលចាំបាច់» ។ តាមការបញ្ជាក់របស់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងមន្ទីរសន្តិសុខទាំងពីរនេះមានលក្ខណៈធ្ងន់ធ្ងរ និងប៉ះពាល់ដល់ជនរងគ្រោះជាច្រើននាក់ ។ ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រូវការពេលវេលាចំនួន ៦ថ្ងៃប៉ុណ្ណោះក្នុងការបង្ហាញភស្តុតាងអំពីឧក្រិដ្ឋដែលកើតឡើងនៅមន្ទីរសន្តិសុខទាំងពីរនេះ ។[៣៦]

### ឃ.៣) ការផ្លាស់ទីលំនៅដោយបង្ខំនៅក្នុងដំណាក់កាលទីបី និងការបោស សម្អាតពាក់ព័ន្ធនឹងភូមិភាគបូព៌ា

ការផ្លាស់ទីលំនៅដោយបង្ខំនៅក្នុងដំណាក់កាលទីបី និងការបោសសម្អាតនៅភូមិភាគបូព៌ា ក៏ត្រូវបានក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដាក់បញ្ចូលនៅក្នុងសំណុំរឿង០០២/០២ដែរ ។ ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា អង្គហេតុទាំងនេះមានការជាប់ពាក់ព័ន្ធយ៉ាងខ្លាំង និងបំពេញបន្ថែមទៅលើភស្តុតាងស្តីអំពីមន្ទីរសន្តិសុខស-២១ ជាពិសេសការបោសសម្អាតកម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងភូមិភាគបូព៌ា សមាជិកកងទ័ពបដិវត្តន៍កម្ពុជា និងអ្នកដែលជាប់ពាក់ព័ន្ធជាមួយ សោ ភឹម លេខាភូមិភាគបូព៌ា ។ បន្ថែមលើនេះ អង្គហេតុទាំងនេះជាប់ពាក់ព័ន្ធទៅនឹងបទចោទប្រកាន់ស្តីអំពីការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញទៅលើអតីតអ្នកជាប់និន្នាការជាមួយរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី ព្រះសង្ឃពុទ្ធសាសនា ជនជាតិចាម ជនជាតិចិនខ្មែរកម្ពុជាក្រោម និងជនជាតិវៀតណាម ដោយមូលហេតុពូជសាសន៍ និងនយោបាយ ។ ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រូវការពេលវេលាចំនួន៩ថ្ងៃ ដើម្បីបង្ហាញភស្តុតាងអំពីអង្គហេតុទាំងនេះ ។

### ឃ.៤) ភាពមិនអាចទម្លាក់ចោលបាននៃទីតាំងឧក្រិដ្ឋកម្ម និងឬបទចោទប្រកាន់

ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញជំហរជំទាស់យ៉ាងខ្លាំង ចំពោះការប៉ុនប៉ង [របស់ភាគី ណាមួយ ឬអង្គជំនុំជម្រះ] ទម្លាក់ចោលនូវបទចោទប្រកាន់ ឬទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធចេញពីសំណុំរឿង០០២/០២ ។ បើយោងតាមការលើកឡើងរបស់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ការសម្រេចទម្លាក់ចោលបទចោទប្រកាន់ ឬទីតាំងឧក្រិដ្ឋកម្មណាមួយ នឹងធ្វើឲ្យប៉ះពាល់ដល់




កម្មាភិបាលខ្មែរក្រហមថតនៅមុខនាវាកងទ័ពជើងទឹករបស់ចិន នៅកំពង់ផែកំពង់សោម (បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

ផលប្រយោជន៍យុត្តិធម៌ និងប្រឆាំងទៅនឹងគោលការណ៍នានាដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា ។[៣៧] អំណះអំណាងរបស់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានយោងទៅលើមាត្រា៧ (ការរលត់នៃបណ្តឹងអាជ្ញា) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។ មាននេះចែងថា ៖ មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅ ៖

មរណភាពនៃជនល្មើស ។

ការផុតអាជ្ញាយុកាល ។

ការលើកលែងទោសជាទូទៅ ។

និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ។

អាជ្ញាអស់ជំនុំ ។

ដូច្នេះ អត្ថន័យនៃការលើកឡើងរបស់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគឺថា ការសម្រេចទម្លាក់ចោលបទចោទប្រកាន់ (ដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ) នឹងមិនអាចធ្វើទៅរួចឡើយ ប្រសិនបើពុំបានបំពេញតាមលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំង៥ខាងលើ ។ តាមរយៈមាត្រានេះ ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំអង្គជំនុំជម្រះសាលាដំបូងធ្វើការជំនុំជម្រះទៅលើបទចោទប្រកាន់ទាំងអស់ដែលមាននៅក្នុងសំណុំរឿង០០២ ពោលគឺពុំត្រូវទម្លាក់ចោលបទល្មើសណាមួយដែលបានចោទប្រកាន់រួចហើយ នៅក្នុងដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ ។

### ង) សំណើសុំរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន

នៅក្នុងសារណាជាលាយលក្ខណ៍អក្សររបស់ខ្លួន ក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន បានបង្ហាញជំហរជំទាស់យ៉ាងខ្លាំងចំពោះការប៉ុនប៉ងបំបែកបន្តទៀត នូវអង្គហេតុដែលនៅសេសសល់ក្នុងសំណុំរឿង០០២ ។[៣៨] មេធាវីលើកឡើងថា ការបំបែកនេះនឹងធ្វើឲ្យប៉ះពាល់សិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានការកាត់ទោសដោយយុត្តិធម៌ និងមិនអូសបន្លាយពេលវេលា ។[៣៩] មេធាវីការពារក្តីបានលើកយកការពិចារណារបស់តុលាការកំពូលដែលថា "សវនាការពីរបន្តបន្ទាប់គ្នា [...] ពិតជាត្រូវការចំណាយពេលវេលាច្រើនជាងសវនាការតែមួយ ដោយជៀសមិនរួចឡើយ"[៤០] និងសន្និដ្ឋានថា ការបន្តបំបែកសំណុំរឿង០០២ នឹងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះដោយពុំមានការអូសបន្លាយពេលវេលា ។ មេធាវីការពារក្តីលើកឡើងទៀតថា នីតិវិធីជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ មានភាពយឺតយ៉ាវ និងមានការលំបាកផ្នែកនីតិវិធី និងគតិយុត្ត ហើយបានឈានទៅដល់ កម្រិតធ្ងន់ធ្ងរមួយដែលនាំឲ្យ ខៀវ សំផន សុំឲ្យបញ្ចប់កិច្ចដំណើរការនីតិវិធីភ្លាមៗ ។[៤១] លើសពីនេះទៀត ការមិនកំណត់វិសាលភាពនៃសំណុំរឿង០០២/០១ ឲ្យបានច្បាស់លាស់ អវត្តមានក្របខណ្ឌច្បាប់អនុវត្តឲ្យបានច្បាស់លាស់ក្នុងការបង្ហាញភ័ស្តុតាង និងភាពស្រពិចស្រពិលទាំងស្រុងក្នុងការជ្រើសរើសអង្គហេតុ សម្រាប់យកមកជំនុំជម្រះ បានបណ្តាលឲ្យមានការរំលោភទៅលើសិទ្ធិរបស់ ខៀវ សំផន ។[៤២]

សរុបសេចក្តីមក ក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការជំនុំជម្រះទៅលើអង្គហេតុទាំងអស់ដែលនៅសល់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពោលគឺ សំណុំរឿង០០២/០២ គឺត្រូវក្តោបអង្គហេតុទាំងអស់ដែលនៅសល់ ។

### ច) សំណើសុំរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា

នៅក្នុងសំណើជាលាយលក្ខណ៍អក្សរ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា លើកឡើងថា ផលប្រយោជន៍ចម្បងរបស់ នួន ជា ទាក់ទិននឹងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង០០២/០២ គឺថា នួន ជា អាចមានឱកាសពេញលេញដើម្បីបង្ហាញភ័ស្តុតាងដោះបន្ទុកដែលគាំទ្រដល់ការការពារខ្លួន ។ មេធាវីការពារក្តីអះអាងថា "អង្គហេតុហួសពីវិសាលភាពចង្អៀតនៃបទចោទនៅក្នុងដីកាដំណោះស្រាយ គឺពាក់ព័ន្ធនឹងការបញ្ជាក់ការពិត" និងរិះគន់ថា ក្នុងអំឡុងពេលជំនុំជម្រះលើសំណុំរឿង០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់វិធីសាស្ត្រ "ចង្អៀតជ្រុលហួស ដើម្បីទទួលយកភ័ស្តុតាងដែលស្ថិត នៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ និងជាទូទៅស្ថិតនៅក្រៅដីកាដំណោះស្រាយ" ។[៤៣] ក្នុងន័យនេះ ក្រុមមេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកភ័ស្តុតាង ឬបើកឲ្យសួរដេញដោលសាក្សីបានទូលំទូលាយជាងមុន និងជៀសវាងការដកចេញភ័ស្តុតាង

ណាមួយ ឬសាក្សីណាម្នាក់ ដោយសារមូលហេតុ«មិនជាប់ទាក់ទងដោយផ្ទាល់ទៅនឹងទីកន្លែងឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងវិសាលភាពនៃការជំនុំជម្រះនោះទេ» ។ ភស្តុតាងទាំងអស់ ត្រូវតែទទួលយកជាបឋម ក្នុងករណីភស្តុតាងទាំងនោះមានការជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុណាមួយនៃដីកាដំណោះស្រាយ ។[៤៤]

ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា លើកឡើងទៀតថា ការចងសម្ព័ន្ធរវាងកងកម្លាំង ភូមិភាគពាយ័ព្យ និងភូមិភាគបូព៌ា ដើម្បីប្រឆាំងនឹង ប៉ុល ពត និងនួន ជា និងតួនាទីរបស់រដ្ឋាភិបាលវៀតណាមក្នុងការគាំទ្រការប្រឆាំងនេះ គឺជាអង្គហេតុដែលចាំបាច់សម្រាប់ នួន ជា ការពារខ្លួន។ បន្ថែមលើនេះ ការដ្ឋានទំនប់ត្រពាំងថ្ម មន្ទីរសន្តិសុខវត្តគីរីរម្យ មន្ទីរសន្តិសុខវត្តធ្លក គោលការណ៍បោសសម្អាតផ្ទៃក្នុង និងការជម្លៀសប្រជាជនដំណាក់កាលទី៣ គឺជាបទចោទសំខាន់បំផុតដែលទាក់ទងទៅនឹងអំពើឧក្រិដ្ឋកម្មដែលកើតនៅភូមិភាគបូព៌ា និងភូមិភាគឧត្តរ ។[៤៥]

## ២) អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម និង ចាម

### ក) និយមន័យ

អំពើប្រល័យពូជសាសន៍ គឺជាការប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើខាងក្រោម ហើយដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយដូចជា ៖ ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម ការធ្វើឲ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញាសមាជិកក្រុម ការធ្វើដោយចេតនាឲ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅមួយ ដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬមួយផ្នែក ការដាក់នូវវិធានការនានាដែលមានបំណងរារាំងមិនឲ្យមានការផ្តល់កំណើតទារក ការបញ្ជូនកុមារដោយបង្ខំពីក្រុមមួយទៅឲ្យក្រុមមួយផ្សេងទៀត ។[៤៦]

នៅក្នុងដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ ជនជាប់ចោទ នួន ជា និងខៀវ សំផន ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍លើជនជាតិចាម និងជនជាតិវៀតណាម ។ ជនជាប់ចោទទាំងពីររូបនេះទទួលរងការចោទប្រកាន់ថា «បានប្រព្រឹត្ត (ដោយបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម) រៀបចំផែនការញុះញង់ឲ្យប្រព្រឹត្តបញ្ជា ឲ្យមានការប្រព្រឹត្តនូវឧក្រិដ្ឋកម្ម បានជួយនិងជំរុញដល់អ្នកចារី ឬត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ» នូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការសម្លាប់សមាជិកក្រុមចាម និងវៀតណាម ក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។[៤៧]

### ១) ការប្រព្រឹត្តទៅលើជនជាតិវៀតណាម

ដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះបានចោទប្រកាន់ថា ចាប់ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៩ ប្រជាជនស៊ីវិលវៀតណាមដែលរស់នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង ទទួលរងការសម្លាប់រង្គាល ។[៤៨] ក្រៅពីខេត្តព្រៃវែង និងស្វាយរៀង ជនជាតិវៀតណាមក៏ត្រូវបានសម្លាប់រង្គាល ដែរនៅខេត្តសៀមរាប ។ នៅចុងឆ្នាំ១៩៧៨ ប្រជាជនវៀតណាមរស់នៅក្នុងស្រុកស្វាយលើ និងស្រុកជីក្រែង ត្រូវបានចាប់យកទៅសម្លាប់នៅវត្តខ្សាច់ ភូមិយាង ឃុំបុស្សីលក ខេត្តសៀមរាប ។[៤៩] ប្រជាជនវៀតណាមក៏ត្រូវបានសម្លាប់ដែរនៅខេត្តបាត់ដំបង ពោធិ៍សាត់ មណ្ឌលគិរី ក្នុងតំបន់ស្វយ័ត១០៥ កំពត តាកែវ ក្រចេះ ក្នុងតំបន់ស្វយ័ត ៥០៥ កោះកុងក្នុងភូមិភាគបស្ចិម និងស្រុកក្រូចឆ្មារ និងស្រុកខ្សាច់កណ្តាល ។[៥០]

នៅក្នុងដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ ក៏លើកឡើងដែរអំពីគោលនយោបាយក្នុងការសម្លាប់ជនជាតិវៀតណាម ដោយបញ្ជាក់ថា «ប្រសិនបើបុរសជនជាតិវៀតណាម រៀបការជាមួយស្ត្រីខ្មែរ គឺមានតែបុរសទេដែលត្រូវបានយកទៅសម្លាប់ ចំពោះប្រពន្ធ និងកូនត្រូវបានទុកជីវិត។ ប៉ុន្តែ ប្រសិនបើស្ត្រីជាជនជាតិវៀតណាមបានរៀបការជាមួយនឹងបុរសខ្មែរ ប្រពន្ធ និងកូននោះ នឹងត្រូវយកទៅសម្លាប់ចោល ចំណែកប្តីត្រូវបានទុកជីវិត» ។[៥១]

តាមរយៈទស្សនាវដ្តីទង់បដិវត្តន៍ចេញ ខែមេសា ឆ្នាំ១៩៧៧ ដីកាដំណោះស្រាយ ចោទប្រកាន់ ថាបក្សកុម្មុយនីស្តកម្ពុជាបាន «អំពាវនាវដោយផ្ទាល់ ដើម្បីសម្លាប់រាល់សមាជិកនៃសហគមន៍ប្រជាជនវៀតណាមដែលនៅសេសសល់ក្នុងប្រទេសកម្ពុជា» ។ តាមរយៈទស្សនាវដ្តីនេះ សហចៅក្រមស៊ើបអង្កេតអះអាងថា បក្សកុម្មុយនីស្តកម្ពុជាបានប្រើពាក្យជារួមដើម្បី «រកខ្មាំង[...] ពិនិត្យខ្មាំង[...] វិភាគខ្មាំង[...] តាមដានខ្មាំង[...] កៀបសង្កត់ខ្មាំង[...] ចាប់

ខ្លាំង[...] និងកម្ទេចខ្មាំង» ។ ទស្សនាវដ្ដីនេះ ក៏បានបញ្ជាក់ដែរ “បញ្ហាមួយដែលត្រូវយកចិត្តទុកដាក់សំខាន់ណាស់ដែរ គឺវែកមុខពួក ស.អ.អ និងភ្នាក់ងាររបស់វាពួក ក.ស.ប និងភ្នាក់ងាររបស់វាពួកយ (វៀតណាម) លេបទឹកដី និងផ្នែបម្រើរបស់វាឲ្យច្បាស់ និងជាបន្ដបន្ទាប់ក្នុងបក្សទាំងមូល កងទ័ពទាំងមូល និងប្រជាជនទាំងមូល វាយផ្ដាច់ខ្មាំងនយោបាយ កុំឲ្យវាមកលបចូលបានក្នុងបក្សរបស់យើង កងទ័ពរបស់យើង និងប្រជាជនរបស់យើងជារៀងរហូត ។ ឯបុសចាស់របស់វាដែលនៅសេសសល់ខ្លះក្រោយពីយើងកម្ចាត់ឲ្យវាខ្ទេចខ្ទីនេះ គឺត្រូវបំផុសមហាជនឲ្យគេបោសសម្អាតវាថែមទៀតឲ្យស្អាតជាស្ថាពរ» ។[៥៧]

សហចៅក្រមស៊ើបអង្កេតក៏បានយោងផងដែរទៅលើព្រះរាជសាររបស់សម្ដេចព្រះបាទ នរោត្ដម សីហនុ (បោះពុម្ពផ្សាយក្នុងឆ្នាំ២០០៦) ដែលបានផ្ដល់ព័ត៌មានលម្អិតទាក់ទងទៅនឹងកិច្ចប្រជុំមួយដែលព្រះអង្គបានចូលរួមប្រជុំជាមួយ ប៉ុល ពត នៅដំណាក់កាលចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ព្រះរាជសារនេះរៀបរាប់ពី ប៉ុល ពត ដែលបានប្រាប់មកព្រះអង្គថា “ប្រទេសកម្ពុជារបស់យើងនឹងមិនបានសុខសាន្តទេ ដរាបណាយើងជាជនជាតិកម្ពុជានៅមិនទាន់បានកម្ទេចបោលនូវកំពូជយួនក៏អាក្រក់នេះ ។ ខ្ញុំបានចាប់ផ្ដើមបញ្ជូនកងទ័ពយើងទៅកម្ពុជាក្រោម (កូសាំងស៊ីន) ក្នុងបេសកកម្មដើម្បីសម្លាប់ឲ្យបានច្រើនជាអតិបរមានូវ បុរស ស្ដ្រី និងកុមារ របស់កំពូជយួនដ៏អាក្រក់បំផុតនេះ ។ ក៏ប៉ុន្ដែថា (យើង) មិនអាចកម្ទេចពួកវាចោលទាំងស្ដ្រី ទាំងបុរសឲ្យអស់ពីក្នុងប្រទេសរបស់ពួកវាបានទេ ។ នៅតំបន់អណ្ណាម និងតុងកឹង គឺនៅមានប្រជាជនវារាប់សិបលាននាក់នៅឡើយ ។ ដូច្នេះ ខ្ញុំក៏បានសម្រេចចិត្តផ្លាស់ប្ដូរយុទ្ធសាស្ដ្រ និងកលល្បិច ។ គឺ (ផ្លាស់ប្ដូរ) ទាំងស្រុងតែម្ដង ។ (គឺ) ខ្ញុំបញ្ឆោតពួកវាឲ្យចូលមកស្រុកយើង ដោយធ្វើយ៉ាងណាឲ្យពួកវាជឿយ៉ាងស៊ប់ថា ពួកវាពិតជាទទួលបានជ័យជម្នះតាមមធ្យោបាយយោធា ។ ដល់ពេលណាពួកវាបានចូលមកដល់កម្ពុជាប្រជាធិបតេយ្យហើយ យើងជាប្រជាជនកម្ពុជាទាំងប្រុស ទាំងស្រី នឹងកាប់ពួកវាជាដុំតូចៗ និងហាន់ពួកវាជាកង់ៗ ។ នៅវៀតណាមពួកវាគ្មានផ្លូវថានឹងបានឃើញទាហាន ពួកវាត្រឡប់ទៅស្រុកវាវិញឡើយ ហើយពួកវាពិតជានឹងបញ្ជូនកងពលជាច្រើនមករកយើងទៀត ហើយយើងជាប្រជាជនកម្ពុជានឹងបន្ដហាន់ពួកវាជាកង់ៗ ។ ហើយដល់ដំណាក់កាលចុងក្រោយ បន្ទាប់ពីមានការរំដោះកម្ពុជាក្រោមរបស់យើងរួច យើងនឹងធ្វើដំណើរទៅកាន់ប្រទេសរបស់ពួកវាគឺទៅអណ្ណាម និងទៅឲ្យដល់តុងកឹងទៀត ដែលការធ្វើដូច្នេះគឺដើម្បីកាប់សម្លាប់ប្រពន្ធ និងកូនរបស់ពួកវា(ក្មេងប្រុសស្រី និងទារក) ។ ហេតុដូចនេះ



កងយោធាខ្មែរក្រហមបោសសម្អាត និងដេញដេរលំនៅដ្ឋានក្នុងទីក្រុងភ្នំពេញ ក្រោយខ្មែរក្រហមទទួលជ័យជម្នះ

កំពូជយួនក៏អាក្រក់បំផុត នឹងវិនាសបាត់បង់ពីផ្ទៃផែនដីនេះ" ។ គួរបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតបានផ្តល់ការកត់សម្គាល់ថា ព្រះរាជសារនេះនឹងមានទម្ងន់ជាភស្តុតាងបាន លុះត្រាតែមានសក្ខីកម្មដែលមានទម្រង់ជាកំណត់ហេតុស្តាប់ចម្លើយ ។

សហចៅក្រមស៊ើបអង្កេតរកឃើញទៀតថា "ចាប់ពីឆ្នាំ១៩៧៧ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើននូវការឃោសនាញុះញង់ឲ្យស្អប់ប្រជាជនវៀតណាម ។ បក្សកុម្មុនីស្តកម្ពុជាបានឃោសនាថា វៀតណាម គឺជាពួកជនវាតទីកដីឈ្លានពាន ឃោរឃៅសាហាវ ដណ្តើមទឹកដី លេបទឹកដី មានបំណងត្រួតត្រាកម្ពុជា ដើម្បីលេបត្របាក់ប្រជាជាតិ ប្រជាជន និងទឹកដីកម្ពុជាយើងទាំងមូល ។ បក្សកុម្មុយនីស្តកម្ពុជាបានញុះញង់ បញ្ឆេះភាពស្អប់ខ្ពើមដែលពោរពេញទៅដោយភាពឈឺចាប់ ប្រឆាំងទៅនឹង ប្រជាជនវៀតណាម និងបានជំរុញឲ្យកម្មាភិបាលបន្តការញុះញង់នូវភាពស្អប់ខ្ពើមនេះនៅក្នុងស្រទាប់ប្រជាជន" ។[៥៣]

### ក) ការប្រព្រឹត្តទៅលើជនជាតិចាម

នៅក្នុងដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះបានបញ្ជាក់ថា មានសាក្សីជាច្រើននាក់ផ្តល់សក្ខីកម្មថា ជនជាតិចាមត្រូវបានបង្ខំឲ្យបរិភោគសាច់ជ្រូក ។ អ្នកដឹកនាំសាសនា និងអ្នករៀនចេះដឹងសាសនាឥស្លាមជ្រៅជ្រះត្រូវបានចាប់ខ្លួន និងសម្លាប់ចោល ។ ស្ត្រីជនជាតិចាមត្រូវបានគេបង្ខំឲ្យកាត់សក់ និងហាមឃាត់មិនឲ្យយកក្រមាគ្របក្បាល ។ ភាសា សម្លៀកបំពាក់ និងប្រពៃណីចាមត្រូវបានហាមឃាត់ ។[៥៤] សាក្សីជាច្រើនទៀតបានផ្តល់សក្ខីកម្មថា នៅក្នុងឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ ប្រជាជនចាមត្រូវបានសម្លាប់រង្គាលនៅភូមិភាគកណ្តាល និងភូមិភាគបូព៌ា ។[៥៥] សាក្សីម្នាក់ទៀតបានរៀបរាប់ថា រូបគាត់ត្រូវបានហៅឲ្យទៅប្រជុំនៅឆ្នាំ១៩៧៧ ក្នុងភូមិបុសខ្នុរស្រុកចំការលើ ខេត្តកំពង់ចាម តំបន់៤១ ភូមិភាគកណ្តាល(ភូមិភាគឧត្តរចាស់) ។ កិច្ចប្រជុំនេះធ្វើឡើងដើម្បីរៀបចំផែនការកម្ទេចខ្មាំង ។ ក្នុងអំឡុងពេលនោះប្រធានអង្គប្រជុំបានប្រកាសថា "ខ្មាំងរបស់បដិវត្តន៍មានច្រើន ប៉ុន្តែខ្មាំងដែលធំជាងគេរបស់យើងគឺ ចាម ។ ដូច្នេះផែនការនេះអំពាវនាវឲ្យមានការកម្ទេចជនជាតិចាមឲ្យអស់មុនឆ្នាំ១៩៨០ ។ បន្ថែមលើនេះ សាក្សីដដែលនេះបានឃើញសៀវភៅមួយមានចំណងជើងថា "ផែនការសម្រាប់សហករណ៍ជឿនលឿន" ដែលក្នុងនេះបានលើកឡើងថា "ចាម គឺជាខ្មាំងដែលធំជាងគេ ហើយត្រូវកម្ទេចឲ្យអស់មុនឆ្នាំ១៩៨០" ។[៥៦] សាក្សីម្នាក់ទៀតបានផ្តល់សក្ខីកម្មថា នៅឆ្នាំ១៩៧៧ មានកម្មាភិបាលសន្តិសុខមកពីតំបន់២១ (ភូមិភាគបូព៌ា) បានប្រាប់គាត់ថា "ទៅថ្ងៃមុខពួកចាមដែលនៅសេសសល់នឹងត្រូវសម្លាប់ទាំងអស់" ។[៥៧] សាក្សីម្នាក់ទៀតបានរៀបរាប់ថា ចុងឆ្នាំ១៩៧៨ មានការប្រជុំរវាង កែ ពក និងលេខាស្រុកនៃភូមិភាគបូព៌ា និងភូមិភាគកណ្តាល ។ នៅក្នុងកិច្ចប្រជុំនោះ កែ ពក បានសួរទៅកាន់លេខាស្រុកក្រូចឆ្មារថា "គម្រោងដែលដាក់ជូនដោយបក្ស តើបានបញ្ចប់ប៉ុន្មានភាគរយហើយ? ...សមមិត្តត្រូវតែកម្ទេចពួកចាមដែលស្ថិតក្នុងកងចល័តមុន ព្រោះពួកគេទាំងនោះសុទ្ធតែជាជនក្បត់ជាតិ" ។[៥៨] ជនជាតិចាមត្រូវបានសម្លាប់រង្គាលនៅស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។[៥៩] សាក្សីម្នាក់ទៀត បានបញ្ជាក់ថា ប្រជាជនចាមរស់នៅភូមិសំបូរមាស និងភូមិសាច់សូ ស្រុកកងមាស ខេត្តកំពង់ចាម មានទាំងបុរស ស្ត្រី និងកុមារ ប្រមាណ៣០០នាក់ ក៏ត្រូវបានចាប់ខ្លួន និងយកទៅសម្លាប់ចោលដែរ ។[៦០] សាក្សីជាច្រើនទៀតបានរៀបរាប់ថា ជនជាតិចាមត្រូវបានបំបែកចេញពីជនជាតិខ្មែរ បន្ទាប់មកយកទៅសម្លាប់ចោល ។[៦១]



(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើវិសាលភាពសំណុំរឿង០០២/០២

### ឌី សុជាតា

នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសេចក្ដីប្រកាសព័ត៌មានរបស់ខ្លួនដោយបញ្ជាក់ពីការកំណត់វិសាលភាពលើសំណុំរឿង០០២/០២ ដែលបានបំបែកចេញពីដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ ។ ការកំណត់វិសាលភាពនេះ ធ្វើឡើងបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់កិច្ចដំណើរការនីតិវិធីរបស់ខ្លួនលើសំណុំរឿង០០២/០១ ដែលសព្វថ្ងៃកំពុងរង់ចាំការចេញសាលក្រមដោយអង្គជំនុំជម្រះសាលាដំបូង ។ នេះគឺជាការចេញសេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីថ្មីមួយ ដោយកំណត់ទីតាំងឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់តាមអង្គហេតុ ដែលនឹងត្រូវដាក់បញ្ចូលដើម្បីយកមកជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ ប្រឆាំងនឹងជនជាប់ចោទពីររូបគឺ នួន ជា និងខៀវ សំផន ។

ការចោទប្រកាន់នៅក្នុងដំណាក់កាលនេះ រួមមានអំពើប្រល័យពូជសាសន៍ ការរៀបការដោយបង្ខំ និងអំពើរំលោភសេពសន្ថវៈ ការប្រព្រឹត្តលើពុទ្ធសាសនិកជន ការបោសសម្អាតផ្ទៃក្នុងបក្ស ការប្រព្រឹត្តជាក់លាក់លើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មន្ទីរសន្តិសុខចំនួនបួន ការដ្ឋានការងារចំនួនបី និងសហករណ៍ចំនួនមួយគឺជាមូលដ្ឋានសម្រាប់ការជំនុំជម្រះនៃសំណុំរឿង ០០២/០២ ។ ដើម្បីកំណត់វិសាលភាពនេះបានអង្គជំនុំជម្រះសាលាដំបូងបានពិចារណាទៅលើលក្ខខណ្ឌនានា ដែលតម្រូវឲ្យមានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស ព្រមទាំងជាតំណាងសមស្របនៃដីកាដំណោះស្រាយទាំងមូល ។ ក្រោយពីបានពិចារណាទៅលើសេចក្ដីសន្និដ្ឋានស្នើសុំរបស់ភាគីនានានៃរឿងក្ដី អង្គជំនុំជម្រះសាលាដំបូង បានសម្រេចយកទីតាំងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងការចោទប្រកាន់តាមអង្គហេតុខាងក្រោមនេះ មកធ្វើជាមូលដ្ឋានសម្រាប់ការជំនុំជម្រះនៃសំណុំរឿង ០០២/០២ ដូចតទៅ ៖

- អំពើប្រល័យពូជសាសន៍ចំពោះជនជាតិចាម និងវៀតណាម (ដោយមិនរាប់បញ្ចូលបទឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ ដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តន៍កម្ពុជាក្នុងទឹកដីវៀតណាម)
- ការរៀបការដោយបង្ខំ និងអំពើរំលោភសេពសន្ថវៈ (ទូទាំងប្រទេស)
- ការបោសសម្អាតផ្ទៃក្នុង
- មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខភ្នំក្រោល
- ការដ្ឋានទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម
- សហករណ៍ត្រាំកក់
- ការប្រព្រឹត្តចំពោះពុទ្ធសាសនិកជន (កម្រិតតែសហករណ៍ត្រាំកក់)
- ការប្រព្រឹត្តជាក់លាក់លើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (ដែលអនុវត្តកម្រិតតែសហករណ៍ត្រាំកក់ ការដ្ឋានទំនប់១មករា មន្ទីរសន្តិសុខក្រាំងតាចាន់) ។

នៅក្នុងសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងក៏បានលើកឡើងពីការសម្រេចលើការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីថា ភាគីសហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីគាំទ្រការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម ។ ប៉ុន្តែ មេធាវីការពារក្ដី ខៀវ សំផន បានជំទាស់មិនឲ្យមានការបំបែកកិច្ចដំណើរការនីតិវិធីណាមួយបន្ថែមទៀតឡើយ ។ ចំណែកមេធាវីការពារក្ដី នួន ជា ពុំបានបង្ហាញជំហរគាំទ្រ ឬជំទាស់ទេ ប៉ុន្តែបានស្នើសុំឲ្យបញ្ចូលទីតាំងឧក្រិដ្ឋកម្មជាក់លាក់បន្ថែមក្នុងករណីមានការបំបែកកិច្ចដំណើរការនីតិវិធី ។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើង

អំពីការចង្អុលបង្ហាញរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសេចក្ដីសម្រេចកាលពីពេលមុនថា បទចោទនិងទីតាំងឧក្រិដ្ឋកម្មដែលត្រូវបញ្ចូលក្នុងសំណុំរឿង០០២/០២ យ៉ាងហោចណាស់គួរដាក់បញ្ចូលមន្ទីរស-២១ ការដ្ឋានការងារសហករណ៍ និងបទល្មើសប្រល័យពូជសាសន៍ ។ ទោះជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងពុំបានសម្រេចជាមុនថាតើការបំបែកកិច្ចដំណើរការនីតិវិធីចំពោះការចោទប្រកាន់ដែលនៅសេសសល់ក្នុងសំណុំរឿង០០២ ជាការចាំបាច់ឬយ៉ាងណាទេ បន្ទាប់ពីសំណុំរឿង០០២/០១ បានបញ្ចប់ ។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងត្រូវពិនិត្យនូវកត្តាទាំងអស់ដែលពាក់ព័ន្ធ ដើម្បីសម្រេចថាតើមានការចាំបាច់ ដែរឬទេ ក្នុងការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមទៀត ។ អង្គជំនុំជម្រះសាលាដំបូងក៏បានលើកឡើងអំពីសិទ្ធិរបស់ជនជាប់ចោទរួមមានសិទ្ធិទទួលបានការជំនុំជម្រះដោយមិនពន្យារពេលឥតប្រយោជន៍ និងលទ្ធភាពរបស់ជនជាប់ចោទក្នុងការចូលរួមការរៀបចំការពារខ្លួនក្នុងសវនាការបន្តបន្ទាប់ ។ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា វិសាលភាពនៃសំណុំរឿង០០២/០២ ត្រូវមានទីតាំងឧក្រិដ្ឋកម្ម និងបទចោទនានា ដែលត្រូវស្នើសុំដោយការិយាល័យសហព្រះរាជអាជ្ញា ។ គួររំឭកថា សំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលស្នើឲ្យពង្រីកទីតាំងឧក្រិដ្ឋកម្មនិងបទចោទនានានោះ បានឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវីការពារក្ដី នួន ជា និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហើយក៏បានអនុញ្ញាតឲ្យបញ្ចប់សវនាការក្នុងថិរវេលាមួយសមស្របដែរ ។ សំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា បានបញ្ចូលនូវការចោទប្រកាន់អំពីការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈ ។ មេធាវីការពារក្ដី នួន ជា ពុំបានជំទាស់ទៅនឹងការស្នើសុំរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីឲ្យពង្រីកវិសាល



ផ្សារធំថ្មីក្នុងរបបខ្មែរក្រហម (បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

ភាពនៃការចោទប្រកាន់អំពីការរំលោភសេពសន្ថវៈ និងការរៀបការដោយបង្ខំ នៅក្នុងក្របខណ្ឌទូទាំងប្រទេស ដោយតម្រូវឲ្យបន្ថែមការស្តាប់សក្ខីកម្មសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ។ អង្គជំនុំជម្រះយល់ស្របចំពោះសំណើនេះដោយយល់ឃើញថា នេះជាអាទិភាពទីមួយនៃក្រុមដើមបណ្តឹងរដ្ឋប្បវេណី ហើយការឯកភាពតាមសំណើតែមួយ នេះនឹងនាំឲ្យមានការពង្រីកវិសាលភាពនៃសំណុំរឿង០០២/០២ តិចតួចប៉ុណ្ណោះ ។ មេធាវីការពារក្តី នួន ជា ស្នើសុំឲ្យបញ្ចូលទីតាំងឧក្រិដ្ឋកម្ម និងអង្គហេតុចោទប្រកាន់បន្ថែមទៀត ជាពិសេសទីតាំងឧក្រិដ្ឋកម្មនៅភូមិភាគបូព៌ា ភូមិភាគឧត្តរ និងការដ្ឋានទំនប់ត្រពាំងថ្ម ។ ចំពោះទីតាំងទាំងនេះក៏ត្រូវសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដែរ ដោយផ្អែកលើអំណះអំណាងថាវាផ្តល់នូវភាពជាតំណាងភូមិសាស្ត្រសម្រាប់ភូមិភាគពាយ័ព្យ និងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ដែលមានកម្រិតខ្ពស់ ។ អង្គជំនុំជម្រះយល់ស្របដោយពិចារណាលើផលប្រយោជន៍យុត្តិធម៌ ។ ស្របគ្នានឹងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តី នួន ជា ក៏ស្នើសុំបញ្ចូលការចោទប្រកាន់ស្តីពីការបោសសម្អាតផ្ទៃក្នុងនៅក្នុងវិសាលភាពសំណុំរឿង០០២/០២ ដែរ ។ ដោយពិចារណាថា ក្រុមមេធាវីការពារក្តី នួន ជា កំណត់ការបញ្ចូលការចោទប្រកាន់ទាំងនេះថា មានសារសំខាន់បំផុតសម្រាប់ផលប្រយោជន៍ជនជាប់ចោទ ហើយថាការទទួលយកសំណើនេះ នឹងមិនចំណាយពេលសវនាការច្រើនទេ អង្គជំនុំជម្រះទទួលយកសំណើសុំនេះ ។ ការបោសសម្អាតផ្ទៃក្នុងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនៅនឹងការចោទប្រកាន់ពីការជម្លៀសប្រជាជនដោយបង្ខំ ហេតុនេះការបញ្ចូលការចោទប្រកាន់ទាំងនេះឆ្លុះបញ្ចាំងពីខ្លឹមសារទូលំទូលាយជាងមុននៃដីការដំណោះស្រាយ ។

អង្គជំនុំជម្រះបានសម្រេចបដិសេធសំណើសុំរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឲ្យបន្ថែមមន្ទីរសន្តិសុខភូមិភាគឧត្តរ និងមន្ទីរសន្តិសុខកោះខ្យង និងសំណើសុំរបស់មេធាវីការពារក្តី នួន ជា ស្នើសុំឲ្យបន្ថែមមន្ទីរសន្តិសុខវត្តគិរីរម្យ និងមន្ទីរសន្តិសុខវត្តធ្លក ។ ការបដិសេធនេះ ដោយហេតុថា អង្គជំនុំជម្រះមានជំនឿថា ការបញ្ចូលទីតាំងទាំងនេះ នឹងប៉ះពាល់ដល់ប្រសិទ្ធភាព និងភាពគ្រប់គ្រងបានដែលកើតឡើងដោយការជ្រើសរើសបំបែកកិច្ចដំណើរការនីតិវិធីសវនាការសំណុំរឿង០០២ តាំងពីដំបូងម្លេះ ដោយមិនបានទទួលផលប្រយោជន៍ទៅតាមអ្វីដែលភាគីចង់បាន ។ អង្គជំនុំជម្រះបានបដិសេធការស្នើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលសំណើនេះយល់ស្របដោយមេធាវីការពារក្តី នួន ជា ដែរនោះ គឺស្នើសុំឲ្យដាក់បញ្ចូលការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំក្នុងដំណាក់កាលទីបី ទៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ ។ អង្គជំនុំជម្រះផ្តល់ហេតុផលថា ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំត្រូវបានយកមកដេញដោលយ៉ាងទូលំទូលាយរួចមកហើយ នៅក្នុងសំណុំរឿង០០២/០១ ។ ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីបីនឹងត្រូវលើកយកមកពិចារណាក្នុងសំណុំរឿង០០២/០២ តាមរយៈការបញ្ចូលមន្ទីរស-២១ និងការបោសសម្អាតផ្ទៃក្នុងដែលនឹងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី៣នេះ ។

អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ពីការប៉ាន់ប្រមាណពេលវេលារបស់សហព្រះរាជអាជ្ញា ដែលថា សវនាការលើអង្គហេតុនានា នៅក្នុងសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញាដែលត្រូវបានពង្រីកនោះនឹងត្រូវចំណាយពេលពីរទៅបីឆ្នាំទើបចប់ ។ ការណ៍ដែលអង្គជំនុំជម្រះសាលាដំបូងបន្ថែម ទីតាំងឧក្រិដ្ឋកម្មថែមទៀត នឹងមិនបន្ថែមពេលវេលាច្រើនទៀតដល់ការប៉ាន់ប្រមាណនេះទេ ។ ទោះបីអង្គជំនុំជម្រះសាលាដំបូង មិនអាចផ្តល់ការប្រមាណច្បាស់លាស់ចំពោះថិរវេលានៃកិច្ចដំណើរការនីតិវិធីដែលនឹងត្រូវចំណាយបន្ទាប់ពីមានការបំបែកកិច្ចដំណើរការនីតិវិធីសវនាការក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា អង្គជំនុំជម្រះអាចដំណើរការសវនាការចំពោះអង្គហេតុដែលបានចោទប្រកាន់ដូចដែលបានលើកឡើងក្នុងថិរវេលាមួយដ៏សមស្របបាន ។

អង្គជំនុំជម្រះសាលាដំបូងនឹងបង្គាប់ឲ្យភាគីទាំងអស់ ដាក់បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងបញ្ជីឯកសារភស្តុតាង ដែលភាគីមានបំណងស្នើសុំដាក់បញ្ចូលសម្រាប់ជំនុំជម្រះក្នុងសំណុំរឿង០០២/០២ ។ អង្គជំនុំជម្រះសាលាដំបូងនឹងកំណត់កាលបរិច្ឆេទរបស់សវនាការបឋមសម្រាប់សំណុំរឿង០០២/០២ បន្ទាប់ពីបានទទួលបញ្ជីទាំងនោះរួចរាល់ ។

# អង្គជំនុំជម្រះសាលាដំបូងសម្រេចចាត់តាំងអ្នកជំនាញឱ្យពិនិត្យសម្បទារបស់ជនជាប់ចោទសាជាថ្មី

**នួន ឡៃហុល**

នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា និងខៀវ សំផន ដាក់សារណាខ្លីមួយអំពីបញ្ហាសុខភាពកូនក្តីរបស់ខ្លួនក្នុងការចូលរួមសវនាការ ។ អង្គជំនុំជម្រះបង្គាប់ឲ្យក្រុមមេធាវីការពារក្តីចង្អុលបង្ហាញថា តើស្ថានភាពសុខភាពកូនក្តីរបស់ខ្លួន មានការប្រែប្រួលដែរ ឬទេរហូតមកដល់ពេលបច្ចុប្បន្ននេះ? តើការវាយតម្លៃឡើងវិញអំពីសម្បទារបស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន ក្នុងការចូលរួមសវនាការមានភាពចាំបាច់ដែរឬទេ? និងថា តើជនជាប់ចោទ នួន ជា និង ខៀវ សំផន អាចមានលទ្ធភាពចូលរួមសវនាការតាមកាលបរិច្ឆេទដូចបានគ្រោងទុកដែរឬទេ?

នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ដាក់សារណាជូនអង្គជំនុំជម្រះសាលាដំបូងដោយស្នើសុំឲ្យមានការវាយតម្លៃយ៉ាងល្អិតល្អន់ទៅលើស្ថានភាពសុខភាព និងសមត្ថភាពរបស់ នួន ជា ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីសវនាការ ។ មេធាវីការពារក្តីអះអាងថា បច្ចុប្បន្ន នួន ជា មានការឈឺចុកចាប់ និងមិនស្រួលខ្លួន ដែលផលវិបាកទាំងនេះបានធ្វើឲ្យប៉ះពាល់ដល់សមត្ថភាពក្នុងការផ្តង់អារម្មណ៍លើបញ្ហាអង្គហេតុដ៏ស្មុគស្មាញ ។[៦២] មេធាវីការពារក្តីបានអះអាងទៀតថា ជនជាប់ចោទ នួន ជា នៅតែមានជំងឺជាច្រើនរួមទាំង *«ការចងចាំរយៈពេលខ្លីបំផុត ដែលជាធម្មតា មិនលើសពីពីរបីនាទីឡើយ»* ហើយថា ជំងឺមួយចំនួនកាន់តែចុះដុនដាបទៅៗ ។[៦៣] គួររំឭកថា កាលពីខែមីនា ឆ្នាំ២០១៣ អ្នកជំនាញរកឃើញថាជនជាប់ចោទ នួន ជា មានបញ្ហាឆ្អឹងខ្នង និងចុះខ្សោយផ្នែកសាច់ដុំដោយសារ នួន ជា ធ្វើចលនារាងកាយតិចតួចពេក ។

នៅក្នុងសារណានេះដែរ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ស្នើសុំអង្គជំនុំជម្រះសាលាដំបូងធ្វើសវនាការតែពេលព្រឹកប៉ុណ្ណោះ ក្នុងករណីអង្គជំនុំជម្រះរកឃើញថាជនជាប់ចោទ នួន ជា មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។ សវនាការត្រូវ



កងរាជអាវុធហត្ថរបស់ លន់ នល់ ក្នុងពិធីហ៊ឹកហាត់នៅទីក្រុងភ្នំពេញ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាប់ផ្តើមនៅម៉ោង ៧:៣០ នាទីព្រឹក (ជាធម្មតាអង្គជំនុំជម្រះបើកសវនាការនៅម៉ោង៩ព្រឹក) ជាពេលវេលាដែល នួន ជា អាចផ្តង់អារម្មណ៍បានល្អបំផុត ។

ក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ក៏បានដាក់សារណាជាលាយលក្ខណ៍អក្សរអំពីស្ថានភាពសុខភាពរបស់ ខៀវ សំផន ជូនអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃជាមួយគ្នានឹងក្រុមមេធាវីការពារក្តី នួន ជា ដែរ ។ មេធាវីការពារក្តីអះអាងថា ខៀវ សំផន ពុំអាចចូលរួមសវនាការបាន៤ថ្ងៃក្នុងមួយសប្តាហ៍ជាប់ៗគ្នាដូចពេលមុនឡើយ ពីព្រោះឥឡូវនេះ ខៀវ សំផន មានអាការៈឆាប់ហត់ និងសមត្ថភាពក្នុងការផ្តង់អារម្មណ៍មានការថយចុះ ។[៦៤] ក្រៅពីនេះ ខៀវ សំផន មានជំងឺប្រព័ន្ធដង្ហើម ដែលតម្រូវឲ្យចូលសម្រាកនៅមន្ទីរពេទ្យជាញឹកញាប់ ។[៦៥] យោងទៅលើស្ថានភាពទាំងនេះ ក្រុមមេធាវីការពារក្តីស្នើសុំឲ្យកាត់បន្ថយពេលវេលាធ្វើសវនាការមកត្រឹម៤ព្រឹកក្នុងមួយសប្តាហ៍ ដោយចាប់ផ្តើមពីម៉ោង ៩ព្រឹក ដល់ម៉ោង ១១សៀល ឬ ៣ថ្ងៃពេញក្នុងមួយសប្តាហ៍ ។

ជាលទ្ធផល នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចចាត់តាំងវេជ្ជបណ្ឌិត ហ៊ុយណា ហ្វារ៉ែស្សេល វេជ្ជបណ្ឌិត ចាន់ គិនមីង និងវេជ្ជបណ្ឌិត ហួត លីនណា ឲ្យធ្វើការពិនិត្យវាយតម្លៃអំពីសម្បទារបស់ជនជាប់ចោទ នួន ជា និងខៀវ សំផន ឡើងវិញ ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះកត់សម្គាល់ថា «*ទោះបីជាមេធាវីការពារក្តី នួន ជា ពុំបានដាក់ជូនភស្តុតាងរឹងមាំដើម្បីគាំទ្រដល់សំណើរបស់ខ្លួនយ៉ាងណាក្តី ក៏អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងបរិបទនៃការរៀបចំសវនាការ វាសមស្រប និងចាំបាច់នៅក្នុងការពិនិត្យវាយតម្លៃសម្បទារបស់ជនជាប់ចោទ ដោយពិចារណាទៅលើវ័យចាស់ជរា និងស្ថានភាពទន់ខ្សោយរបស់គាត់ ហើយការពិនិត្យវាយតម្លៃលើកចុងក្រោយដោយអ្នកជំនាញនោះបានកន្លងផុតទៅជាយូរមកហើយ និងមានកិច្ចដំណើរការនីតិវិធីជាច្រើនទៀតនៅក្នុងសំណុំរឿង០០២/០២ ដែលតម្រូវឲ្យមានការចូលរួមពីជនជាប់ចោទ*» ។[៦៦]

ទោះបីជាយ៉ាងណាក្តី អង្គជំនុំជម្រះពុំទាន់សម្រេចទៅលើសំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ដែលសុំឲ្យកាត់បន្ថយរយៈពេលធ្វើសវនាការនៅឡើយ ។ អង្គជំនុំជម្រះផ្តល់ហេតុផលថា ខ្លួនពុំអាចសម្រេចអំពីបញ្ហានេះបាន គឺដោយសារមានការផ្តល់ព័ត៌មានផ្ទុយគ្នាពាក់ព័ន្ធនឹងបញ្ហាសុខភាពរបស់ជនជាប់ចោទ ខៀវ សំផន ។ ដាក់ស្នែងសារណាជាលាយលក្ខណ៍អក្សររបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ អះអាងថា ខៀវ សំផន មានអាការៈឆាប់ហត់ និងសមត្ថភាពក្នុងការផ្តង់អារម្មណ៍មានការថយចុះ យកមកធ្វើជាហេតុផលក្នុងការស្នើសុំអង្គជំនុំជម្រះឲ្យកាត់បន្ថយម៉ោងធ្វើសវនាការ ។ ប៉ុន្តែនៅក្នុងពេលសវនាការថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ មេធាវីការពារក្តី ខៀវ សំផន អះអាងថា ខៀវ សំផន មានសុខភាពល្អ និងមិនមានអ្វីចោទជាបញ្ហានោះទេ ។ អង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចអំពីបញ្ហានេះ បន្ទាប់ពីជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រូវបានវាយតម្លៃសុខភាពរួចរាល់សិន ។

កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចលើកាយសម្បទារបស់ជនជាប់ចោទពីររូបគឺ នួន ជា និង ខៀវ សំផន ថាមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការសំណុំរឿង០០២/០២ ។ សេចក្តីសម្រេចនេះត្រូវបានធ្វើឡើង បន្ទាប់ពីជនជាប់ចោទទាំងពីរត្រូវបានត្រួតពិនិត្យដោយអ្នកជំនាញវេជ្ជសាស្ត្រទាំងបីរូបគឺមានវេជ្ជបណ្ឌិត ហ៊ុយណា ហ្វារ ស្សេល វេជ្ជបណ្ឌិត ចាន់ គិនមីង និងវេជ្ជបណ្ឌិត ហួត លីនណា ។ អ្នកជំនាញបានសន្និដ្ឋាន ថាជនជាប់ចោទ នួន ជា និង ខៀវ សំផន មិនមានជំងឺផ្លូវចិត្តទេ និងមិនឃើញមានភស្តុតាង អំពីការចុះខ្សោយខាងសតិបញ្ញាស្មារតី ដែលខុសពីធម្មតានៃបញ្ញាស្មារតីរបស់មនុស្ស ដែលមានវ័យ និងសាវតាដូចគាត់នោះដែរ ។ អ្នកជំនាញយល់ឃើញថា នួន ជា និង ខៀវ សំផន អាចចូលរួមសវនាការដែលមានរយៈពេលពេញលេញនិងពេលវេលាសម្រាកជាធម្មតាទៅតាមកាលវិភាគរបស់តុលាការបាន ។ បន្ទាប់ពីបានពិនិត្យរបាយការណ៍របស់អ្នកជំនាញ និងរបាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍ទាក់ទងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា នួន ជា និង ខៀវ សំផន មិនមានបញ្ហាផ្នែករាងកាយ ឬបញ្ញាស្មារតីដែលធ្វើឲ្យគាត់មិនអាចចូលរួមប្រកបដោយអត្ថន័យក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២/០២ឡើយ ។

# វិសាលភាពនៃការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០២/០១

ឌី សុជាតា

## ១) សេចក្តីផ្តើម

ប្រជាជនកម្ពុជាទាំងមូល រួមទាំងអ្នកដែលបានឆ្លងកាត់ និង អ្នកកើតក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារការបំផ្លិចបំផ្លាញ និងការកាប់សម្លាប់យ៉ាងសាហាវឃោរឃៅរបស់ខ្មែរក្រហម ។ របបកម្ពុជាប្រជាធិបតេយ្យបានដឹកនាំប្រទេសកម្ពុជាអស់រយៈពេល ៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ គិតចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដោយបានធ្វើឲ្យបាត់បង់ជីវិតប្រជាជនប្រមាណជាងបីលាននាក់ និងបន្សល់ទុកនូវវិនាសកម្ម យ៉ាងធំសម្បើមដល់ប្រទេសជាតិទាំងមូល ។ ដើម្បីស្វែងរកយុត្តិធម៌ជូនប្រជាជាតិទាំងមូលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបង្កើតឡើងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង អង្គការសហប្រជាជាតិ ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ និង អ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅក្នុងរបបនោះ ។ តុលាការនេះក៏បង្កើតឡើងក្នុងគោលបំណងលើកកម្ពស់វប្បធម៌ទប់ស្កាត់ មិនឲ្យមានសាជាថ្មីនៃឧក្រិដ្ឋកម្មយ៉ាងព្រៃផ្សៃបែបនេះនៅគ្រប់ទិសទីលើពិភពលោក និងក្លាយទៅជាតុលាការគំរូសម្រាប់ប្រព័ន្ធយុត្តិធម៌ប្រទេសកម្ពុជា និងក្នុងសាកលលោកទាំងមូល ។ វិធានផ្ទៃក្នុងនៃសាលាក្តីកាត់ទោសខ្មែរក្រហមបានអនុញ្ញាតឲ្យជនរងគ្រោះមានសិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតាមរយៈការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីចូលរួមគាំទ្រដល់ការចោទប្រកាន់ក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលទាំងឡាយ ដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅរបបកម្ពុជាប្រជាធិបតេយ្យ និងដើម្បីទទួលបាននូវសំណង ។ គួរបញ្ជាក់ថា ការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានលក្ខណៈខុសពីសាក្សី ។



សិស្សកំពុងតម្រង់ជួរចូលក្នុងសាលសវនាការនៃសាលាក្តីខ្មែរក្រហម (បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ២) តើនរណាជាដើមបណ្តឹងរដ្ឋប្បវេណី?

ដើមបណ្តឹងរដ្ឋប្បវេណី គឺជាជនរងគ្រោះដែលទទួលរងការឈឺចាប់ទាំងផ្លូវកាយ ផ្លូវចិត្ត និងខូចខាតសម្ភារ បណ្តាលមកពីឧក្រិដ្ឋកម្ម ដែលកើតមាននៅក្នុងរបបខ្មែរក្រហម ។ ឧក្រិដ្ឋកម្មទាំងនោះ ត្រូវចោទប្រកាន់នៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងត្រូវស៊ើបអង្កេត ដោយតុលាការនេះ ។ គោលបំណងនៃការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺដើម្បីការចូលរួមដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មតាមរយៈការគាំទ្រដល់ការចោទប្រកាន់ និងដើម្បីទាមទារសំណង ដែលមានតែសំណងពីរប្រភេទប៉ុណ្ណោះគឺសំណងផ្លូវចិត្ត និងសំណងសមូហភាព[៦៧] ។ តុលាការនេះសម្រេចថា ខ្លួនពុំអាចផ្តល់សំណងជាសាច់ប្រាក់បានឡើយ ដោយហេតុថា ជនរងគ្រោះមានច្រើនលើសលប់ ។ ប៉ុន្តែជនរងគ្រោះអាចទទួលបានសំណងតាមរូបភាពជារួម និងសំណងជាការគាំទ្រខាងផ្លូវចិត្ត ។ ដើម្បីក្លាយខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជនរងគ្រោះត្រូវដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយបង្ហាញអំពីអត្តសញ្ញាណឲ្យបានច្បាស់ និងបង្ហាញនូវលទ្ធផល ដោយផ្ទាល់ពីឧក្រិដ្ឋកម្ម យ៉ាងហោចណាស់បទឧក្រិដ្ឋមួយក្នុងចំណោមបទឧក្រិដ្ឋជាច្រើន ដែលត្រូវចោទប្រកាន់លើជនត្រូវចោទថា ជនរងគ្រោះពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារ ឬផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណង ។ នៅពេលពិចារណាអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថាអង្គហេតុ ដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ មានភាពពិតប្រាកដមែន ។ គួរបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការជ្រើសរើសមេធាវីរបស់ខ្លួន នៅចំពោះមុខកិច្ចដំណើរការនីតិវិធីរបស់តុលាការ ។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ បានចូលរួមក្នុងដំណើរការជំនុំជម្រះដំណាក់កាលទីមួយក្នុងសំណុំរឿង០០២ (០០២/០១) ត្រូវទទួលយកតាមរយៈសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត និងមួយចំនួនទៀតបានទទួលតាមរយៈ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដោយអនុវត្តតាមវិធាន២៣ស្ទួន(២) និង(៣) នៃវិធានផ្ទៃក្នុង ។ ដោយផ្អែកលើវិធាន និងគោលការណ៍អន្តរជាតិ បុគ្គលម្នាក់អាចត្រូវបានចាត់ទុកថាជាជនរងគ្រោះ ទោះបីជាជនល្មើសត្រូវបានកំណត់ ឬពុំត្រូវបានកំណត់អត្តសញ្ញាណ ត្រូវបានចាប់ខ្លួនចោទប្រកាន់ ឬប្រកាសថាជាពិរុទ្ធជនក៏ដោយ ។

## ៣) សំណើសុំបញ្ជាក់ពីវិសាលភាពនៃការផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី

នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ នៅពេលបញ្ចប់ការផ្តល់សក្ខីកម្មនៅក្នុងសវនាការដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ ត្រូវបានផ្តល់ឱកាសឲ្យធ្វើការថ្លែងអំពីទុក្ខសោករបស់អ្នកស្រីក្នុងអំឡុងរបបកម្ពុជាប្រជាធិប្បតេយ្យ ។ មុនពេលស្តាប់នូវការថ្លែងទុក្ខសោករបស់អ្នកស្រី សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំចៅក្រមនៃអង្គជំនុំជម្រះដោយផ្ទាល់មាត់ថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ត្រូវបានអនុញ្ញាតឲ្យថ្លែងអំពីព្យសនកម្មដែលបានទទួលរងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ។ ដោយពិចារណាលើលក្ខណៈទូទៅលើសំណើនេះ អង្គជំនុំជម្រះសាលាដំបូងបានស្នើដល់សហមេធាវីនាំមុខឲ្យធ្វើការបង្ហាញពីជំហររបស់ពួកគេជាលាយលក្ខណ៍អក្សរ ។

នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនៅក្នុងជំហរជាលាយលក្ខណ៍អក្សររបស់ខ្លួនដោយបញ្ជាក់អំពីមូលហេតុសំណើសុំថា ភាពឈឺចាប់ ដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរងគឺជាសិទ្ធិដែលមិនអាចកាត់ផ្តាច់បានអំពីលក្ខណៈសម្បត្តិជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ។ សិទ្ធិនេះអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីលេចឡើងនៅក្នុងអំឡុងពេលនៃកិច្ចពិភាក្សាដេញដោលអំពីការប៉ះទង្គិចទៅលើបុគ្គលមនុស្សពីសំណាក់អង្គហេតុដែលបានចោទប្រកាន់ ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបន្តទៀតថា ការឈឺចាប់គឺជាស្ថានភាពអូសបន្លាយនៃការឈឺចាប់ផ្លូវកាយ និងផ្លូវចិត្ត ដែលបង្កឡើងដោយព្យសនកម្មនានា ដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរង ។ ស្ថានភាពដែលមានលក្ខណៈជាបុគ្គលនេះអាចមានលក្ខណៈខុសៗគ្នា អាស្រ័យលើបុគ្គលដែលពាក់ព័ន្ធ ។ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

វេណីបានលើកឡើងថា វាពុំអាចទៅរួចទេក្នុងការ ដែលជនរងគ្រោះនៃអង្គហេតុ ដែលកើតឡើងបន្តបន្ទាប់គ្នាធ្វើការច្រៀកការឈឺចាប់របស់ខ្លួនជាចម្រៀកៗទៅតាមសម័យកាល ឬទៅតាមបច្ចេកទេសនានានោះ ។ ដើមបណ្តឹងរដ្ឋប្បវេណី ពុំអាចធ្វើការផ្សារភ្ជាប់ការឈឺចាប់ជាក់លាក់របស់ខ្លួនមួយផ្នែកទៅនឹងព្រឹត្តិការណ៍ណាមួយបានទេ នៅខណៈដែលព្រឹត្តិការណ៍ទាំងនោះបានកើតឡើងបន្តបន្ទាប់គ្នា ឬជាដំណាក់កាលៗនៅក្នុងឆាកជីវិតរបស់គាត់ ។ ប្រសិនបើដូច្នេះមែនលទ្ធផលនៃការផ្តល់សក្ខីកម្ម និងការថ្លែងទុក្ខសោកមានលក្ខណៈជាសិប្បនិម្មិត ហើយពុំបានលាតត្រដាងអំពីការឈឺចាប់ពិតប្រាកដ ដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងឡើយ ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ទៀតថា បន្ទាប់ពីមានសេចក្តីសម្រេចស្តីពីការបំបែកសំណុំរឿង០០២ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានកត់សម្គាល់ឃើញថា ការអនុវត្តជាក់ស្តែងវាពុំអាចទៅរួចទេក្នុងការណ៍ ដែលនៅខណៈពេលដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសលើកឡើងអំពីការឈឺចាប់របស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែត្រូវធ្វើដោយមានកំណត់ និងត្រូវជ្រើសរើសនូវព្យសនកម្មដែលពាក់ព័ន្ធតែទៅនឹងឧក្រិដ្ឋកម្មទាំងឡាយ ដែលកើតមានឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ ។

នៅក្នុងសំណើសុំរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ទៀតថា តាំងពីដំបូងរហូតមកដល់ពេលបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងហាក់ដូចជាបានប្រកាន់យកចក្ខុវិស័យនេះទោះជានៅក្រោយពេលមានសេចក្តីសម្រេចបំបែកសំណុំរឿងក៏ដោយ ។ មុនពេលដែលមានការពិភាក្សាថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ លោកប្រធានអង្គជំនុំជម្រះបានប្រកាសជាច្រើនលើកនៅក្នុងសវនាការថា «ដើមបណ្តឹងរដ្ឋប្បវេណីអាចលើកឡើងអំពីការឈឺចាប់ដែលខ្លួនមានអំពីព្យសនកម្មដែលខ្លួនទទួលរងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលគិតចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ សូមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ធ្វើការបង្ហាញអំពីព្យសនកម្មដែលខ្លួនបានទទួលរងនៅ ក្នុងសម័យកាលដូចបានជម្រាបជូនខាងលើ» ។ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី មានទិដ្ឋភាពខាងអង្គហេតុមួយផ្នែក និងមួយផ្នែកទៀតមានលក្ខណៈពិសេសចំពោះជនរងគ្រោះ ដែលជាដើមបណ្តឹងរដ្ឋប្បវេណី និងចំពោះភាគីនៃរឿងក្តី ។ ដោយមានឱកាសលើកឡើងពីការឈឺចាប់របស់ខ្លួន ដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសជាលើកដំបូងក្នុងឆាកជីវិត ក្នុងការបង្ហាញជាសាធារណៈ និងចំពោះមុខអង្គជំនុំជម្រះនូវការឈឺចាប់ដែលខ្លួនបានទទួលរងអស់រយៈពេលជាង៣០ឆ្នាំ និងផ្តល់ជូនអង្គជំនុំជម្រះនូវធាតុសំខាន់សម្រាប់ជាប្រយោជន៍ដល់ការវាយតម្លៃលើអង្គហេតុ ដើម្បីកំណត់អំពីភាពធ្ងន់ធ្ងរ និងការធ្វើចំណាត់ថ្នាក់ អង្គហេតុនោះ ។ ការលើកឡើងជាលក្ខណៈបុគ្គលអំពីការឈឺចាប់របស់ខ្លួន ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានស្តាប់ចម្លើយក្នុងអង្គសវនាការ បានបង្ហាញជានិមិត្តរូបនូវសេចក្តីឈឺចាប់ខ្លោចផ្សាររបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ រួមទាំងជនរងគ្រោះគ្រប់រូប ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានបន្តទៀតថា វាជារឿងមួយ ដែលមានសារសំខាន់ក្នុងការអនុញ្ញាតឲ្យមានពេលវេលាក្នុងការ ស្តាប់អំពីភាពឈឺចាប់នៅពេលដែលគេអនុញ្ញាតឲ្យមានពេលវេលាក្នុងការស្តាប់អំពីភាពឈឺចាប់នៅពេលដែលត្រូវអនុញ្ញាតឲ្យមានការបំភ្លឺក្នុងវេទិកាតុលាការពីសំណាក់ជនរងគ្រោះដែលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏បានរំឭកទៀតថា រហូតមកទល់នឹងពេលបច្ចុប្បន្ននេះសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងការឈឺចាប់មានរយៈពេលខ្លី ហើយនៅក្នុងករណីខ្លះត្រូវបានគាត់តែងជាលាយលក្ខណ៍អក្សរជាមុន ដើម្បីអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីអាចលើកឡើងបានសព្វគ្រប់ជ្រាលជ្រៅនូវអ្វីដែលខ្លួនមានបំណង ដើម្បីជៀសវាងកុំឲ្យមានការប៉ះពាល់ផ្នែកអារម្មណ៍ខ្លាំងពេក ។ តុលាការពុំអាចបង្រួមសារសំខាន់នៃឱកាសនេះ សម្រាប់បុគ្គលពាក់ព័ន្ធ ដែលអាចឲ្យពួកគាត់មានការលំបាកក្នុងការថ្លែងឲ្យបានស៊ីជម្រៅ និងច្បាស់លាស់ អំពីអ្វីមួយដែលមានសារៈសំខាន់បំផុតក្នុងជីវិតរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះឡើយ ។ នៅក្នុងសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ទៀតថា វាមានសារសំខាន់សម្រាប់ប្រជាជនកម្ពុជា និងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការណ៍ដែលសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងសក្ខីកម្មដែលពាក់ព័ន្ធនឹងអង្គហេតុ និងសក្ខីកម្ម ដែល

ពាក់ព័ន្ធនឹងការឈឺចាប់ដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចពិភាក្សាដេញដោល ។ នេះជាធាតុផ្សំមួយក្នុងចំណោមធាតុផ្សំទាំងឡាយ ដែលនាំឲ្យមានយុត្តិធម៌ពេញលេញនៅក្នុងការជំនុំជម្រះក្តីនេះ ។ ក្នុងការផ្សះផ្សាជាតិមានបង្កប់អត្ថន័យថា ជនរងគ្រោះ ជាពិសេសដើមបណ្តឹងរដ្ឋប្បវេណី មានការពេញចិត្តចំពោះដំណើរការនីតិវិធី និងសវនាការ ។ ដើមបណ្តឹងរដ្ឋប្បវេណីមានបំណងមុតមាំក្នុងការនិយាយអំពីការឈឺចាប់ដែលខ្លួនបានទទួលរងអស់រយៈពេល៣០ឆ្នាំកន្លងមក ។ ដោយហេតុថា តុលាការពុំអាចធ្វើការបែងចែកការឈឺចាប់របស់មនុស្សម្នាក់ បានដូច្នេះវាពុំអាចទទួលយកបានទេចំពោះការកម្រិតការថ្លែងពីការឈឺចាប់ក្នុងក្របខណ្ឌនៃដំណើរការនីតិវិធីសំណុំរឿង០០២/០១ ។ ជាចុងក្រោយ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំដល់អង្គជំនុំជម្រះមេត្តាបញ្ជាក់អំពីការអនុវត្តជាក់ស្តែងរបស់អង្គជំនុំជម្រះចំពោះបញ្ហាស្តីអំពីវិសាលភាពនៃការផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការឈឺចាប់របស់ខ្លួនទាំងមូល និងសព្វជ្រុងជ្រោយនៅក្នុងសំណុំរឿង ០០២ ។ ការថ្លែងពីការឈឺចាប់នេះក៏អាចអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញនូវទុក្ខសោក និងក្តីឈឺចាប់ក្នុងនាមជាជនរងគ្រោះទាំងអស់ផងដែរ ដែលអាចរួមចំណែកដល់យុត្តិធម៌ និងការផ្សះផ្សាជាតិ ។ ហេតុដូច្នេះសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសថា នៅពេលបញ្ចប់ការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីអាចថ្លែងពាក់ព័ន្ធនឹងទុក្ខសោកវេទនាទាំងអស់ ដែលពួកគាត់បានជួបប្រទះក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យតែម្តង ។

## ៤) ជំហររបស់សហព្រះរាជអាជ្ញាលើវិសាលភាពនៃការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ចំពោះភាគីសហព្រះរាជអាជ្ញា ក៏បានធ្វើការគាំទ្រចំពោះសំណើរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីថា ជាក់ស្តែងនៅពេលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវចាត់ទុកថា អាចទទួលយកបានដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះសំណុំរឿង០០២ទាំងមូល ហើយការបែងចែក ការឈឺចាប់រវាងសំណុំរឿង០០២/០១ និងផ្នែកដែលនៅសេសសល់នៃសំណុំរឿង០០២ មានលក្ខណៈសិប្បនិម្មិត ។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា គោលបំណងនៃការថ្លែងអំពីទុក្ខសោកទាំងនេះត្រូវបានកម្រិតត្រឹមផលប៉ះពាល់ដល់ជនរងគ្រោះប៉ុណ្ណោះ ដូច្នេះមិនចាំបាច់កំណត់វិសាលភាពនៃការថ្លែងអំពីទុក្ខសោកទាំងនោះឡើយ ។

## ៥) ជំហររបស់មេធាវីការពារក្តីលើវិសាលភាពនៃការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី

### ក) មេធាវីការពារក្តី ខៀវ សំផន

មេធាវីការពារក្តី ខៀវ សំផន បានឆ្លើយតបនៅក្នុងបន្ទប់សវនាការថា ក្នុងការពិពណ៌នាពីព្យសនកម្ម ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ពីអង្គហេតុដែលពុំមានការអនុញ្ញាត ដែលជាអង្គហេតុ មិនជាប់ពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ ។ ទាក់ទិននឹងអង្គហេតុទាំងនេះ ជនជាប់ចោទពុំមានឱកាសក្នុងការការពារខ្លួនឡើយ ។ មេធាវីបន្តថា ទោះជាមានការទទួលស្គាល់ថា ការឈឺចាប់ផ្លូវចិត្ត ដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងអាចត្រួតលើគ្នា ដែលពិបាកក្នុងការបំបែកចេញជាផ្នែកៗក៏ដោយ ក៏វាពុំមែនជាព្យសនកម្មពិតប្រាកដលើរាងកាយ ដែលពិតជាលទ្ធផលនៃព្រឹត្តិការណ៍ជាក់លាក់នោះឡើយ ។ មេធាវីការពារក្តី ខៀវ សំផន បន្តទៀតថា មិនត្រូវអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសក្ខីកម្មអំពីបញ្ហានានាដែលពុំមែនជាផ្នែកនៃសំណុំរឿង ០០២/០១ឡើយ ពីព្រោះអង្គហេតុទាំងនេះនឹងមិនត្រូវបានយកមកពិភាក្សា ឬសួរដេញដោល ដូច្នេះមិនមានប្រយោជន៍អ្វីក្រៅពីធ្វើឲ្យប៉ះពាល់ដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីនោះទេ ។ ទោះបីជាមានការយល់ស្របថា ការជំនុំជម្រះដ៏ត្រឹមត្រូវ និងប្រកបដោយយុត្តិធម៌អាចមានឥទ្ធិពលលើការផ្សះផ្សាជាតិក៏ដោយ ក៏ការផ្សះផ្សាជាតិនេះមិនអាចត្រូវយកមកប្រើជាលេសមួយ ដើម្បីរំលោភបំពានលើគោលការណ៍ជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដែលគេប្រើប្រាស់ជាមូលដ្ឋាននោះដែរ ។ មេធាវីការពារក្តីស្នើឲ្យអង្គជំនុំជម្រះបដិសេធសំណើ និងបង្គាប់ឲ្យភាគីទាំងអស់គោរពព្រំដែនកំណត់ជាលទ្ធផលចេញមកពីការបំបែកកិច្ចដំណើរការនីតិវិធី ដូចដែលអង្គជំនុំជម្រះ បានបង្គាប់នោះ ដោយផ្អែកលើមូលដ្ឋានថា ព្រំដែនកំណត់ទាំងនោះនឹងត្រូវបានពិចារណា

ឡើងវិញ ប្រសិនបើអង្គជំនុំជម្រះយល់ស្របតាមសំណើរបស់សហមេធាវីនាំមុខ ។

### ៥) មេធាវីការពារក្តី នួន ជា

ចំពោះមេធាវីការពារក្តី នួន ជា បានទទួលស្គាល់ថា ការបំបែកនូវការទទួលរងការឈឺចាប់ជាផ្នែកៗ គឺជាការលំបាកក៏ដោយ មេធាវីកត់សម្គាល់ថា ខ្លួនជួបប្រទះនឹងបញ្ហាប្រឈមដូចគ្នា



នួន ជា ក្នុងបន្ទប់សវនាការនៃសាលាក្តីខ្មែរក្រហម
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងការកំហិតវិសាលភាពលើអង្គហេតុទាំងឡាយដែលខ្លួនយល់ឃើញថាជាប់ពាក់ព័ន្ធ ក្រោយពីមានដីកាបំបែកកិច្ចដំណើរការនីតិវិធី ។ ដូច្នេះមេធាវីការពារក្តី នួន ជា លើកឡើងថា ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានផ្តល់ឱកាស ដើម្បីនិយាយរៀបរាប់អំពីអ្វីៗទាំងអស់ ដែលបានជួបប្រទះនោះ មេធាវីស្នើថា កូនក្តីរបស់ខ្លួន (ជនជាប់ចោទ នួន ជា) គប្បីទទួលបានឱកាសដូចដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីទទួលបានដែរ ដើម្បីឲ្យមានសមភាពក្នុងការថ្លែងនេះ ។

### ៦) សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើវិសាលភាពនៃការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់នូវអំណះអំណាងរបស់ភាគីទាំងអស់ ចំពោះវិសាលភាពនៃការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចមួយ នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ។ សេចក្តីសម្រេចនេះបានឯកភាពតាមសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលស្នើសុំអនុញ្ញាតឲ្យដើមបណ្តឹងធ្វើការថ្លែងអំពីទុក្ខវេទនាទាក់ទងនឹងសម័យកាលកម្ពុជាប្រជាធិបតេយ្យទាំងមូល ។ អង្គជំនុំជម្រះសាលាដំបូងក៏បានបញ្ជាក់ថា ខ្លួននឹងបន្តលំដាប់លំដោយនៃការសួរសំណួរដូចពេលបច្ចុប្បន្នទៅដើមបណ្តឹងរដ្ឋប្បវេណី និងការអនុវត្តរបស់ខ្លួន ក្នុងការអនុញ្ញាតឲ្យមេធាវីការពារក្តីធ្វើសេចក្តីអត្ថាធិប្បាយស្តីពីការថ្លែងអំពីទុក្ខវេទនា បន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការ ។ ប៉ុន្តែអង្គជំនុំជម្រះណែនាំឲ្យសហមេធាវីនាំមុខរៀបចំការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីក្នុងលក្ខណៈមួយដែលបែងចែងរវាងសក្ខីកម្មលើអង្គហេតុ និងសេចក្តីថ្លែងទាក់ទងនឹងទុក្ខវេទនា ។ អង្គជំនុំជម្រះសាលាដំបូងក៏បានប្រកាសថា នៅពេលវាយតម្លៃអំពីភ័ស្តុតាងនៅក្នុងសាលក្រមទម្ងន់ដែលត្រូវផ្តល់ទៅឲ្យសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវបានវាយតម្លៃទៅតាមករណីនីមួយៗ ដោយពិនិត្យទៅលើភាពអាចជឿជាក់បាននៃសក្ខីកម្មនោះ ។ បន្ទាប់ពីការវាយតម្លៃ ដែលមានសំអាងហេតុអំពីភ័ស្តុតាងនេះ រាល់មន្ទិលសង្ស័យលើពិរុទ្ធភាពនឹងត្រូវបកស្រាយជាប្រយោជន៍ដល់ជនជាប់ចោទ ។

### កំណត់សម្គាល់

១ “កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ” ហៅកាត់ថា “កិច្ចព្រមព្រៀង”ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ ត្រង់មាត្រា ១៤ ។

២ មាត្រា១៥នៃកិច្ចព្រមព្រៀង

៣ មាត្រា១៦នៃកិច្ចព្រមព្រៀង

៤ មាត្រា១៧នៃកិច្ចព្រមព្រៀង

៥ សេចក្តីប្រកាសព័ត៌មាន អង្គជំនុំជម្រះសាលាដំបូងប្រកាសកាត់បន្ថយចំនួនថ្ងៃសវនាការប្រចាំសប្តាហ៍ក្នុងសំណុំរឿង០០២/០១ ចុះថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០១២ ។ អាចរកបានក្នុងគេហទំព័រ ៖ www.eccc.gov.kh/articles/23098

៦ “តុលាការខ្មែរក្រហមជូនដំណឹងដល់បុគ្គលិកជាតិពីកង្វះថវិកាសម្រាប់ខែធ្នូនេះ” ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២ ។ អាចរកបានក្នុងគេហទំព័រ ៖ www.khmer.rfi.fr/khmer-rouge-tribunal-lack-of-budget-for-national-employee

៧ សូមមើលអត្ថបទ “រដ្ឋាភិបាលកម្ពុជាបង្កើនថវិការហូតដល់ ១.៨លានដុល្លារសម្រាប់តុលាការខ្មែរក្រហម” ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.khmer.rfi.fr/aide-financiere-du-gouvernement-kmer-au-tribunal-khmer-rouge

៨ “បុគ្គលិកសាលាក្តីមួយចំនួនអាចលាឈប់ដោយសារបញ្ហាប្រាក់ខែ” ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ ។ អាចរកបានក្នុងគេហទំព័រ ៖

៩ “បុគ្គលិកជាតិនៅតុលាការខ្មែរក្រហមដាក់ឱសានវាទត្រឹមដំណាច់ខែមករា ពីរឿងប្រាក់ខែ” ចុះថ្ងៃទី២៣ ខែ មករា ឆ្នាំ២០១៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.khmer.rfi.fr/print/79367

១០ “វិបត្តិសាលាក្តីខ្មែរក្រហមនៅតែបន្តអូសបន្លាយគ្មានច្រកចេញ” ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.khmer.rfi.fr/La-crise-au-tribunal-khmer-rouge-continue

១១ ប្រតិចារិកសវនាការលើអង្គសេចក្តីនៃសំណុំរឿង០០២ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៣ ឯកសារលេខ E1/174.1 ទំព័រ១ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.eccc.gov.kh/document/court/25939

១២ “បុគ្គលិកជាតិផ្នែកបកប្រែពហិការមិនធ្វើការ សវនាការសាលាក្តីខ្មែរក្រហមត្រូវផ្អាក” ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ។ អាចរកបានក្នុងគេហទំព័រ ៖ www.khmer.rfi.fr/Les-traducteurs-ne-travaillent-pas-le-proces-n-a-pas-lieu

១៣ “សាលាក្តីខ្មែរក្រហម ៖ អ្នកភាពបកប្រែបន្ធូរលក្ខខណ្ឌ” ចុះផ្សាយថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.khmer.rfi.fr/Les-traducteurs-du-tribunal-moins-exigeants

១៤ “បុគ្គលិកតុលាការខ្មែរក្រហមផ្នែកប្រតិចារិកធ្វើកូដកម្មដែរ” ចុះផ្សាយថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.khmer.rfi.fr/Les-employes-charges-de-transcription-du-tribunal-khmer-rouge-font-la-greve

១៥ “បុគ្គលិកជាតិតុលាការខ្មែរក្រហមចូលធ្វើការវិញ តែនៅចាំកិច្ចសន្យាការងារ” ចុះផ្សាយថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០១៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.khmer.rfi.fr/Les-employes-du-tribunal-khmer-rouge-reprennent-leur-travail

១៦ “បុគ្គលិកជាតិនៅសាលាក្តីខ្មែរក្រហមអាចធ្វើកូដកម្មជាថ្មី?” ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.khmer.rfi.fr/Les-employes-du-tribunal-khmer-rouge-peuvent-recommencer-la-greve%3F

១៧ សវនាការថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣ ។ រូបភាពវីដេអូអាចរកបានក្នុងគេហទំព័រ ៖ http://www.youtube.com/watch?v=U0O9IhVunR4&list=PL5hT6Kk09kQGFbwTQrSlm2JoEp_HYt8CK&index=33 (ត្រង់នាទីទី១៧)

១៨ “បុគ្គលិកជាតិនៅសាលាក្តីខ្មែរក្រហម នឹងទទួលបានប្រាក់ខែ ៤ខែដើមឆ្នាំ” ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http:// www.khmer.rfi.fr/Les-employes-du-tribunal-khmer-rouge-vont-recevoir-leur-quatre-salaire

១៩ “សាលាក្តីខ្មែរក្រហមកាត់បន្ថយបុគ្គលិក១០ភាគរយ” ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.khmer.rfi.fr/cambodia/20130702-khmer-rouge-court-dismiss-staff

២០ “សាលាក្តីខ្មែរក្រហមប្រកាសនីតិវិធីបន្តជាច្រើន ទោះជាជួបវិបត្តិថវិកា” ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http:// www.khmer.rfi.fr/nouvelle-mesure-tribunal-khmer-rouge-pour-poursuivre-cas002

២១ “មន្ត្រីរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ ចេញដំណើរទៅបណ្តាប្រទេសសមាជិកអាស៊ាន ដើម្បីរៃអង្គាសថវិកាជួយសាលាក្តីខ្មែរក្រហម” ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.khmer.rfi.fr/officers-raise-fund-for-eccc

២២ “បុគ្គលិកសាលាក្តីខ្មែរក្រហម ១០០នាក់ ដាក់ញត្តិស្នើសុំឈប់ធ្វើការងារ” ចុះផ្សាយថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.khmer.rfi.fr/cambodia/20130823-khmer-rouge-court-member-salary

២៣ “វិបត្តិថវិកាបន្តញាំញីនៅសាលាក្តីខ្មែរក្រហម នាំឲ្យបុគ្គលិកជាតិមិនទទួលបានប្រាក់ខែនៅខែសីហា” ។ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣

២៤ “សាលាក្តីខ្មែរក្រហមសល់ក្តីសង្ឃឹមចុងក្រោយលើការអំពាវនាវរបស់លោក បាន គីមូន” ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០១៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.khmer.rfi.fr/tribunal-khmer-rouge-crise-budgetaire-appel-de-BanKimoon

២៥ កិច្ចសម្ភាសន៍វាងលោក ឌីម សុវណ្ណរ៉ុំ ជាមួយវិទ្យុបារាំងអន្តរជាតិនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.khmer.rfi.fr/DimSovannarom-Tribunal-khmer-rouge-vit-avec-fonds-volontairement-donnes

២៦ “អង្គការសហប្រជាជាតិសម្តែងការព្រួយបារម្ភចំពោះវិបត្តិថវិកាសាលាក្តី” ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៣ អាចរកបានក្នុងគេហទំព័រ ៖ http://www.khmer.rfi.fr/cambodia/20130905-UN-worries-

about-ECCC

២៧ «ភាគីកម្ពុជានៃសាលាក្តីខ្មែរក្រហមទទួលមូលនិធិសង្គ្រោះបន្ទាន់» ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.rfa.org/khmer/news/krt/eccc-kh-side-gets-1million-loan-from-un-side-09182013074445.html ។ អាចរកមើលបន្ថែមនៅក្នុងគេហទំព័រ ៖ http://www.khmer.rfi.fr/OnuPays-donnateurs-donnent-1%2C15Mdollars-au-tribunal-khmer-rouge

២៨ «គម្រោងថវិកាសម្រាប់ឆ្នាំ ២០១៤-២០១៥ របស់ អ.វ.ត.ក ត្រូវបានអនុម័ត» ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.eccc.gov.kh/articles/30136

២៩ អនុស្សរណៈស្តីអំពី«ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់សំណុំរឿង០០២/០២ និងការកំណត់កាលបរិច្ឆេទនៃការដាក់ឯកសារនាពេលខាងមុខ» ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ឯកសារលេខ E301/5 កថាខណ្ឌទី ៥ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.eccc.gov.kh/search/node/E301/5

៣០ «សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងវិសាលភាពនៃសំណុំរឿង០០២/០២ និងការកំណត់កាលបរិច្ឆេទសវនាការ រួមជាមួយឧបសម្ព័ន្ធ ក» ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៣ ។ ឯកសារលេខ E301/2 កថាខណ្ឌទី១០ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.eccc.gov.kh/document/court/28236

៣១ ឯកសារ E301/2 កថាខណ្ឌទី១៣-១៤ ។

៣២ ឯកសារ E301/2 កថាខណ្ឌទី១៥ ។

៣៣ ឯកសារ E301/2 កថាខណ្ឌទី១១ ។

៣៤ «សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្តីអំពីវិសាលភាពនៃសំណុំរឿង ០០២,០២» ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ។ ឯកសារលេខ E301/5/3 កថាខណ្ឌទី១ ។ អាចរកបានក្នុងគេហទំព័រ ៖ www.eccc.gov.kh/search/node/E301/5/3

៣៥ ឯកសារលេខ E301/5/3 កថាខណ្ឌទី១៩

៣៦ ឯកសារលេខ E301/5/3 កថាខណ្ឌទី២១-២៨ ។

៣៧ ឯកសារលេខ E301/5/3 កថាខណ្ឌទី៣៦ ។

៣៨ «សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីលោក ខៀវ សំផន ពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០២/០២» ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ។ ឯកសារលេខ E301/5/2 កថាខណ្ឌទី២ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.eccc.gov.kh/document/court/29959

៣៩ ឯកសារលេខ E301/5/2 កថាខណ្ឌទី៣ ។

៤០ ឯកសារលេខ E301/5/2 កថាខណ្ឌទី៦ ។

៤១ ឯកសារលេខ E301/5/2 កថាខណ្ឌទី៩ ។

៤២ ឯកសារលេខ E301/5/2 កថាខណ្ឌទី១០ ។

៤៣ «ចម្លើយតបរបស់ នួន ជា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ដែលសុំឲ្យដាក់សារណាទាក់ទិននឹងវិសាលភាពនៃសំណុំរឿង ០០២,០២» ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ។ ឯកសារលេខ E301/5/4 កថាខណ្ឌទី៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.eccc.gov.kh/search/node/E301/5/4

៤៤ ឯកសារលេខ E301/5/4 កថាខណ្ឌទី៤ ។

៤៥ ឯកសារលេខ E301/5/4 កថាខណ្ឌទី៧ ។

៤៦ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ មាត្រា ៤ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.eccc.gov.kh/document/legal/law-on-eccc

៤៧ «ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២» ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ។ ឯកសារលេខ D427 កថាខណ្ឌទី ១៦១៣ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.eccc.gov.kh/search/node/d427

៤៨ ឯកសារលេខ D427 កថាខណ្ឌទី៧៩៧ ។

៤៩ ឯកសារលេខ D427 កថាខណ្ឌទី៨០២ ។

៥០ ឯកសារលេខ D427 កថាខណ្ឌទី៨០៣ ។

៥១ ឯកសារលេខ D427 កថាខណ្ឌទី៨០៧ ។

៥២ ឯកសារលេខ D427 កថាខណ្ឌទី៨១៤ ។

៥៣ ឯកសារលេខ D427 កថាខណ្ឌទី៨២០ ។

៥៤ ឯកសារលេខ D427 កថាខណ្ឌទី៧៥៦ ។

៥៥ ឯកសារលេខ D427 កថាខណ្ឌទី៧៦៣ ។

៥៦ ឯកសារលេខ D427 កថាខណ្ឌទី៧៦៥ ។

៥៧ ឯកសារលេខ D427 កថាខណ្ឌទី៧៦៦ ។

៥៨ ឯកសារលេខ D427 កថាខណ្ឌទី៧៦៩ ។

៥៩ ឯកសារលេខ D427 កថាខណ្ឌទី៧៧០ ។

៦០ ឯកសារលេខ D427 កថាខណ្ឌទី៧៧៩ ។

៦១ ឯកសារលេខ D427 កថាខណ្ឌទី៧៨៥-៧៨៦ ។

៦២ «សេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ និងដីកាចាត់តាំងអ្នកជំនាញ» ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ឯកសារលេខ E301/10 ត្រង់កថាខណ្ឌទី២ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.eccc.gov.kh/document/court/30010

៦៣ ឯកសារលេខ E301/10 ត្រង់កថាខណ្ឌទី៧ ។

៦៤ ឯកសារលេខ E301/10 ត្រង់កថាខណ្ឌទី៣ ។

៦៥ ឯកសារលេខ E301/10 ត្រង់កថាខណ្ឌទី៨ ។

៦៦ ឯកសារលេខ E301/10 ត្រង់កថាខណ្ឌទី៧ ។

៦៧ វិធាន២៣ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិសោធនកម្មលើកទី៨ ។



ខៀវ សំផន (ទីពីររាប់ពីស្តាំ) ទទួលប្រធានាធិបតី ណេវិន ពេលទស្សនកិច្ចប្រទេសកម្ពុជាក្នុង ខែវិច្ឆិកា ឆ្នាំ១៩៧៧
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)



គណៈប្រតិភូបរទេសដើរមើលលំនៅដ្ឋានដែលត្រូវបានបោះបង់ចោលក្នុងទសវត្ស៨០ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)



ទិដ្ឋភាព សិស្ស និស្សិត ប្រជាជន និងអ្នកសារព័ត៌មាន កំពុងដើរតម្រង់ចូលសាលសវនាការ នៃសាលាក្តីខ្មែរក្រហម
ដើម្បីតាមដានកិច្ចដំណើរការនីតិវិធី (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ពន្យល់ពាក្យសំខាន់ៗ

**១**-ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ៖ សំដៅទៅលើដីកាជាលាយលក្ខណ៍អក្សរ ដែលចេញដោយសហព្រះរាជអាជ្ញា ស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតបើកការស៊ើបសួរ ចំពោះករណីបទល្មើសណាមួយ និងធ្វើការចោទប្រកាន់ ។

**២**-ដីកាសន្និដ្ឋានស្ថាពរ ៖ សំដៅទៅលើដីកាជាលាយលក្ខណ៍អក្សរ ដែលចេញដោយសហព្រះរាជអាជ្ញាស្នើសុំទៅសហចៅក្រមស៊ើបអង្កេតឲ្យធ្វើដីកាដំណោះស្រាយ ចំពោះសំណុំរឿងណាមួយ ។

**៣**-ដីកាដំណោះស្រាយ ៖ សំដៅទៅលើដីកាចុងក្រោយ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ នៅពេលបញ្ចប់ការស៊ើបសួរដែលអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ ។


មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល ៖ dccam@online.com.kh

គេហទំព័រ ៖ www.dccam.org ឬ www.cambodiatribunal.org



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ

*Bereau of Democracy, Human Rights, and Labor,*

*U.S. Department of State*


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | នួន ជា, បងនួន, បងទី២ | | | |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



**ឌី សុជាតា**
បរិញ្ញាបត្រច្បាប់ សិក្សាជាភាសាអង់គ្លេស ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**លឹម ជ័យច័ត្ត**
បរិញ្ញាបត្រច្បាប់ និងបរិញ្ញាបត្រសេដ្ឋកិច្ចពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យា-សាស្ត្រសេដ្ឋកិច្ច និងជាជ័យលាភីថ្នាក់ជាតិ ទទួលបានពានរង្វាន់មេដាយមាសក្នុងការប្រកួតសវនាការប្រឌិត ឆ្នាំ២០១០ ។



**ទូន ឡៃហុល**
បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**ចាន់ ប្រាថ្នា**
បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



អ្នកភូមិកំពុងតម្រង់ជួរដើម្បីចូលក្នុងបន្ទប់សវនាការនៅសាលាក្ដីខ្មែរក្រហម (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)